DRAFT

## គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

# របាយការណ៍សង្ខេប

## ស្តីពី

## ដំណើរការពិគ្រោះយោបល់ជាមុន នៅក្នុងប្រទេសកម្ពុជា

## លើគម្រោងទំនប់វារីអគ្គិសនី ដនសាហុង របស់ឡាវ



**រៀបចំដោយៈ**

**ក្រុមការងារថ្នាក់ជាតិ សម្រាប់ការពិគ្រោះយោបល់ជាមុន**
**លើសំណើគម្រោងទំនប់វារីអគ្គិសនី ដន សាហុង**
**និង**
**អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា**

### ខែធ្នូ ឆ្នាំ២០១៤

## មាតិការបាយការណ៍


១. អំពីគណៈកម្មការទន្លេមេគង្គ ................................................................ ៣

២. អំពីអាងទន្លេមេគង្គ និងគម្រោងវារីអគ្គិសនី ........................... ៥

៣. ព័ត៌មានអំពីគម្រោង និងឯកសារគម្រោង ដនសាហុង ..................... ៩

៤. កិច្ចដំណើរការ នៃការពិគ្រោះយោបល់ជាមុន ..................................... ២២

៥. ការវាយតម្លៃដោយក្រុមការងារ គណៈកម្មការទន្លេមេគង្គ ............... ២៧

៦. លទ្ធផល នៃការពិគ្រោះយោបល់នៅតំបន់មេគង្គ បឹងទន្លេសាប
និងនៅថ្នាក់ជាតិ ............................. ៣៩

៧. ការវាយតម្លៃជំហរភាគីឡាវ វៀតណាម ថៃ ដៃគូអភិវឌ្ឍន៍
និងសង្គមស៊ីវិល ................................ ៤៦

៨. ការវាយតម្លៃឯកសារគម្រោង ដោយក្រសួងជំនាញកម្ពុជា .............. ៥២


**ក្រុមការងារថ្នាក់ជាតិ សម្រាប់ការពិគ្រោះយោបល់ជាមុន**
**លើសំណើគម្រោងទំនប់វារីអគ្គិសនី ដន សាហុង**

ដែលបានចាត់តាំងដោយក្រសួងពាក់ពន្ធ័ មានសមាសភាពដូចខាងក្រោម៖

1. គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា៖ ឯ.ឧ គល់ វឌ្ឍនា អគ្គលេខាធិការរង ជាប្រធានក្រុមការងារ។
2. ក្រសួងធនធានទឹក និងឧតុនិយម៖ លោក ម៉ៅ ហាក់ អគ្គនាយករង កិច្ចការបច្ចេកទេសនិងជាប្រធាន នាយកដ្ឋានជលសាស្រ្ត និងការងារទន្លេ ជាសមាជិកក្រុមការងារ។
3. ក្រសួងបរិស្ថាន៖ លោក ជ្រិន សុខា អគ្គនាយករង ជាសមាជិកក្រុមការងារ។
4. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៖ លោក ឆេង ផែន នាយកស្តីទីវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍជលផលទឹកសាប រដ្ឋបាលជលផល ជាសមាជិកក្រុមការងារ។
5. ក្រសួងរ៉ែ និងថាមពល៖ លោក ជា ណារិន ប្រធាននាយកដ្ឋានវារីអគ្គិសនី ជាសមាជិកក្រុមការងារ។

នៅគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានក្រុមការងារផ្ទៃក្នុងមួយដោយឡែក សម្រាប់ការតាមដាន ប្រមូលពត៌មាន វិភាគវាយតម្លៃ និងរាយការណ៍ អំពីសភាពការណ៍អភិវឌ្ឍន៍ទំនប់វារីអគ្គិសនី ទាំងនៅលើទន្លេមេ និងដៃទន្លេ នៃទន្លេមេគង្គ ផងដែរ។

## ១. អំពីគណៈកម្មការទន្លេមេគង្គ

គណៈកម្មការទន្លេមេគង្គ (Mekong River Commission) បានបង្កើតឡើងដោយកិច្ចព្រមព្រៀងមេគង្គ ស្តីពីកិច្ចសហប្រតិបត្តិការ ដើម្បីការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព នៃអាងទន្លេមេគង្គ ចុះហត្ថលេខា នៅថ្ងៃទី5 ខែមេសា ឆ្នាំ 1995 ដោយប្រទេសជាសមាជិក កម្ពុជា ឡាវ ថៃ និងវៀតណាម។ ដោយឡែក ប្រទេសចិន និងប្រទេសមីយ៉ាន់ម៉ា គឺជាដៃគូសន្ទនា របស់គណៈកម្មការទន្លេមេគង្គ (Dialogue Partners) ហើយប្រទេសផ្តល់ជំនួយនានា គឺជាដៃគូអភិវឌ្ឍរបស់គណៈកម្មការទន្លេមេគង្គ (Development Partners)។




**កិច្ចព្រមព្រៀងមេគង្គ ឆ្នាំ1995**

<u>**គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា**</u> (Cambodia National Mekong Committee) ជាសេនាធិការជំនួយការឲ្យរាជរដ្ឋាភិបាល សម្រាប់សម្របសម្រួលក្នុងការគ្រប់គ្រង ការសិក្សា ការការពារ ការអភិរក្ស និងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ពន្ធ័ដ៏ទៃទៀត ក្នុងអាងទន្លេមេគង្គប្រកបដោយនិរន្តរភាព ក្នុងក្របខណ្ឌទូទាំងប្រទេស និងសម្រាប់ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយនឹងគណៈកម្មាធិការជាតិទន្លេមេគង្គ នៃប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ និងប្រទេសជាដៃគូសន្ទនា និងជាដៃគូអភិវឌ្ឍនៅក្នុងអាងទន្លេមេគង្គទាំងមូល ស្របតាមកិច្ចព្រមព្រៀងមេគង្គ ឆ្នាំ1995 (Mekong Agreement)។

**<u>កិច្ចព្រមព្រៀងមេគង្គ ឆ្នាំ1995៖</u>** នៅក្នុងជំពូកIII មាត្រា5 បានចែងអំពីការប្រើប្រាស់ទឹកដោយសមហេតុផល និងដោយសមធម៌ (Article 5: Reasonable and Equitable Utilization)។ នៅក្នុងកថាខ័ណ្ឌ B.2.a) បានចែងថា "*នៅលើទន្លេមេនៃទន្លេមេគង្គ នារដូវប្រាំង ការប្រើប្រាស់ទឹក ត្រូវតែធ្វើ<u>ការពិគ្រោះយោបល់ជាមុន</u> ក្នុងគោលបំណងស្វែងរកការព្រមព្រៀងគ្នាមួយ ដោយគណៈកម្មាធិការរួម* " (On the mainstream of the Mekong River, during the dry season: Intra-basin use shall be subject to a <u>Prior Consultation</u> which aims at arriving at an agreement by the Joint Committee" ) ។




**រចនាសម្ព័ន្ធ គណៈកម្មការទន្លេមេគង្គ៖ ក្រុមប្រឹក្សា, គណៈកម្មាធិការរួម និងលេខាធិការដ្ឋាន**

កិច្ចព្រមព្រៀងមេគង្គ ឆ្នាំ1995 បានចែងអំពីកិច្ចសហប្រតិបត្តិការ ដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃអាងទន្លេមេគង្គ។ មាត្រា2 នៃកិច្ចព្រមព្រៀងនេះ បានចែងអំពីការលើកសំណើគម្រោង និងកម្មវិធីនានា (Projects, Programmes and Planning) ការរៀបចំផែនការ ដើម្បីជម្រុញ គាំទ្រ សហការ និង សម្របសម្រួលក្នុងការអភិវឌ្ឍនូវសក្តានុពលឲ្យបានពេញលេញ ដើម្បីជាផលប្រយោជន៍ជានិរន្តដល់ប្រទេសជាសមាជិក និងការទប់ស្កាត់នូវការប្រើប្រាស់ទឹកខ្ជះខ្ជាយនៅក្នុងអាងទន្លេមេគង្គ។ មាត្រា3 បានចែងអំពីការការពារបរិស្ថានធនធានធម្មជាតិ វារីសត្វ និងការរក្សាតុល្យភាពនៃប្រពន្ធ័អេកូឡូស៊ីទន្លេ (Protection of the Environment and Ecological Balance) ឲ្យរួចផុតពីការបំពុល និងផលប៉ះពាល់ ធ្ងន់ធ្ងរនានា។ មាត្រា5 បានចែងអំពីគោលការណ៍នៃការប្រើប្រាស់ទឹក ប្រកបដោយសមភាព និងសមធម៌ (Reasonable and Equitable Utilization) ទាំងនៅតាមដៃទន្លេ និងទន្លេមេនៃទន្លេមេគង្គ ទាំងនៅក្នុងរដូវប្រាំង និងនៅក្នុងរដូវវស្សា។

មាត្រា20 បានចែងអំពីគោលការណ៍នៃការធ្វើសេចក្ដីសម្រេចរបស់ក្រុម ប្រឹក្សានៃគណៈកម្មការទន្លេមេគង្គ (Decisions of Council) គឺដោយគោលការណ៍ជាឯកច្ឆ័ន្ទ (Unanimous Vote) លើកលែងតែក្នុងករណីទាំងឡាយណា ដែលមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការ ហើយមាត្រា34 បានចែងអំពីដំណោះស្រាយដោយគណៈកម្មការទន្លេមេគង្គ (Resolution by Mekong River Commission) និងមាត្រា35 បានចែងអំពីដំណោះស្រាយដោយរដ្ឋាភិបាលនៃប្រទេសជាសមាជិក (Resolution by Governments)។

នៅក្នុងជំពូកII នៃកិច្ចព្រមព្រៀងមេគង្គ ឆ្នាំ1995 ស្ដីពីនិយមន័យក៏បានចែងដែរថា *ការពិគ្រោះយោបល់ជាមុន* គឺជាការជូនដំណឹងយ៉ាងទាន់ពេលវេលា រួមទាំងទិន្នន័យនិងពត៌មានបន្ថែម ជូនដល់គណៈកម្មាធិការរួម ដែលនឹងអនុញ្ញាតឲ្យប្រទេសជាសមាជិកដែលស្ថិតនៅតាមដងទន្លេ ធ្វើការពិភាក្សា និងវាយតម្លៃផលប៉ះពាល់នៃសំណើប្រើប្រាស់ទឹកណាមួយ មកលើការប្រើប្រាស់ទឹក របស់ប្រទេសជាសមាជិកដ៏ទៃទៀត និងផលប៉ះពាល់ដ៏ទៃទៀត ដែលពត៌មានទាំងនេះ នឹងជាមូលដ្ឋានសម្រាប់ការឈានដល់កិច្ចព្រមព្រៀងគ្នាមួយ។ ការពិគ្រោះយោបល់ជាមុន មិនមែនជាសិទ្ធវ៉េតូលើការប្រើប្រាស់ទឹក ហើយក៏មិនមែនជាសិទ្ធជាឯកតោភាគី ក្នុងការប្រើប្រាស់ទឹក ដោយប្រទេសណាមួយតាមដងទន្លេ ដោយមិនបានគិតគូរដល់សិទ្ធនៃប្រទេសផ្សេងទៀតតាមដងទន្លេ (Prior consultation: is timely notification plus additional data and information to the Joint Committee… that would allow the other member riparians to discuss and evaluate the impact of the proposed use upon their uses of water and any other affects, which is the basis for arriving at an agreement. Prior consultation is neither a right to veto the use nor unilateral right to use water by any riparian without taking into account other riparians′ rights).

ទាក់ទិននឹងបញ្ហានេះ នៅក្នុងនិតិវិធីប្រើប្រាស់ទឹករបស់គណៈកម្មការទន្លេមេគង្គ ស្ដីពីការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (Procedures for Notification, Prior Consultation and Agreement-PNPCA) កថាខណ្ឌ5.5 បានចែងលំអិតអំពីរយៈពេលនៃការពិគ្រោះយោបល់ជាមុន ដែលមានរយៈពេល6ខែដំបូង ហើយអាចបន្តបន្ថែមរយៈពេលនេះទៀតបាន ក្នុងករណីចាំបាច់ និងដោយមានការឯកភាពពីគណៈកម្មាធិការរួម។

ដោយឡែក អំពីយន្តការដោះស្រាយបញ្ហា និងទំនាស់៖ កិច្ចព្រមព្រៀងមេគង្គ ឆ្នាំ1995 គឺជាឯកសារមេនៅក្នុងកិច្ចសហប្រតិបត្តិការណ៍តំបន់ ព្រមទាំងនិតិវិធីប្រើប្រាស់ទឹកចំនួន5 របស់គណៈកម្មការទន្លេមេគង្គ។ គណៈកម្មាធិការរួម ត្រូវខិតខំគ្រប់បែបយ៉ាង ដើម្បីដោះស្រាយបញ្ហា និងទំនាស់ផ្សេងៗ និងនៅពេលចាំបាច់ត្រូវបញ្ជូនករណីនេះ ទៅក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ (មាត្រា24 ច)។ ក្រុមប្រឹក្សាទទួលពិនិត្យ និងដោះស្រាយបញ្ហានានា ទំនាស់ និងជម្លោះទាំងឡាយដែលបញ្ជូនមកក្រុមប្រឹក្សា (មាត្រាទី18 គ)។ ក្នុងករណីដែលគណៈកម្មការទន្លេមេគង្គ មិនអាចមានលទ្ធភាពដោះស្រាយទំនាស់ ឬជម្លោះឲ្យបានទាន់ពេលវេលា ត្រូវបញ្ជូនបញ្ហានោះទៅរដ្ឋាភិបាលដើម្បីដោះស្រាយ តាមរយៈការចរចារការទូត ឲ្យបានទាន់ពេលវេលា (មាត្រា34)។

## ២. អំពីអាងទន្លេមេគង្គ និងគម្រោងវារីអគ្គិសនី

## ២.១ អាងទន្លេមេគង្គ

ទន្លេមេគង្គ មានប្រភពទឹកហូរមកពីតំបន់ទីបេនៃប្រទេសចិន (ខេត្តយូណាន) មីយ៉ាន់ម៉ា ថៃ ឡាវ កម្ពុជា និងវៀតណាម រួចហូរចាក់ចូលទៅក្នុងសមុទ្ទចិនខាងត្បូង។ ទន្លេនេះមានផ្ទៃអាងទំហំ 795,000 គម$^2$ (លំដាប់ទី21 ក្នុងចំណោមទន្លេធំៗនៅលើសកលលោក) មានប្រវែង4,800គម (លំដាប់ទី12) និងមានជារទឹកមធ្យមចំនួន 15,000ម$^3$/វិនាទី (លំដាប់ទី8)។

រូបភាពខាងក្រោម បង្ហាញនូវទំហំ និងគិតជាភាគរយនៃប្រទេសនីមួយៗ ដែលមានចំណែកនៅក្នុងអាងទន្លេមេគង្គ ជាទំហំផ្ទៃដី និងជាបរិមាណជារទឹក (ទឹកភ្លៀង) ហូរចាក់ចូលក្នុងទន្លេមេគង្គ។




- *Catchments Area by Country:*
  - *China: 165,000 Km$^2$ (21%)*
  - *Myanmar: 24,000 Km$^2$ (3%)*
  - *Lao PDR : 202,000 Km$^2$ (25%)*
  - *Thailand: 184,000 Km$^2$ (23%)*
  - *Cambodia: 155,000 Km$^2$ (20%)*
  - *Vietnam: 65,000 Km$^2$ (8%)*
- *LMB Catchments Area :*
  *606,000 Km$^2$ (76%)*
- *Flow : 475,000 M.m$^3$/year*
- *Flow Contribution:*
  - *China : 16%*
  - *Myanmar: 2%*
  - *Lao PDR : 35%*
  - *Thailand : 18%*
  - *Cambodia : 18%*
  - *Vietnam : 11%*

**ផែនទី អាងទន្លេមេគង្គ**

## ២.២ គម្រោងវារីអគ្គិសនី នៅលើទន្លេមេ នៃទន្លេមេគង្គ

នៅឆ្នាំ2014 មានគម្រោងវារីអគ្គិសនីចំនួន19គម្រោង នៅតាមដងទន្លេមេ នៃទន្លេមេគង្គ៖

- នៅកំណាត់ទន្លេ ឡានសាង/មេគង្គ (ក្នុងប្រទេសចិន) មានគម្រោងទំនប់វារីអគ្គិសនី ចំនួន8គម្រោង មានសក្តានុពលសរុបចំនួន 15,000មេហ្គាវ៉ាត់ ដែលក្នុងនោះ៖
  - គម្រោងចំនួន6 បានសាងសង់រួចរាល់ និងកំពុងប្រតិបត្តិការ។
  - គម្រោងចំនួន1 កំពុងស្ថិតក្នុងដំណាក់កាល រៀបចំផែនការសាងសង់។
  - គម្រោងទី8 (ដែលនៅខ្សែទឹកក្រោមគេ កៀកនឹងព្រំដែនឡាវ) ត្រូវបានលុបចោល ឬពន្យាពេល។




- នៅកំណាត់ទន្លេមេគង្គ ព្រំប្រទល់ឡាវនិងមីយ៉ាន់ម៉ា (ប្រវែង 250គម) ពុំមានគម្រោងវារីអគ្គិសនីទេ។

- នៅកំណាត់ទន្លេមេគង្គ នៃប្រទេសថៃ ឡាវ កម្ពុជា និងវៀតណាម គិតចាប់ពីតំបន់ត្រីកោណមាសមកក្រោម មានគម្រោងវារីអគ្គិសនីចំនួន11គម្រោង មានសក្តានុពលសរុបចំនួន 15,000មេហ្គាវ៉ាត់ ដែលក្នុងនោះ រាប់ពីលើចុះក្រោម មាន៖
- គម្រោងចំនួន6 ស្ថិតនៅខ្សែទឹកខាងលើទីក្រុងវៀងចន្ទ៍៖ ប៉ាក់បែង>លួងប្រាបាង>**សាយាបុរី**>ប៉ាក់ឡាយ>សាណាខាំ>ប៉ាក់ជុំ>។ គម្រោងសាយាបូរី ត្រូវបានកំពុងសាង សង់ចាប់តាំងពីដើមឆ្នាំ 2012 ហើយគម្រោងប៉ាក់ជុំ ជាគម្រោងរួមគ្នារវាងឡាវថៃ ដោយសារកំណាត់ទន្លេត្រង់ចំណុចនេះ ជាព្រំដែនរួមគ្នា។
- គម្រោងចំនួន3 ស្ថិតនៅខ្សែទឹកខាងក្រោមទីក្រុងវៀងចន្ទ៍៖ >បានគុំ>ឡាត់សួ>**ដនសាហុង**>។ គម្រោងបានគុំ ជាគម្រោងរួមគ្នារវាងឡាវថៃ ដោយសារកំណាត់ទន្លេត្រង់ចំណុចនេះ ជាព្រំដែនរួមគ្នា។ គម្រោងទាំងបីនេះ ស្ថិតនៅខាងលើព្រំដែនឡាវកម្ពុជា ហើយគម្រោងដនសាហុង ភាគីឡាវកំពុងរៀបចំការដ្ឋានសាងសង់។
- គម្រោងចំនួន2 ស្ថិតនៅក្នុងទឹកដីកម្ពុជា៖ >ស្ទឹងត្រែង>សំបូរ (ក្នុងខេត្តក្រចេះ)។ គម្រោងទាំងពីរនេះ ស្ថិតក្នុងដំណាក់កាលធ្វើផែនការនៅឡើយ។




ទីតាំងគម្រោងវារីអគ្គិសនី នៅលើទន្លេមេគង្គមេ

Figure S1: Proposed Mekong mainstream hydropower projects in the LMB and Yunnan Province, China




## ៣. ព័ត៌មានអំពីគម្រោង និងឯកសារគម្រោង ដនសាហុង

### ៣.១ ទីតាំងគម្រោង

គម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** គឺជាគម្រោងមួយក្នុងចំណោមបណ្តាគម្រោងទំនប់វារីអគ្គិសនី ដែលគ្រោងធ្វើការសាងសង់នៅលើទន្លេមេ នៃទន្លេមេគង្គ មានទីតាំងស្ថិតនៅក្នុងខេត្ត**ចំប៉ាសាក់** ភាគខាងត្បូងនៃប្រទេសឡាវ មានចម្ងាយប្រមាណ 1,500m នៅខ្សែទឹកខាងលើ នៃព្រំប្រទល់កម្ពុជា-ឡាវ ក្នុងតំបន់**ស៊ីផាន់ដន** ដែលក្នុងនោះមានប្រេកផ្លូវទឹក (Channel) សំខាន់ៗចំនួន7 ហូរកាត់ទទឹងល្បាក់ទឹកធ្លាក់។ គម្រោងនេះ ស្ថិតនៅលើប្រេក**សាហុង** (Hou Sahong) ដែលជាប្រេកសំខាន់ជាងគេបំផុត ក្នុងចំណោមប្រេកសំខាន់ៗទាំង7 សម្រាប់ការធ្វើបន្លាស់ទីឆ្លងកាត់ទៅមករបស់ត្រីទាំងនៅក្នុងរដូវប្រាំង និងរដូវវស្សា សម្រាប់ការចិញ្ចឹមជីវិត និងពងកូន។

## ៣.២ លក្ខណៈបច្ចេកទេសនៃគម្រោង

យោងតាមឯកសារគម្រោងរបស់ឡាវ គម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** មាន៖




ទីតាំងអាង និងទំនប់វារីអគ្គិសនី ដនសាហុង



**<u>អាងទន្លេ និងលក្ខណៈសំខាន់ៗនៃទន្លេ</u>**

- ផ្ទៃរងទឹកភ្លៀង (Catchment Area)៖ 553,000 $Km^2$
- លំហូរជារទឹកមធ្យម (Mean Flow)៖ 9,578 $m^3/s$
- លំហូរមេដ្យាន (Median Flow "Expected 50% of time")៖ 4,734 $m^3/s$
- លំហូរជារទឹកមធ្យមប្រចាំថ្ងៃ អតិបរមា (Maximum average daily flow)៖ 47,600 $m^3/s$
- លំហូរជារទឹកមធ្យមប្រចាំថ្ងៃ អប្បរមា (Minimum average daily flow)៖ 1,236 $m^3/s$

**<u>អាងស្តុកទឹក</u>**៖ ផ្ទៃអាងផ្ទុកទឹកអតិបរមានៅក្នុងទំនប់ មានទំហំ 220 ha

**<u>កម្លាំងផលិត</u>**

- សមត្ថភាពផលិត៖ 260MW
- សមត្ថភាពផលិតជាមធ្យមក្នុងរដូវវស្សា (មិថុនា-វិច្ឆិកា)៖ 248 MW
- សមត្ថភាពផលិតជាមធ្យមក្នុងរដូវប្រាំង (ធ្នូ-ឧសភា)៖ 222 MW

**<u>ថាមពល (នៅចំណុចចែកចាយ)</u>**

- ថាមពលមធ្យមប្រចាំឆ្នាំ៖ 2,044 GWh
- ថាមពលផលិតប្រចាំឆ្នាំ សម្រាប់ឆ្នាំដែលមានទឹកគ្រប់គ្រាន់៖ 2,086 GWh
- ថាមពលផលិតប្រចាំឆ្នាំ សម្រាប់ឆ្នាំដែលមានភាពរាំងស្ងួត៖ 1,953 GWh

**<u>រចនាសម្ព័ន្ធនៃគម្រោង</u>**

- ប្រភេទទំនប់៖ ទំនប់បេតុង កិនបង្ហាប់ (RCC "Roller Compact Concrete")
- Crest Elevation: 76.90 masl (ម៉ែត្រធៀបនឹងនីវ៉ូសមុទ្រ)
- Crest Length: 7.0 Km
- កម្ពស់អតិបរមានៃទំនប់៖ 25 m

**<u>ទំនប់បង្ហៀរសម្រាប់សង្គ្រោះបន្ទាន់</u>**

- ប្រភេទ៖ Free/ Ungate
- Sill Elevation: 75.45 masl (ម៉ែត្រធៀបនឹងនីវ៉ូសមុទ្រ)
- Crest Length: 700 m

**<u>ស្ថានីយ៍ថាមពល</u>**

- ទំហំស្ថានីយ៍ថាមពល៖ 88 m x 79 m
- សមត្ថភាពផលិតសម្រាប់ទួរប៊ីននីមួយៗ៖ 65 MW
- ចំនួនទួរប៊ីនសរុប៖ 4
- ប្រភេទទួរប៊ីន៖ Bulb

- ធារទឹក (Design flow) ដែលបានគ្រោងកំណត់ សម្រាប់បង្ហូរចេញពីស្ថានីយ៍ថាមពល៖ 1,600 $m^3/s$

គម្រោងនេះ នឹងគាស់កកាយបាតទន្លេយកថ្មចេញ ដែលមានបណ្តាយប្រវែង 1.8Km ជម្រៅពី 5-6m និងអាចម៍ថ្ម មានបរិមាណ 2.4 mil.$m^3$ នៅត្រង់មាត់ប្រកផ្លូវទឹកចូល នៃប្រកសាហុង ដើម្បីបង្វែរទាញទឹកពីប្រកផ្សេងៗទៀតឲ្យចូលក្នុងប្រកសាហុង ឲ្យបានច្រើន សម្រាប់ការផលិតថាមពល ជាពិសេសនៅរដូវប្រាំង និងនៅមាត់ប្រកចេញ ក្រោយតួទំនប់ ឲ្យជ្រៅដើម្បីឲ្យទឹកហូរចេញបានខ្លាំង។



# ស្ថានីយវារីអគ្គិសនី ដនសាហុង







**Figure 4-2 Schematic Diagram of flows affected by the DSHPP**




### ៣.៣ ឯកសារគម្រោង

ឯកសារសិក្សាគម្រោង ដនសាហុង ដែលភាគីឡាវ បានផ្ញើមកប្រទេសកម្ពុជា ថៃ និងវៀតណាម ដែលជាសមាជិកគណៈកម្មការទន្លេមេគង្គ កាលពីថ្ងៃទី02 ខែតុលា ឆ្នាំ2013 ដោយប្រើប្រាស់និតិវិធី "**ការជូនដំណឹង**" ( Notification ) គឺ៖

**A. Social and Environmental Impact Assessment Document:**
1. Cummulative Impact Assessment
2. Environmental Impact Assessment
   - Fisheries Study 2010 (Annex to EIA)
   - Fisheries Study 2013 (Annex to EIA)
3. Environmental Management and Monitoring Plan
4. Social Impact Assessment
5. Social Management and Monitoring Plan
6. Resettlement Action Plan

**B. Engineering Documents:**
1. Engineering Status Report (2011)
2. Engineering Status Report Drawing (2011)

ភាគីឡាវបានជូនដំណឹងបន្ថែម ដោយដាក់នៅលើគេហ៍ទំព័រ៖ http://dshpp.com/reports/កាលពីថ្ងៃទី25 ខែកក្កដា ឆ្នាំ2014 បន្ទាប់ពីបានយល់ព្រម ដាក់គម្រោងនេះ ក្រោមដំណើរការនៃការពិគ្រោះយោបល់ជាមុន ( Prior Consultation ) គឺ៖

Technical Aspects
- DSHPP Engineering Status-Report-2011
- DSHPP Engineering Status-Report-Drawing-A3-2011
- DSHPP-Hydrology-Hydraulics-Sediment-Status-Report-Rev-B-Oct-2011
- DSHPP-Transboundary-Hydraulic-Effects-Rev-B

Environment and Social Documents

**1.1. Environment Study**

1.1.1. EIA Main Document

1.1.1.1. EIA

- DSHPP-EIA-FINAL

1.1.1.2. Annexes C&D

- Fisheries Study-2010_DSHPP-EIA-FINAL-Annex C-2
- Fisheries Study-2013_DSHPP-EIA-FINAL-Annex D

1.1.2. Environmental Management and Monitoring Plan (EMMP)

**1.2. Social Study**

1.2.1. SIA Main Documents

- DSHPP-SIA-FINAL-2013

1.2.2. Social Management and Monitoring Plan (SMMP)

- DSHPP-SMMP-FINAL-2013

1.2.3. Resettlement Action Plan (RAP)

- DSHPP-RAP-FINAL-2013

**1.3. Cumulative Impact Assessment**

- DSHPP-CIA-FINAL-2013

DSHPP Presentations

- Hou Sahong-Inlet-Fish-Passage-Restoration-Mach-2013
- Khone-Larn-Fish-Passage
- MRC-Engineering-Presentation-07.03.2014
- Pakse-Engineering-Presentation-11.03.2014
- Site-Visit-Presentation-11.03.2014

## ៣.៤ សាវតា និងវឌ្ឍនភាព នៃគម្រោង

តាមរយៈលិខិតលេខ L OSV 590/1 ចុះថ្ងៃទី02 ខែតុលា ឆ្នាំ2013 របស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ(Mekong River Commission Secretariat-MRCS) ប្រទេសឡាវ បានបញ្ជូនឯកសារសំណើគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** ដល់ប្រទេសកម្ពុជា វៀតណាម និងថៃ ដោយប្រើប្រាស់និតិវិធីនៃ "**ការជូនដំណឹង**" (Notification) ដែលផ្អែកទៅនឹងកិច្ចព្រមព្រៀងមេគង្គឆ្នាំ1995 (Mekong Agreement) និងនីតិវិធីស្តីពីការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (Procedures for Notification, Prior Consultation and Agreement-PNPCA) របស់គណៈកម្មការទន្លេមេគង្គ។ មាត្រា5 នៃកិច្ចព្រមព្រៀងមេគង្គឆ្នាំ1995 បានចែងថា "**រាល់សំណើគម្រោងប្រើប្រាស់ទឹកក្នុងទន្លេមេ នៃទន្លេមេគង្គ ក្នុងរដូវប្រាំង ត្រូវឆ្លងកាត់និតិវិធីនៃការពិគ្រោះយោបល់ជាមុន**" ("Any proposed project of intra-basin use on the mainstream of the Mekong River during the dry season shall be subject to Prior Consulta-tion") ដែលជាមូលដ្ឋានសម្រាប់ឈានដល់ការឯកភាពគ្នាមួយ ក្នុងចំណោមគណៈកម្មាធិការរួម នៃគណៈកម្មការទន្លេមេគង្គ (MRC-Joint Committee-JC) ថាតើត្រូវសម្រេចយ៉ាងណាលើសំណើគម្រោងនេះ។

ភាពខុសគ្នារវាង "**ការជូនដំណឹង**" និង "**ការពិគ្រោះយោបល់ជាមុន**" នៅក្នុង PNPCA គឺ៖ "**ការជូនដំណឹង**" គឺគ្រាន់តែជាការប្រាប់ឲ្យដឹង និងការផ្តល់នូវឯកសារសំណើគម្រោងដល់បណ្តាប្រទេសជាសមាជិក ដោយមិនត្រូវការទទួលយកមតិយោបល់របស់ប្រទេសជាសមាជិកឡើយ។ រីឯ "**ការពិគ្រោះយោបល់ជាមុន**" គឺជាដំណើរការនៃការពិគ្រោះយោបល់ លើសំណើគម្រោងរហូតឈានដល់ការឯកភាពគ្នាមួយក្នុងចំណោម MRC-JC ថាតើគួរ

សម្រេចយ៉ាងណាលើសំណើគម្រោងនេះ។ នៅក្នុងកិច្ចព្រមព្រៀងមេគង្គ បានបញ្ជាក់បន្ថែមទៀតថា "**ការពិគ្រោះយោបល់ជាមុន**" មិនមែនជាសិទ្ធធ្វើវ៉េតូ (Veto) លើការប្រើប្រាស់ទឹក ហើយក៏មិនមែនជាសិទ្ធជាឯកតោភាគីក្នុងការប្រើប្រាស់ទឹកដោយមិនគិតគូរពិចារណាអំពីសិទ្ធប្រើប្រាស់ទឹករបស់ប្រទេសជាសមាជិកផ្សេងៗទៀតដែរ។ "**ការពិគ្រោះយោបល់ជាមុន**" មានរយៈពេល 6ខែរាប់ចាប់ពីថ្ងៃដែលបានទទួលឯកសារសំណើគម្រោងជាផ្លូវការ ហើយប្រសិនណាបើចាំបាច់ គឺអាចពន្យាពេល តាមការសម្រេចរបស់ MRC-JC។

បន្ទាប់ពីមានសំពាធតានតឹងកាន់តែខ្លាំងឡើង និងពីគ្រប់ទិសទីទាំងក្នុងមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ក្នុងព្រមទាំងពីប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គផងដែរនោះ អំឡុងរយៈពេលជាង8 ខែមក ថាភាគីឡាវមិនបានគោរពកិច្ចព្រមព្រៀងមេគង្គ ភាគីឡាវនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ លើកទី20 នាចុងខែមិថុនា ឆ្នាំ2014 នៅទីក្រុងបាងកក ប្រទេសថៃ បានប្តូរជំហររបស់ខ្លួន មកយល់ព្រមដាក់ឯកសារគម្រោងទំនប់វារីអគ្គិសនី ដនសាហុង ក្រោមនិតិវិធីនៃការពិគ្រោះយោបល់ជាមុន។

នៅក្នុងប្រទេសឡាវរហូតមកដល់បច្ចុប្បន្ន សំណើគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** បានត្រូវបំពេញកិច្ចព្រមព្រៀងដូចតទៅ៖

- **ថ្ងៃទី23 ខែមិនា ឆ្នាំ2006៖** ក្រុមហ៊ុន Mega First Corporation Berhad (MFCB) បានចុះ MOU ជាមួយរដ្ឋាភិបាលឡាវ ដើម្បីធ្វើការសិក្សាសមិទ្ធិលទ្ធភាពគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង**។
- **ខែធ្នូ ឆ្នាំ2007៖** ការសិក្សាសមិទ្ធិលទ្ធភាព (ទី1) និងការវាយតម្លៃផលប៉ះពាល់បរិស្ថាន បានបញ្ចប់។
- **ថ្ងៃទី13 ខែកុម្ភៈ ឆ្នាំ2008៖** ក្រុមហ៊ុន MFCB បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងអភិវឌ្ឍន៍គម្រោង (Project Development Agreement) គម្រោងជាមួយរដ្ឋាភិបាលឡាវ។
- **ឆ្នាំ2009៖** ការសិក្សាអំពីជលផល ការធ្វើបន្លាស់ទីរបស់ត្រី និងកម្មវិធីត្រួតពិនិត្យ បានចាប់ផ្តើម។
- **ឆ្នាំ2010៖** ការសិក្សាពិស្តារអំពីបរិស្ថាន និងសង្គម បានត្រូវបង្ហាញជូនរដ្ឋាភិបាល និងប្រជាជនមូលដ្ឋាន។
- **ឆ្នាំ2012៖** ក្រសួងធនធានធម្មជាតិ និងបរិស្ថានឡាវ បានពិនិត្យឡើងវិញ និងបានអនុម័តលើការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម។
- **ឆ្នាំ2013៖** ការសិក្សាអំពីបរិស្ថាន និងសង្គម បានត្រូវធ្វើបច្ចុប្បន្នភាព និងដាក់ជូនពិនិត្យសាជាថ្មី។
- **បច្ចុប្បន្ន ខែវិច្ឆិកា ឆ្នាំ2014៖**
  កិច្ចព្រមព្រៀងសម្បទាន (Concession Agreement) និងកិច្ចព្រមព្រៀងជាវថាមពល (Power Purchase Agreement) បានទទួលការឯកភាពពីរដ្ឋាភិបាលឡាវ ហើយរដ្ឋាភិបាលឡាវ កំពុងដាក់ឯកសារនេះ ឆ្លងសភាជាតិឡាវ ដើម្បីពិនិត្យ និងអនុមត័។ តាមការសាកសួរបន្ថែមទៅភាគីឡាវ ថានៅពុំទាន់មានការពិភាក្សាលើឯកសារខាងលើនេះ នៅក្នុងរបៀបវារៈប្រជុំសភាជាតិឡាវ នៅឡើយទេ។

វិនិយោគិន នៃសំណើគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** គឺក្រុមហ៊ុន MFCB ដែលជាក្រុមហ៊ុនមកពីប្រទេសម៉ាឡេស៊ី។ ក្នុងការបំពេញកិច្ចសន្យារបស់ខ្លួន MFCB បានចុះកិច្ចសន្យាបន្តទៅបណ្តាក្រុមហ៊ុន៖

- AECOM ជាក្រុមហ៊ុនមកពីប្រទេសនូវែលសេឡង់ ទទួលខុសត្រូវលើកិច្ចការវិស្វកម្ម (Engineering Feasibility Studies)។

- ក្រុមហ៊ុនប្រឹក្សាបច្ចេកទេសជាតិ (National Consultant Company) ទទួលខុសត្រូវលើការធ្វើបច្ចុប្បន្នភាព ការវាយតម្លៃផលប៉ះពាល់បរិស្ថាន (EIA) (រួមមាន EIA, CIA, EMMP, SIA, និងSMMP) ដែលបានបញ្ចប់ដោយក្រុមហ៊ុន PEC Konsult Sdn Bhd និងក្រុមហ៊ុន Australian Power and Water Ltd.។
- ក្រុមហ៊ុន SMEC ទទួលខុសត្រូវក្នុងការជួយដល់កិច្ចការវិស្វកម្មមួយចំនួន និងផ្តល់ប្រឹក្សាបច្ចេកទេសក្នុងការជួយជម្រុញយ៉ាងណាឲ្យទទួលបានការអនុម័តផ្សេងៗ និងបញ្ចប់ការរៀបចំមួយចំនួន សម្រាប់ការទទួលបាន នូវការដេញថ្លៃលើកិច្ចការវិស្វកម្ម ការផ្គត់ផ្គង់ និងការសាងសង់។ សេវារបស់ក្រុមហ៊ុន SMEC រួមទាំងជាតុចូលខាងផ្នែកវិស្វកម្ម ដើម្បីជួយឲ្យបានការអនុម័តខាងផ្នែកបរិស្ថាន និងការបញ្ចប់កិច្ចព្រមព្រៀងជាវថាមពល (Power Purchase Agreement) និងកិច្ចព្រមព្រៀងសម្បទាន (Concession Agreement)។

## ការរៀបចំ ជាឯកតោភាគី ដោយភាគីឡាវ៖

ថ្ងៃទី10-12 ខែវិច្ឆិកា ឆ្នាំ2013៖ ភាគីឡាវ បានរៀបចំការធ្វើទស្សនៈកិច្ចលើកទី1 នៅទីតាំងគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** ក្នុងគោលបំណងផ្តល់ឱកាសដល់បណ្តាអ្នកពាក់ព័ន្ធនានា គណៈកម្មាធិការជាតិទន្លេមេគង្គ នៃប្រទេសជាសមាជិក បណ្តាញសារព័ត៌មានជាតិ និងអន្តរជាតិ អង្គការសង្គមស៊ីវិល ដើម្បីស្វែងយល់អំពីស្ថានភាព និងការអភិវឌ្ឍន៍នៃគម្រោង និងដើម្បីទទួលបាននូវអនុសាសន៍ពីអ្នកពាក់ព័ន្ធ។ ក្រុមការងារថ្នាក់ជាតិកម្ពុជា ក៏បានចូលរួមទស្សនៈកិច្ចនេះ និងយល់ឃើញថា គម្រោងនេះស្ថិតនៅក្នុងប្រេក**សាហុង** ដែលជាប្រេកមួយក្នុងចំណោមប្រេកសំខាន់ៗចំនួន7 ក្នុងទន្លេមេ នៃទន្លេមេគង្គ ស្ថិតក្នុងតំបន់ **ស៊ីផាន់ដន។** ប្រេក**សាហុង** គឺជាប្រេកដ៏សំខាន់តែមួយគត់ ដែលអាចឲ្យត្រីធ្វើបន្លាស់ទី ពីខ្សែទឹកខាងក្រោម ទៅខ្សែទឹកខាងលើ និងពីខ្សែទឹកខាងលើ មកខ្សែទឹកខាងក្រោមវិញ ក្នុងរដូវប្រាំង។ ប្រេក **សាដាម** និងប្រេក **សាំងកឿក** មិនអាចជំនួសឲ្យប្រេក**សាហុង** សម្រាប់ការបន្លាស់ទី របស់ត្រី ក្នុងរដូវប្រាំងបានទេ បើទោះបីជាមានផែនការសំអាតសម្រាម កំទេចកំទីថ្ម ចេញពីប្រេកទាំងពីរនេះក៏ដោយ។ ឯប្រេកផ្លូវទឹកផ្សេងទៀត រឹតតែមានទឹករាក់ ដើរឆ្លងកាត់បាននៅរដូវប្រាំង។



រូបខាងលើ៖ ច្រកផ្លូវទឹក សាំងកៀក ខែមីនា ឆ្នាំ2014



រូបខាងលើ៖ ច្រកផ្លូវទឹក សាដាំ នាខែមីនា ឆ្នាំ2014





**រូបខាងលើ៖ ប្រកផ្លូវទឹក សាហុង ចំណុចទីតាំងទំនប់ នាខែមីនា ឆ្នាំ2014**

**ថ្ងៃទី16 ខែមករា ឆ្នាំ2014៖** កិច្ចប្រជុំពិសេស ស្តីពីគម្រោងទំនប់វារីអគ្គិសនី **ដនសាហុង** របស់គណៈកម្មាធិការរួម នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ។ ប្រទេសកម្ពុជា ថៃ និងវៀតណាម បានទទូចម្តងហើយម្តងទៀត ដោយស្នើឲ្យភាគីឡាវ ដាក់ឆ្លងគម្រោងនេះ ទៅតាមនិតិវិធីប្រើប្រាស់ទឹក គឺការពិគ្រោះយោបល់ជាមុន ដោយសារថា ជាប្រភេទគម្រោងប្រើប្រាស់ទឹកទន្លេមេ នៃទន្លេមេគង្គ នៅក្នុងរដូវប្រាំង។ ជាលទ្ធផលគឺពុំមាន ការឯកភាពគ្នាក្នុង

ចំណោមសមាជិកគណៈកម្មាធិការរួមទេ ដោយហេតុថាភាគីឡាវនៅតែប្រកាន់ជំហររបស់ខ្លួនថា ត្រឹមតែ "**ការជូនដំណឹង**" គឺសមស្របសម្រាប់គម្រោងនេះ។

មតិយោបល់របស់កម្ពុជា នៅក្នុងកិច្ចប្រជុំនេះ មានដូចខាងក្រោម៖

**Special Session of the MRCS Joint Committee**
**Comments of Cambodia Delegation**
**on the proposed Don Sahong Hydropower Project**

16 January, 2014, Vientiane Lao PDR

1. Cambodia appreciates the Special Session of the Joint Committee organized upon the requests of the MRC member countries as a platform for discussions, sharing and exchanging views for the issues of mutual concerns regarding the proposed Don Sahong Hydropower Project.

2. Don Sahong Hydropower Project is one of the planned Hydropower Projects on the mainstream of the Mekong River. The nature of this project is a type of *"intra-basin use on the mainstream during the dry season"*. According to the 1995 Mekong Agreement and the Procedures for Notification, Prior Consultation and Agreement, Section 5.1. b. Scope of Prior Consultation, it shall be subject to Prior Consultation, the process which allows the riparian states to discuss and evaluate the impacts of the proposed project and any other affects which is the basis for arriving at an agreement. In the case that MRC Joint Committee decision could not be reached, we would like to propose the Meeting to bring this matter to the MRC Council for their view.

3. Cambodia highly appreciates the Initial Assessment of the Don Sahong Hydropower Project, the MRCS Review Report, conducted by MRC Secretariat. We fully acknowledged the technical and science-based objective assessment and would like to request the Review Report's comments and recommendations be considered and fulfilled by the Lao PDR.

4. In addition to the MRCS initial assessment, our initial comments to the received project documents and experienced from the site visit revealed that the study has not been complete and did not cover the transboundary issues to the downstream in Cambodia, resulting in some concerns such as:

   i Existing literatures show that there are more than 100 fish species migrate through Huo Sahong channel, of which more than 32 species are Cambodia's commercial dominant species. If the new migrating routes are not functional well the dam will impact significantly on fisheries, food and nutrition security of Cambodian peoples.

   ii Hou Sahong is the only channel located in the mainstream of Mekong River, close to the Cambodia-Lao border, that fishes can migrate upstream from Cambodia in dry season to their spawning habitats in Siphandon area and upper parts of the Mekong. Once it is built the dam will totally block the entire migration route. The Mitigation measures proposed in the project EIA to clear the Hou Sangpeuk and Hou Sadam channels for alternative fish migrating routes in dry season seems not to be effective, as the project would dredge the entrance of Hou Sahong Channel to significantly increase water flow to sufficiently run the turbines during dry season, leading to a shortage of water flow into Hou Sangpeuok and Hou Sadam in dry season.

   iii Limited compilation of baseline data and information of physical and biological resources and socio-economic capitals at the proposed project and surrounding transboundary areas, which will be the solid benchmark for future monitoring and evaluation of any changes and negative impacts resulting from the project implementation.

iv The study and analysis were unilaterally conducted by Lao PDR where the project location is very close to Cambodia-Lao border. Its implementation may adversely cause severe impact to immediate downstream areas in Cambodia, i.e. the environmental and socio-economic impacts resulting from the changing in flow, sediment/silt and nutrients, the obstacle to fish migration and reducing its biomass, water quality degradation, loss/destruction of habitats of endangered and rare species, especially the Khone Falls area, deep-pool dolphin habitats, the Cambodian Ramsar site, Tonle Sap Lake, etc.

v It is required to further study and analyze the impacts to income generation, food security, livelihoods for people resulting from transboundary fish migration's impacts during and after dam construction due to changing of water flow regime and block fish passage, of which replacement costs from loss of fisheries and practical countermeasures need to be addressed.

vi It is required that the detailed planning of sediment extraction and excavating/blasting of bed rocks for channel modification purposes, with the countermeasures to minimize water quality degradation and health impacts, and to minimize the loss/destruction of fish habitats especially species in deep-pools.

vii It is required the Cost and Benefit Analysis at upstream and downstream (transboundary context) of the proposed project site, based on the changes of physical and biological resources, and socio-economic capitals.

សរុបជារួម អង្គប្រជុំបានសម្រេចយកបញ្ហានេះទៅពិភាក្សាក្នុងកម្រិតក្រុមប្រឹក្សា នៃគណៈកម្មការទន្លេមេគង្គ (MRC Council) បន្តទៀត។

**ថ្ងៃទី07 ខែមីនា ឆ្នាំ2014៖** ភាគីឡាវ បានរៀបចំកិច្ចប្រជុំបច្ចេកទេស ស្តីពីសំណើគម្រោងទំនប់វារីអគ្គិសនី **ដនសាហុង** នៅទីក្រុងវៀងច័ន្ទ ដើម្បីជូនដំណឹងបន្ថែម ដល់អ្នកពាក់ព័ន្ធ គណៈកម្មាធិការជាតិទន្លេមេគង្គ នៃប្រទេសជាសមាជិក តំណាងស្ថានទូត នៃប្រទេសដៃគូអភិវឌ្ឍន៍ អ្នកពាក់ព័ន្ធក្នុងប្រទេសឡាវ និងតំណាង MRCS អំពីលទ្ធផលនៃការវាយតម្លៃបឋម ដោយ MRCS លើឯកសារគម្រោង ស្តាប់បទបង្ហាញរបស់ម្ចាស់គម្រោង ។ ប្រតិភូឡាវ បានបញ្ជាក់ពីជំហររបស់ខ្លួនក្នុងការបើកចំហរបញ្ហា ដើម្បីឲ្យមានការចូលរួមដ៏ទូលំទូលាយ និងប្រកបដោយតម្លាភាពពីអ្នកពាក់ព័ន្ធទាំងអស់ និងប្តេជ្ញាធ្វើតាមអនុសាសន៍ និងគោរពតាម កិច្ចព្រមព្រៀងមេគង្គ និងគោលការណ៍សុវត្ថិភាពបរិស្ថាន។ ប្រតិភូ ក្រុមការងារថ្នាក់ជាតិកម្ពុជា បានចូលរួម និងបានលើកសំណួរពាក់ព័ន្ធនឹងការវិភាគលើតម្លៃនិងភាពចំណេញនៃគម្រោង ការចូលរួមដោយតម្លាភាពពីសាធារណៈ សុវត្ថិភាពទំនប់កង្វះខាតទិន្នន័យនិងព័ត៌មានវិទ្យាសាស្ត្រ ការវាយតម្លៃផលប៉ះពាល់បរិស្ថានឆ្លងដែន និងបានស្នើសុំឲ្យភាគីឡាវ និងម្ចាស់គម្រោងធ្វើការសិក្សាប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ និងដោយមានការចូលរួមទូលំទូលាយ ដោយតម្លាភាពពី

គ្រប់អ្នកពាក់ព័ន្ធសំខាន់ៗ និងប្រទេសជាសមាជិក។ កម្ពុជាក៏បានបន្ថែមថា គម្រោងនេះត្រូវតែដាក់ឲ្យឆ្លងកាត់ដំណើរការ នៃការពិគ្រោះយោបល់ជាមុនស្របតាមកិច្ចព្រមព្រៀងមេគង្គ។



**ថ្ងៃទី11-12 ខែមិនា ឆ្នាំ2014៖** ភាគីឡាវ បានរៀបចំការធ្វើទស្សនៈកិច្ចទីតាំងគម្រោងលើកទី2 ចូលរួមដោយបណ្តាអ្នកពាក់ព័ន្ធ គណៈកម្មាធិការជាតិទន្លេមេគង្គ នៃប្រទេសជាសមាជិក បណ្តាញសារព័ត៌មានជាតិនិងអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងអង្គទូតនៃបណ្តាប្រទេសដៃគូអភិវឌ្ឍន៍ ដើម្បីស្វែងយល់អំពីស្ថានភាព និងវឌ្ឍនភាពបច្ចុប្បន្នភាព នៃគម្រោងក្នុងរដូវប្រាំង ដើម្បីធ្វើការប្រៀបធៀបនឹងស្ថានភាពនៅរដូវវស្សា ដែលបានចុះពិនិត្យលើកទី1 ជាពិសេសការពិនិត្យស្ថានភាពនៃផ្លូវជម្រើសសម្រាប់ត្រីធ្វើបន្លាស់ទី។ ប្រតិភូក្រុមការងារថ្នាក់ជាតិកម្ពុជាបានសង្កេតឃើញថាពុំមានសំណង់អ្វីត្រូវបានសាងសង់នោះទេតែមានការដុតព្រៃខ្លះៗ នៅក្នុងទីតាំងដែលអនាគតនឹងក្លាយទៅជាអាងស្តុកទឹករបស់ទំនប់ នៅពេលសាងសង់រួច។ ជាទូទៅកំពស់ទឹកខាងលើល្បាក់បានស្រកចុះបន្តិចបន្តួច បើប្រៀបធៀបនឹងកម្រិតកម្ពស់ទឹក ក្នុងរដូវវស្សា ក្នុងកំឡុងពេលទស្សនៈកិច្ចលើកទី1 ដែលតួថ្មល្បាក់ បានដើរតួនាទីជាទំនប់បង្ហៀរ។ មានបរិមាណទឹកតិចតួចហូរឆ្លងកាត់ផ្លូវជម្រើសទាំងពីរសម្រាប់ត្រីធ្វើបន្លាស់ទីគឺប្រេក **សាដាម** និងប្រេក **សាំងភឿក**។

**ថ្ងៃទី25-26 ខែមិថុនា ឆ្នាំ2014៖** កិច្ចប្រជុំលើកទី20 របស់ MRC Council នៅទីក្រុងបាងកកប្រទេសថៃ។ ជាលទ្ធផលគឺភាគីឡាវបានប្តូរជំហររបស់ខ្លួន តាមការទាមទាររបស់ប្រទេសជាសមាជិក ដោយយល់ព្រមដាក់សំណើគម្រោងទំនប់វារីអគ្គិសន **ដន សាហុង** ឲ្យឆ្លងកាត់**ការពិគ្រោះយោបល់ជាមុន** ( Prior Consultation ) ស្របតាមកិច្ចព្រមព្រៀងមេគង្គ និងនិតិវិធីប្រើប្រាស់ទឹក។

សូមជម្រាបថា ក្រុមការងារថ្នាក់ជាតិកម្ពុជា អំពីគម្រោងវារីអគ្គិសនីដនសាហុងនេះ បានចូលរួម រាល់គ្រប់សកម្មភាព ដែលភាគីឡាវបានរៀបចំឡើងក្នុងនិតិវិធីនៃការជូនដំណឹង ដូចជាទស្សនៈកិច្ចទីតាំង និងកិច្ចប្រជុំបច្ចេកទេសជាដើម តាំងពីខែវិច្ឆិកា ឆ្នាំ2013 រហូតមកដល់ខែមិថុនា ឆ្នាំ2014 នៅមុនពេលភាគីឡាវ បានប្តូរជំហរ

មកជាការពិគ្រោះយោបល់ជាមុនវិញ។ ម៉្យាងវិញទៀត នៅខែវិច្ឆិកា ឆ្នាំ2013 បន្ទាប់ពីបានទទួលឯកសារគម្រោងដនសាហុងពីភាគីឡាវមក គណៈកម្មាធិការជាតិទន្លេមេគង្គ បានចាត់បញ្ជូនឯកសារគម្រោងទាំងនោះ ជូនដល់ក្រសួងពាក់ពន្ធ័សំខាន់ៗ មានក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងរ៉ែ និងថាមពល ក្រសួងសាធារណៈការ និងដឹកជញ្ជូន និងក្រសួងការបរទេស និងសហប្រតិបត្តិការណ៍អន្តរជាតិ ដើម្បីជ្រាប និងផ្តល់មតិយោបល់បច្ចេកទេសទៅតាមជំនាញ និងការទទួលខុសត្រូវរៀងៗខ្លួន។ នៅចុងឆ្នាំ2013 គណៈកម្មាធិការជាតិទន្លេមេគង្គ បានបូកសរុបមតិយោបល់ ដែលទទួលបាន និងបានបញ្ជូនមតិយោបល់របស់កម្ពុជា នៅក្នុងកិច្ចប្រជុំពិសេស របស់គណៈកម្មាធិការរួមនៃគណៈកម្មការទន្លេមេគង្គ នៅខែមករា ឆ្នាំ2014។

ដោយឡែក ភាគីថៃពុំបានចូលរួមក្នុងសកម្មភាពប្រជុំ ឬទស្សនៈកិច្ចទីតាំងគម្រោង តាមការអញ្ជើញរបស់ភាគីឡាវ តាំងពីខែវិច្ឆិកា ឆ្នាំ2013 រហូតដល់ខែមិថុនា ឆ្នាំ2014 ។

## ៤. កិច្ចដំណើរការ នៃការពិគ្រោះយោបល់ជាមុន

នេះជាដំណើរការពិគ្រោះយោបល់ជាមុន ស្របតាមកិច្ចព្រមព្រៀងមេគង្គ។ នៅថ្នាក់តំបន់ មានការបង្កើតក្រុមការងារថ្នាក់តំបន់មួយ ដើម្បីធ្វើការងារស្របទៅតាមឯកសារល័ក្ខខណ្ឌការងារ (Term of Reference) និងមានសមាសភាពមកពីក្រុមការងារថ្នាក់ជាតិ នៃប្រទេសទាំងបួន ជាសមាជិកគណៈកម្មការទន្លេមេគង្គ។ វាជាយន្តការពិភាក្សា រៀបចំផែនការពិគ្រោះយោបល់ជាមុន ការសិក្សាវាយតម្លៃ និងការជជែកចចារគ្នា ស្តីពីកិច្ចការពាក់ពន្ធ័នឹងគម្រោងវារីអគ្គិសនីដនសាហុង ដើម្បីរាយការណ៍លទ្ធផលនៃការវាយតម្លៃឯកសារគម្រោង ជូនគណៈកម្មាធិការរួមនៃគណៈកម្មការទន្លេមេគង្គ។ យន្តការនេះ គាំទ្រដោយក្រុមការងារបច្ចេកទេស (Technical Task Group) របស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ ដែលមានក្រុមជំនាញជាតិ និងបរទេសចូលរួម (Expert group) ផងដែរ។



កាលបរិច្ឆេទ នៃកិច្ចប្រជុំសំខាន់ៗ




កាលបរិច្ឆេទ នៃកិច្ចប្រជុំសំខាន់ៗ

**ថ្ងៃទី22 ខែសីហា ឆ្នាំ2014៖** កិច្ចប្រជុំថ្នាក់តំបន់លើកទី1 របស់ក្រុមការងារថ្នាក់តំបន់ សម្រាប់ការពិគ្រោះយោបល់ជាមុន លើសំណើគម្រោងទំនប់វារីអគ្គិសនីដនសាហុង នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ បានពិភាក្សា និងបានឯកភាពគ្នា លើបណ្ដាសកម្មភាពការងារ (ផែនទីបង្ហាញផ្លូវ) សម្រាប់ដំណើរការពិគ្រោះយោបល់ជាមុន ដែលមានរយៈពេលដំបូងចំនួន6ខែ ប៉ុន្តែមិនបានឯកភាពគ្នាលើកាលបរិច្ឆេទ នៃការចាប់ផ្ដើមដំណើរការ នៃការពិគ្រោះយោបល់ជាមុន នេះទេ។

**ថ្ងៃទី30 ខែកញ្ញា ដល់ថ្ងៃទី02 ខែតុលា ឆ្នាំ2014៖** កិច្ចប្រជុំលើកទី40 របស់គណៈកម្មាធិការរួមគណៈកម្មការទន្លេមេគង្គJC នៅរាជធានីភ្នំពេញ។ ជាលទ្ធផលគឺអង្គប្រជុំបានឯកភាពគ្នា យកថ្ងៃទី25 ខែកក្កដា ឆ្នាំ2014 ជាកាលបរិច្ឆេទ ចាប់ផ្ដើមដំណើរការ នៃការពិគ្រោះយោបល់ជាមុន ។

**ថ្ងៃទី19 ខែវិច្ឆិកា ឆ្នាំ2014៖** កិច្ចប្រជុំក្រុមការងារថ្នាក់តំបន់លើកទី2 នៅទីក្រុងសៀមរាប ប្រទេសកម្ពុជា ដោយបានពិនិត្យពិភាក្សា និងឯកភាពជាគោលការណ៍លើវឌ្ឍនភាព និងសេចក្ដីព្រាងរបាយការណ៍ សិក្សាវាយតម្លៃបឋម លើសំណើគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** ដោយ MRCS និងបានបង្ហាញពីក្ដីកង្វល់អំពីបញ្ហាប្រឈមមួយចំនួន ដូចជាមានរយៈពេលខ្លីសម្រាប់បំពេញការងារ និងបានផ្ដល់អនុសាសន៍ឲ្យធ្វើការសិក្សា និងបំពេញបន្ថែមលើចំណុចខ្វះខាត ដែលបានលើកឡើងក្នុងកិច្ចប្រជុំ។

**ថ្ងៃទី11-12 ខែធ្នូ ឆ្នាំ2014៖** ទស្សនៈកិច្ចទីតាំងគម្រោងទំនប់វារីអគ្គិសនីដនសាហុង និងកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់តំបន់លើកទី1 ស្តីពីសំណើគម្រោងទំនប់វារីអគ្គិសនី ដន សាហុង ដើម្បីប្រមូល និងពិនិត្យពិចារណាមតិយោបល់ ក្តីកង្វល់ និងអនុសាសន៍នានា ពីបណ្តាអ្នកពាក់ព័ន្ធ ដៃគូអភិវឌ្ឍនានា និងអង្គការសង្គមស៊ីវិលដែលមានសកម្មភាព ទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់តំបន់។ អង្គការសង្គមស៊ីវិលមួយចំនួន បានធ្វើពហិកាមិនចូលរួមទស្សនៈកិច្ច និងកិច្ចប្រជុំខាងលើនេះទេ។

ទស្សនកិច្ចលើកនេះ មានការសង្កេតឃើញថាឡាវបាន និងកំពុងសាងសង់ផ្លូវធំៗ ចូលទៅកាន់តំបន់កោះសាដាំ និងកោះសាហុង ការចាក់ទប់បិទផ្លូវទឹក និងមានការដឹកជញ្ជូនសម្ភារៈសំណង់ ការសាងសង់ផ្ទះកម្មករ សម្រាប់បម្រើឲ្យដំណើរការការដ្ឋានទំនប់វារីអគ្គិសនីដនសាហុង។









រូបភាពការសាងសង់ផ្លូវ និងសំភារៈ នៅប្រកផាផេង (ខែធ្នូ ឆ្នាំ2014)

**ខែមករា ឆ្នាំ2015៖** កិច្ចប្រជុំក្រុមការងារថ្នាក់តំបន់លើកទី3 របស់ ក្រុមការងារថ្នាក់តំបន់ គ្រោងនឹងពិនិត្យលើសេចក្តីព្រាងចុងក្រោយរបាយការណ៍លទ្ធផលនៃការសិក្សា វាយតម្លៃពិនិត្យឡើងវិញសំណើគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** ដែលបានធ្វើដោយ MRC មុនពេលសម្រេចដាក់ជូនជាផ្លូវការ ទៅគណៈកម្មាធិការរួមនៃគណៈកម្មការទន្លេមេគង្គ ដើម្បីពិនិត្យ។

**ខែកុម្ភៈ ឆ្នាំ2015៖** អាចនឹងមានកិច្ចប្រជុំពិសេស របស់គណៈកម្មាធិការរួម នៃគណៈកម្មការទន្លេមេគង្គ ដើម្បីពិនិត្យបូកសរុប លើលទ្ធផលនៃដំណើរការពិគ្រោះយោបល់ជាមុន មានដូចជាមតិយោបល់របស់ប្រទេសកម្ពុជា ថៃ និងវៀតណាម និងរបាយការណ៍វាយតម្លៃគម្រោង របស់ គណៈកម្មការទន្លេមេគង្គ(MRC Review Report) ថាតើគួរសម្រេចយ៉ាងណាលើសំណើគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង**។

## <u>កិច្ចដំណើរការពិគ្រោះយោបល់ជាមុន ថ្នាក់ជាតិ នៅកម្ពុជា៖</u>

ជាដំណើរការមួយ ដែលធ្វើនៅក្នុងប្រទេសនីមួយៗជាសមាជិក ដោយក្រុមការងារថ្នាក់ជាតិនីមួយៗ ដែលធ្វើទន្ទឹមគ្នានឹងការប្រជុំពិភាក្សា និងការវាយតម្លៃនៅថ្នាក់តំបន់ ដោយក្រុមការងារថ្នាក់ជាតិរួមគ្នា (ក្រុមការងារថ្នាក់តំបន់)។

**ថ្ងៃទី17-18 ខែតុលា ឆ្នាំ2014 នៅខេត្តស្ទឹងត្រែង៖** កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ក្រោមជាតិលើកទី1 ស្តីពីគម្រោងទំនប់វារីអគ្គីសនី **ដន សាហុង** សម្រាប់តំបន់មេគង្គកម្ពុជា។ សមាជិកចូលរួមកិច្ចប្រជុំនេះមានចំនួន 90នាក់ មកពី MRCS គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ក្រុមការងារថ្នាក់ជាតិ បណ្តាមន្ទីរជំនាញពាក់ព័ន្ធ (មន្ទីរធនធានទឹក និងឧតុនិយម មន្ទីរបរិស្ថាន និងមន្ទីរកសិកម្ម) អាជ្ញាធរដែនដីថ្នាក់ក្រោមជាតិ(សាលាខេត្ត) តំណាងសហគមន៍មូលដ្ឋាន និងតំណាងអង្គការមិនមែនរដ្ឋាភិបាលថ្នាក់មូលដ្ឋាន និងបណ្តាអ្នកពាក់ព័ន្ធផ្សេងៗទៀត នៃបណ្តាខេត្តតាមដងទន្លេមេគង្គចំនួន6ខេត្តគឺ ខេត្តស្ទឹងត្រែង ក្រចេះ កំពង់ចាម ព្រៃវែង កណ្តាល និងតាកែវ។ ឯកឧត្តមអភិបាលរង តំណាងគណៈអភិបាលខេត្តស្ទឹងត្រែង បានអញ្ជើញចូលរួមជាកត្តិយស បើកកិច្ចប្រជុំនេះ។ គោលបំណងចំបង នៃកិច្ចប្រជុំគឺ ដើម្បីប្រមូលមតិយោបល់ ក្តីកង្វល់និងអនុសាសន៍នានា អំពីគម្រោងទំនប់វារីអគ្គិសនី **ដនសាហុង** ពីបណ្តាខេត្តពាក់ព័ន្ធ ស្ថិតក្នុងតំបន់ទន្លេមេគង្គ។

**ថ្ងៃទី30-31 ខែតុលា ឆ្នាំ2014 នៅខេត្តបាត់ដំបង៖** កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ក្រោមជាតិលើកទី2 ស្តីពីគម្រោងទំនប់វារីអគ្គីសនី **ដន សាហុង** សម្រាប់តំបន់បឹងទន្លេសាប។ ឯកឧត្តមអភិបាលរង តំណាងគណៈអភិបាលខេត្តស្ទឹងត្រែង បានអញ្ជើញចូលរួមជាកត្តិយស បើកកិច្ចប្រជុំនេះ។ សមាជិកចូលរួមកិច្ចប្រជុំនេះមានចំនួន 75នាក់ មកពី MRCS គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ក្រុមការងារថ្នាក់ជាតិបណ្តាមន្ទីរជំនាញពាក់ព័ន្ធ (មន្ទីរធនធានទឹក និងឧតុនិយម មន្ទីរបរិស្ថាន និងមន្ទីរកសិកម្ម) អាជ្ញាធរដែនដីថ្នាក់ក្រោមជាតិ (សាលាខេត្ត) តំណាងសហគមន៍មូលដ្ឋាន និងតំណាងអង្គការមិនមែនរដ្ឋាភិបាលថ្នាក់មូលដ្ឋាន និងបណ្តាអ្នកពាក់ព័ន្ធផ្សេងៗទៀត នៃបណ្តាខេត្តតាមដងទន្លេមេគង្គ ចំនួន6ខេត្តគឺ៖ ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងកំពង់ធំ។

**ថ្ងៃទី12 ខែវិច្ឆិកា ឆ្នាំ2014 នៅរាជធានីភ្នំពេញ៖** កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិលើកទី3ស្តីពីគម្រោងទំនប់វារីអគ្គិសនី **ដនសាហុង។** ឯកឧត្តម ប៊ុន ហ៊ាន រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បានអញ្ជើញជាកិត្តិយសបើក និងដឹកនាំកិច្ចប្រជុំនេះ។ សមាជិកចូលរួមកិច្ចប្រជុំនេះមានចំនួន65នាក់ មកពី MRCS តំណាងទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិប្រចាំកម្ពុជា អង្គការសង្គមស៊ីវិល គ្រឹះស្ថានអប់រំសិក្សាស្រាវជ្រាវសាធារណៈ បណ្តាញសារព័ត៌មានក្នុងស្រុក ក្រុមការងារថ្នាក់ជាតិ ក្រសួងស្ថាប័នពាក់ពន្ធ័ និងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា។ គោលបំណងនៃកិច្ចប្រជុំ គឺដើម្បីប្រមូលមតិយោបល់ក្តីកង្វល់ និងអនុសាសន៍នានាអំពីគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង**ពីបណ្តាអ្នកពាក់ព័ន្ធថ្នាក់ជាតិ និងពិនិត្យពិចារណា និងប្រមូលផ្តុំលទ្ធផល នៃកិច្ចប្រជុំពិគ្រោះយោបល់ដែលបានធ្វើនាពេលកន្លងមក សម្រាប់ជាមូលដ្ឋាន ក្នុងការរៀបចំសេចក្តីព្រាង នៃទម្រង់ឯកសារឆ្លើយតបជាផ្លូវការទៅប្រទេសឡាវ និងដែលជាមូលដ្ឋានសម្រាប់ការពិចារណា នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ បូកសរុបចុងក្រោយថ្នាក់អន្តរក្រសួងក្នុងចំណោមក្រសួងស្ថាប័នរាជរដ្ឋាភិបាល ដែលជាសមាជិកនៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា។

កន្លងមក គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បានធ្វើរបាយរាយការណ៍ជាបន្តបន្ទាប់ គោរពរាយការណ៍ជូន និងទទួលបានការណែនាំដ៏ខ្ពង់ខ្ពស់ ពីប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជា ទីស្តីការគណៈរដ្ឋមន្ត្រី ការជូនរបាយការណ៍ និងការជួបប្រជុំ ជាមួយគណៈកម្មការទី៣ នៃរដ្ឋសភាផងដែរ។

## សកម្មភាពគ្រោងធ្វើបន្ត

**ថ្ងៃទី05 ខែមករា ឆ្នាំ2015៖** កិច្ចប្រជុំគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដើម្បីធ្វើការពិគ្រោះយោបល់ថ្នាក់ជាតិចុងក្រោយ អន្តរក្រសួង ក្នុងចំណោមក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ដែលជាសមាជិកគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដើម្បីពិនិត្យ បូកសរុបលទ្ធផលរួម នៃកិច្ចប្រជុំពិគ្រោះយោបល់ដែលបានធ្វើនាពេលកន្លងមកនិងពិភាក្សា ផ្លាស់ប្តូរមតិយោបល់ ការឯកភាព អនុមត័ លើសេចក្តីព្រាងឯកសារឆ្លើយតបជាផ្លូវការទៅប្រទេសឡាវ។ ប្រទេសថៃ និងវៀតណាម ជាសមាជិកគណៈកម្មការទន្លេមេគង្គ ក៏មានកាតព្វកិច្ចនេះដែរ ស្របតាមនិតិវិធីនៃការពិគ្រោះយោបល់ជាមុន ក្នុងក្របខ័ណ្ឌ MRC។

**ខែមករា ឆ្នាំ2015៖** បន្ទាប់ពីកិច្ចប្រជុំអន្តរក្រសួងខាងលើរួច ជំហានបន្ទាប់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា អាចនឹងធ្វើសេចក្តីរាយការណ៍ជាផ្លូវការ (របាយការណ៍ពិគ្រោះយោបល់ និងសេចក្តីព្រាងចុងក្រោយ នៃឯកសារឆ្លើយតបជាផ្លូវការទៅភាគីឡាវ) ដាក់ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីសុំការណែនាំដ៏ខ្ពង់ខ្ពស់។

**ថ្ងៃទី15-16 ខែមករា ឆ្នាំ2015 នៅហាណូយ ប្រទេសវៀតណាម៖** របៀបវារៈគម្រោងដនសាហុងនេះនឹងមានការពិភាក្សាបន្ថែម នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សា (ថ្នាក់រដ្ឋមន្ត្រី) នៃគណៈកម្មការទន្លេមេគង្គ។

**ចុងខែមករា ឬដើមខែកុម្ភៈ ឆ្នាំ2015៖** គណៈកម្មាធិការជាតិទន្លេមេគង្គ នឹងបញ្ជូនឯកសារឆ្លើយតបជាផ្លូវការទៅភាគីឡាវ តាមរយៈលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ។ លទ្ធផលនៃការឆ្លើយតបនេះ នឹងមានការបូកសរុបឯកសារ ដោយលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ រួចជម្រើសបន្តអាចមានជា៖

ទី១) អាចនឹងដាក់ឆ្លងកិច្ចប្រជុំពិសេសរបស់គណៈកម្មាធិការរួមគណៈកម្មការទន្លេមេគង្គ ដែលអាចធ្វើនៅខែកុម្ភៈ ឬខែមិនា ឆ្នាំ2015 ដើម្បីពិនិត្យពិភាក្សា និងសម្រេច។ ក្នុងករណីពុំមានការឯកភាពគ្នាលើបញ្ហានេះ គណៈកម្មាធិការរួម នឹងធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សានៃគណៈកម្មការទន្លេមេគង្គ ដែលជាថ្នាក់រដ្ឋមន្ត្រីនៃ

ប្រទេសទាំងបួនជាសមាជិក (ប្រទេសវៀតណាម ជាប្រធានក្រុមប្រឹក្សាមានអណ្តតិរយៈពេលមួយឆ្នាំ ផុតនៅចុងខែមិថុនា ឆ្នាំ2015) ដើម្បីពិភាក្សា និងចាត់ការដោះស្រាយបន្ត ទៅតាមនិតិវិធី។

ទី២)ធ្វើការបញ្ជូនដោយត្រង់ នូវរបាយការណ៍បូកសរុប ដោយប្រធានគណៈកម្មាធិការរួម (ប្រទេសកម្ពុជា ជាប្រធានគណៈកម្មាធិការរួម មានអណ្តតិរយៈពេលមួយឆ្នាំ ផុតនៅចុងខែមិថុនា ឆ្នាំ2015) អំពីលទ្ធផលនៃការពិគ្រោះយោបល់ជាមុន ជូនទៅក្រុមប្រឹក្សានៃគណៈកម្មការទន្លេមេគង្គ ដើម្បីពិភាក្សា និងចាត់ការដោះស្រាយបន្ត ទៅតាមនិតិវិធី។

# ៥. ការវាយតម្លៃ ដោយក្រុមការងារ គណៈកម្មការទន្លេមេគង្គ

## ៥.១ ធនធានជលផល និងផ្លូវសម្រាប់ការធ្វើបម្លាស់ទីរបស់ត្រី

### ១. ការវាយតម្លៃបឋម (Preliminary Screening Assessment)

ចំណុចសំខាន់ៗ ត្រូវបានកត់សំគាល់ មានដូចខាងក្រោម៖

- មានតែប្រែក **សាហុង** ប្រែក**សាដាម** និងប្រែក**សាំងភឿក** ប៉ុណ្ណោះដែលត្រូវបានយកមកធ្វើការសិក្សា។ ទោះបីជាយ៉ាងនេះក្តី ប្រែកដទៃទៀតក៏មានសារៈសំខាន់សម្រាប់ការធ្វើបម្លាស់ទីរបស់ត្រីផងដែរ ហើយចាំបាច់ ត្រូវដាក់បញ្ចូលនៅក្នុងវិធានការណ៍កាត់បន្ថយផលប៉ះពាល់។
- វិធានការកែសម្រួលរូបសាស្ត្រនៃប្រែកគោលដៅទាំង៣ខាងលើ អាចធ្វើឲ្យប្រែប្រួលដល់ស្ថានភាពប្រែកផ្សេងៗទៀត។ ករណីនេះគឺអាចជះឥទ្ធិពលដល់វិស័យជលផល និងដំណើរការប្រព័ន្ធអេកូឡូស៊ី។ (ការប៉ាន់ស្មានអំពីបម្រែបម្រួលលំហូរទឹកនៅប្រែកផ្សេងៗទៀត ត្រូវបានធ្វើឡើង ហើយនេះគ្រាន់តែជាសំណើដែលធ្វើឲ្យមានការប្តូរលំហូរទឹកនៅក្នុងប្រែក **សាដាម** និងប្រែក **ផាផេង** ប៉ុណ្ណោះ ។
- លក្ខណៈរូបសាស្ត្ររបស់ប្រែក គឺមានសារៈសំខាន់សម្រាប់ផ្លូវបម្លាស់ទីរបស់ត្រី ដូចនេះសមាសភាគនៃលក្ខណៈរូបសាស្ត្ររបស់ប្រែក **សាហុង** ដែលអាចឲ្យត្រីធ្វើការបម្លាស់ទីបានពេញមួយឆ្នាំ ត្រូវតែធ្វើការសិក្សាដើម្បីឲ្យគេអាចចម្លងលក្ខណៈរូបសាស្ត្ររបស់ប្រែកនេះ សម្រាប់ប្រែកផ្សេងៗទៀត។
- ព័ត៌មានអំពីការធ្វើបម្លាស់ទីរបស់ប្រភេទត្រីជាក់លាក់មួយចំនួននៅក្នុងប្រែក **សាហុង** រួមជាមួយប្រែកដទៃទៀតនៅក្នុងតំបន់ល្បាក់ខោន គឺនៅមានភាពខ្វះខាតនៅឡើយ។
- ការសិក្សាឯករាជ្យមួយចំនួនទៅលើអេកូឡូស៊ី និងការធ្វើបម្លាស់ទីរបស់ត្រី ត្រូវបានចងក្រងជារបាយការណ៍។ បញ្ហាជាក់លាក់មួយចំនួន ដែលមាននៅក្នុងរបាយការណ៍ទាំងនោះ រួមមានដូចខាងក្រោម៖
  - ទិន្នន័យរបស់គម្រោងគឺផ្អែកលើផលចាប់ពីអ្នកនេសាទ ដែលប្រើប្រាស់វិធីសាស្ត្រខ្វះភាពប្រាកដប្រជាតាមបែបវិទ្យាសាស្ត្រចំពោះការយកគំរូត្រីធ្វើការបម្លាស់ទី។
  - គម្រោងរៀបចំផ្លូវត្រីដ៏ធំបែបនេះ ចាំបាច់ត្រូវការទិន្នន័យជីវសាស្ត្រគោល ដែលរួមមាន ប្រភេទ និងទំហំត្រី៖ (ក)ការអាចទៅដល់ទីតាំងមួយ (ខ)ចរិកលក្ខណៈរបស់ត្រី នៅទីតាំងនោះ (ឧទាហរណ៍ ការបែងចែករវាងប្រែក តើត្រីស្វែងរកប្រែកច្រើន ឬប្រើប្រាស់ ប្រែកតែមួយក្នុងការបម្លាស់ទី) និង(គ) ត្រីឆ្លងកាត់ទីតាំងនោះ រួមទាំងលក្ខខ័ណ្ឌកម្លាំងទឹក នៅក្នុងពេលវេលា និងលំហូរខុសៗគ្នា។

- ក្រៅអំពីព័ត៌មានពាក់ព័ន្ធនឹងប្រភេទ និងទម្ងន់ដែលបានរាយការណ៍ខ្លះៗ ការតាមដានលក្ខណៈសរីរាង្គបន្តពូជត្រី គឺជាការចាំបាច់ដែលអាចផ្តល់នូវការយល់ដឹងស៊ីជម្រៅចំពោះការធ្វើបន្លាស់ទី និងសក្តានុពលប្រភេទត្រី ដែលមានពងកូន និងលំហូរកូនត្រីម្សៅនៅតំបន់នោះ។
- គ្មានវិធីសាស្ត្រ ឬគម្រោងពិសោធន៍ណាមួយ ត្រូវបានបង្ហាញឡើង ដើម្បីវាយតម្លៃថាតើទិន្នន័យពាក់ព័ន្ធត្រូវបានប្រមូលមកតាមរបៀបណា។ ដូចគ្នានេះដែរ ផ្អែកតាមការតាមដានធនធានជលផល និងផែនការសកម្មភាព (FishMap) បានស្នើឡើងថា ការតាមដានផលចាប់របស់អ្នកនេសាទនឹងបន្តអនុវត្ត "**ដោយរួមជាមួយវិធីសាស្ត្រយកគំរូ ផ្ទាល់នៃតំបន់សរុបរួម** (direct sampling of accumulation zone)" ប៉ុន្តែគេពុំបានផ្តល់នូវការពិព័ណ៌នាលំអិតពីវិធីសាស្ត្រនេះនៅឡើយទេ។
- គ្មានដំណើរការណាមួយ ត្រូវបានស្នើឡើងសម្រាប់ធ្វើការពិនិត្យឡើងវិញដោយឯករាជ្យទៅលើទិន្នន័យនៃការតាមដានធនធានជលផលទាំងនោះឡើយ។

ដូចគ្នានេះដែរ ការស្រាវជ្រាវអំពីកូនត្រីម្សៅដែលបានអនុវត្តកន្លងមក ចាំបាច់ត្រូវចងក្រងជារបាយការណ៍ពិស្តារ ជាពិសេសត្រូវកំណត់សម្គាល់នូវចំណុចសំខាន់ៗដូចខាងក្រោម៖

- បម្រែបម្រួលប្រភេទកូនត្រីម្សៅ ទៅតាមពេលវេលា (ផ្អែកតាមរដូវកាល) និងទីកន្លែង (របាយកូនត្រីម្សៅនៅក្នុងច្រកនីមួយៗនៃច្រកទាំងអស់)។
- ថាតើកូនត្រីម្សៅមានប្លោកខ្យល់ប៉ោងឡើងដែរឬទេ ដែលការណ៍នេះ មានសារៈសំខាន់ណាស់ក្នុងការវាយតម្លៃផលប៉ះពាល់លើសម្ពាធដែលឆ្លងកាត់ទួប៊ីន។
- ទីតាំងរបស់កូនត្រីម្សៅនៅក្នុងស្រទាប់ទឹកផ្សេងៗ ដើម្បីកំណត់ពីហានិភ័យនៃការស្លាប់របស់កូនត្រីម្សៅដែលបណ្តាលមកពីសម្ពាធក្នុងទួរប៊ីន។
- ថាតើកូនត្រីម្សៅដែលមានប្លោកខ្យល់ភ្ជាប់ជាមួយពោះវៀន មានមុខងារបើកចំហរឬយ៉ាងណា នៅក្នុងដំណាក់កាលដំបូងនៃជីវិត ហើយថាតើប្រភេទត្រីកាបទន្លេមេគង្គ (Cyprinid) មានកូនត្រីម្សៅដែលមានប្លោកខ្យល់លូតលាស់ជាលក្ខណៈថង់ជាច់ដោយឡែក ដែលអាចជួយឲ្យកូនត្រីទាំងនោះទប់ទល់នឹងបម្រែបម្រួល នៃសម្ពាធផ្សេងៗបានដែរឬទេ។
- ព័ត៌មានលំអិត និងវិសាលភាពនៃការតាមដានកូនត្រីម្សៅរបស់ FishMAP ចាំបាច់ត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់ថាតើមានថវិកាគ្រប់គ្រាន់ដែរទេ។
- ថវិកាដែលត្រូវផ្តល់ឲ្យសម្រាប់ការតាមដានអំពីការរស់រានរបស់ត្រី ដែលត្រូវឆ្លងកាត់ទួរប៊ីនទំនងជាមិនគ្រប់គ្រាន់ឡើយ។
- ចាំបាច់ត្រូវមានការវាយតម្លៃអំពីផលប៉ះពាល់ទៅលើប្រព័ន្ធអេកូឡូស៊ី និងហានិភ័យសង្គម ដែលពាក់ព័ន្ធទៅនឹងសក្តានុពល នៃការប្រែប្រួលធនធានជលផល ដែលការវាយតម្លៃនេះ ត្រូវកំណត់ពីភាពដែលអាចកើតមានឡើង និងផលវិបាក ព្រមទាំងភាពងាយស្រួល និងការចំណាយសម្រាប់ការកាត់បន្ថយផលប៉ះពាល់ផងដែរ។

## ២. ការវិភាគសង្គម-សេដ្ឋកិច្ច

ការវិភាគអំពីសង្គម-សេដ្ឋកិច្ច និងការចិញ្ចឹមជីវិត អាចធ្វើឲ្យប្រសើរឡើងថែមទៀត ដើម្បីជួយដល់ការរចនាគ្រោងប្លង់ជម្រើសនៃការចិញ្ចឹមជីវិត។ ជាពិសេស បណ្ដាបញ្ហាដូចតទៅនេះ ចាំបាច់ត្រូវធ្វើការដោះស្រាយ៖

- វិស័យទេសចរណ៍អាចជាប្រភពចំណូលដ៏សំខាន់នាពេលអនាគត និងក៏អាចជាជម្រើសនៃការចិញ្ចឹមជីវិតសម្រាប់ការជម្លៀសប្រជានេសាទដែរ ប្រសិនបើយើងធ្វើការសន្មតថាទេសចរនៅតំបន់ល្បាក់ **ខោនផាផេង** នឹងកើនឡើង។ បញ្ហានេះត្រូវការនូវការវិភាគយ៉ាងម៉ត់ចត់ ទាក់ទងនឹងការប្រែប្រួលទេសចរក្នុងតំបន់ទឹកធ្លាក់ ដែលជាលទ្ធផលនៃការប្រែប្រួលលំហូរទឹក និងធ្វើឲ្យប្រសើរឡើងលទ្ធភាពដែលអាចចូលទស្សនាតំបន់ទាំងនោះ។
- ត្រូវការជាចាំបាច់នូវការវាយតម្លៃហានិភ័យអេកូឡូស៊ី និងសង្គម ទាក់ទងនឹងសក្ដានុពលនៃការប្រែប្រួលធនធានជលផល ដែលកំណត់មិនត្រឹមតែការចិញ្ចឹមជីវិតប៉ុណ្ណោះទេ ប៉ុន្តែជាវិបាកវាក៏ជាភាពងាយស្រួល និងតម្លៃនៃការកាត់បន្ថយ និងកែលម្អផលប៉ះពាល់ផងដែរ។

### ៣. ការប្រែប្រួលរបបជលសាស្ត្រ និងរូបសាស្ត្រនៃប្រេកផ្លូវទឹក

ទំហំដែលប្រេក **សាំងភៀក** និង**សាដាម** អាចជំនួសផ្លូវធម្មជាតិសម្រាប់ការធ្វើបន្លាស់ទីរបស់ត្រី តាមប្រេក **សាហុង**ដែលនឹងបាត់បង់ទៅ គឺជាកត្តាមួយក្នុងចំណោមកត្តាសំខាន់ៗដែលពាក់ព័ន្ធនឹងការកាត់បន្ថយផលប៉ះពាល់ដែលអាចកើតមានឡើងរបស់គម្រោងវារីអគ្គិសនី **ដន សាហុង**។ វិធានការនេះ ជួយកាត់បន្ថយជាអប្បបរមានូវការបាត់បង់ប្រភេទចំណីសម្រាប់សត្វផ្សោត ផលប៉ះពាល់នៅខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោម និងការនេសាទនៅតំបន់ ដែលគម្រោងបានស្នើឡើងនោះ ព្រមទាំងអាចកាត់បន្ថយការស្ទាក់កំណកកករដីល្បាប់ផងដែរ។ ចំណុចសំខាន់ៗដែលត្រូវពិចារណា ទាក់ទងនឹងបញ្ហានេះគឺ៖

- ការជីកឲ្យជ្រៅនូវប្រេក **សាហុង** នៅមាត់ប្រេកចូលផ្នែកខាងលើ ត្រូវបានលើកឡើង ដើម្បីបង្កើនលំហូរទឹកក្នុងបំណងរក្សាផលិតកម្មថាមពល ប៉ុន្តែកិច្ចការនេះអាចបង្កឲ្យមានការបង្វែរកូនត្រីទើបនឹងញាស់ដ៏ច្រើនទៅក្នុងប្រេក**សាហុង**។ ទោះជាយ៉ាងនេះក្តី ក៏ការជីកឲ្យជ្រៅនូវមាត់ប្រេកចូល នៃប្រេក**សាំងភៀក** និង **សាដាម** ដើម្បីកែលម្អការបាត់បង់លំហូរទឹក អាចជួយកាត់បន្ថយផលប៉ះពាល់នេះ។
- ការប្រែប្រួលរូបសាស្ត្រនៃប្រេក **សាំងភៀក** និង**សាដាម** ត្រង់ចំណុច "choke" ត្រូវបានលើកឡើង ដើម្បីធ្វើឲ្យប្រសើរឡើងផ្លូវសម្រាប់ការធ្វើបន្លាស់ទីរបស់ត្រី ប៉ុន្តែឥទ្ធិពលនៃកិច្ចការនេះទៅលើជលសាស្ត្រ កម្លាំងទឹក ឬលក្ខណៈទម្រង់រូបសាស្ត្រ សំខាន់ៗសម្រាប់ការធ្វើបន្លាស់ទីរបស់ត្រី ចាំបាច់ត្រូវធ្វើការតាមដានបន្ត និងបញ្ជាក់ឲ្យបានច្បាស់លាស់។
- ជម្រើសផ្សេងៗទៀតក្នុងការធ្វើឲ្យប្រសើរឡើងផ្លូវសម្រាប់ការធ្វើបន្លាស់ទីរបស់ត្រីនៅក្នុងបណ្ដាប្រេកផ្លូវទឹក រួមមានការបង្កើនបរិមាណទឹកដោយការជីកឲ្យជ្រៅមាត់ប្រេកចូល និងបណ្ដាប្រេកផ្លូវទឹក ឬការកាត់បន្ថយផលិតកម្ម ថាមពលមួយផ្នែកណានោះ ក្នុងកំឡុងពេលសំខាន់ៗនៃការធ្វើបន្លាស់ទីរបស់ត្រី ចាំបាច់ត្រូវតាមដានបន្ត។
- ម៉ូដែលបច្ចុប្បន្ន នៃជលសាស្ត្រ/កម្លាំងទឹក នៃលំហូររវាងបណ្ដាប្រេកផ្លូវទឹក មិនបានលម្អិតគ្រប់គ្រាន់ ក្នុងការជួយដល់ការសិក្សាអំពីការធ្វើបន្លាស់ទីរបស់ត្រី។

- ការសិក្សាដែលបានធ្វើហូតមកដល់បច្ចុប្បន្ន គឺផ្តោតតែទៅលើច្រកផ្លូវទឹកចំនួន4 នៅភាគខាងកើត ប៉ុន្តែឥទ្ធិពលនៃការប្រែប្រួលរូបសាស្ត្របាតទន្លេ និងច្រាំងនៃច្រកទាំងនោះលើលំហូរទឹកនៅក្នុងច្រកផ្សេងៗទៀត គឺមិនទាន់មានការយល់ដឹងច្បាស់លាស់។
- បញ្ហាដែលថាទំហំ និងទម្រង់រូបសាស្ត្ររបស់ច្រក សាំងភឿក និងសាដាម ក្រោយពេលស្ថាររួច មានលក្ខណៈអាចឲ្យត្រីគ្រប់ទំហំអាចឆ្លងកាត់បានឬយ៉ាងណា ចាំបាច់ត្រូវធ្វើការតាមដានបន្ត និង/ឬវាយការណ៍ទៅតាមប្រភេទត្រី អកប្បកិរិយា និងតម្រូវការ នៃការធ្វើបន្លាស់ទី (Guilds)។
- គ្មានព័ត៌មាន ស្តីពីគ្រោងប្លង់ច្រកចូលនៃជម្រើសផ្លូវនៃការធ្វើបន្លាស់ទីរបស់ត្រី **សាំងភឿក** និង**សាដាម** និងស្តីពីការសិក្សានៃលំហូរដែលចាំបាច់សម្រាប់ទាក់ទាញត្រី លទ្ធភាពដែលអាចចូលដល់ច្រកផ្សេងៗទៀតដែលបានលើកឡើង អកប្បកិរិយានៃត្រី ដែលចាំបាច់ត្រូវធ្វើការវាយតម្លៃឲ្យបានពេញលេញនូវទំហំដែលត្រីនឹងប្រើប្រាស់ជាជម្រើសផ្លូវសម្រាប់ការធ្វើបន្លាស់ទី (បច្ចុប្បន្ន លំហូរនៃច្រកដែលជាជម្រើសទាំងនេះ គឺមិនល្អទាល់តែសោះ បើប្រៀបធៀបទៅនឹងច្រក **សាហុង**)។
- គ្មានការពិភាក្សាអំពីការទូទាត់សំណងដល់ប្រជានេសាទរស់នៅក្នុងតំបន់នៃច្រកផ្លូវទឹកទាំងបី ដែលនឹងរងផលប៉ះពាល់ តែទោះជាយ៉ាងនេះក្តី ក៏ភាពស្របច្បាប់នៃការនេសាទទាំងនោះចាំបាច់ត្រូវតាមដានបន្ត។

## ៤. ផ្លូវសម្រាប់ការធ្វើបន្លាស់ទីរបស់ត្រីនៅខ្សែទឹកខាងក្រោម

- ការវាយតម្លៃទៅលើផ្លូវត្រីសម្រាប់ត្រីផ្លាស់ទីចុះក្រោម (ត្រីពេញវ័យ កូនត្រីម្សៅ និងកូនត្រីជំទង់) និងផលប៉ះពាល់ដែលអាចកើតឡើងទៅលើធនធានជលផល អាចត្រូវបានគេធ្វើឲ្យប្រសើរឡើង ដោយការផ្តោតជាសំខាន់ទៅលើ៖
- ទួរប៊ីនប្រភេទ Bulb (មិនមែនជាប្រភេទ Kaplan) ត្រូវបានជ្រើសរើស ដោយសារវាមានប្រសិទ្ធិភាពផលិតថាមពលខ្ពស់ មានតម្លៃថោក និងមិនងាយខូច ជាមួយនឹងការប្រែប្រួលសម្ពាធ។ ប៉ុន្តែការតាមដានលើភាព ដែលអាចទ្រាំរស់បាននៃត្រីទន្លេមេគង្គ នឹងជួយដល់ការវាយតម្លៃនេះ ពិសេសប្រសិនបើផលប៉ះពាល់នៃ Trash rack លើការស្នាក់ទុកនៃត្រីនឹងត្រូវបានពិចារណា។
- ផលប៉ះពាល់នៃសម្ពាធ ការឆ្លងកាត់ និងការប៉ះទង្គិចដោយស្លាបចក្រលើគ្រប់ទំហំត្រីដែលឆ្លងកាត់ទួរប៊ីន ចាំបាច់ត្រូវធ្វើការវាយតម្លៃ។
- ការស្លាប់ត្រីធំៗដ៏ច្រើន ត្រូវបានគេរំពឹងទុក ជម្រើសនៃការកំណាត់ (Fish Screening) ត្រីនៅច្រកចេញ ចាំបាច់ ត្រូវសិក្សាស្រាវជ្រាវ។
- ល្បឿនទឹកធ្លាក់ចុះពី 1m/s ទៅ 0.3m/s ក្នុងចម្ងាយ 2km ពីស្ថានីយ៍ថាមពលក្នុងច្រក **សាហុង** ដែលអាចគ្រប់គ្រាន់ ក្នុងការធ្វើឲ្យកូនត្រីទើបនឹងញាស់ និងកូនត្រីម្សៅរងធ្លាក់ចុះ?។ ហេតុនេះចាំបាច់ត្រូវមានការតាមដានបន្ថែម និងបង្កើតឡើងនូវយុទ្ធសាស្ត្រនៃការកាត់បន្ថយ និងកែលម្អមួយ។ កិច្ចការនេះគឺចាំបាច់បំផុតសម្រាប់ រដូវប្រាំង (ក្នុងខែមិនា) នៅពេលដែល 50%នៃលំហូរទឹកនឹងត្រូវបង្វែរចូលច្រក **សាហុង**។ កិច្ចការនេះ នឹងជួយបំពេញបានខ្លះនូវការបាត់បង់កូនត្រីដែលអណ្តែតតាមខ្សែទឹក។

### ៥. ការគ្រប់គ្រង និងការចិញ្ចឹមជីវិត

លក្ខណៈពិសេសមួយនៃការកាត់បន្ថយផលប៉ះពាល់នៃការខូចខាតធនធានជលផល លើជីវភាពរស់នៅរបស់ប្រជានេសាទមូលដ្ឋាន អាចធ្វើការថ្លឹងថ្លែងបាន តាមរយៈការកាត់បន្ថយសម្ពាធពីការធ្វើនេសាទ ដោយសហគមន៍មូលដ្ឋាន តាមរយៈការរៀបចំឲ្យមានកម្មវិធីមុខរបរចិញ្ចឹមជីវិត និងការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព។ ផែនការសម្មភាពតាមដានធនធានជលផលរបស់គម្រោងវារីអគ្គិសនី ដន សាហុង (FishMAP) មានគោលបំណងដោះស្រាយបញ្ហាទាំងនេះ តាមរយៈវិធានការណ៍កាត់បន្ថយផលប៉ះពាល់ដោយផ្ទាល់ និងការរៀបចំពង្រឹងប្រព័ន្ធគ្រប់គ្រងធនធានជលផល ដោយបង្កើតឲ្យមានជម្រើសមុខរបរចិញ្ចឹមជីវិតដែលមិនពឹងផ្អែកលើវិស័យជលផល ដើម្បីកាត់បន្ថយសម្ពាធនេសាទនៅតាមបណ្តាច្រក ដែលបានកែសម្រួល និងភូមិក្បែរៗនោះ។ ទោះជាយ៉ាងនេះក្តី ក៏ទំហំដែលកិច្ចការនេះនឹងអាចអនុវត្តបាន ឬមានប្រសិទ្ធិភាព ហើយថាតើជម្រើសនៃការចិញ្ចឹមជីវិត អាចកំណត់បាន ឬយ៉ាងណា ចាំបាច់ត្រូវធ្វើការតាមដានបន្ថែម។ ជាការពិត វិធានការនៃការយកចេញពីច្រកនូវឧបករណ៍នេសាទ (Lee Traps) ដែលបាន និងកំពុងប្រើប្រាស់ជាប្រពៃណីក្នុងច្រក **សាហុង** គឺហាក់ដូចជាពុំមានភាពខុសគ្នាអ្វីទាំងអស់។ នេះគឺមានន័យថា ល័ក្ខខ័ណ្ឌគោលជាមូលដ្ឋាន ចាំបាច់ត្រូវបង្កើតឡើង ដោយមានការចូលរួមពីសហគមន៍នេសាទនៅក្នុងតំបន់ព្រំដែនកម្ពុជា។ ដូចគ្នានេះដែរ ការពិនិត្យឡើងវិញ ចំណេះដឹងដែលមានស្រាប់ ស្តីពីផ្លូវធម្មជាតិនៃការធ្វើបន្លាស់ទី នៃប្រភេទត្រីផ្លាស់ទីមានតម្លៃសេដ្ឋកិច្ចចាំបាច់ត្រូវអនុវត្ត ហើយការវិភាគហានិភ័យនៃការចិញ្ចឹមជីវិតទាក់ទងនឹងផលប៉ះពាល់ សម្រាប់ប្រភេទនីមួយៗ ក៏ចាំបាច់ត្រូវអនុវត្តផងដែរ។

### ៦. សន្និដ្ឋាន

រហូតមកទល់នឹងមានគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** ដែលជាច្រកមួយក្នុងទន្លេមេ នៃទន្លេមេគង្គ ទើបមានតម្រូវការចាំបាច់ក្នុងការសិក្សានានា សម្រាប់កាត់បន្ថយផលប៉ះពាល់ដល់ធនធានជលផល និងផ្លូវត្រី ព្រមទាំងលក្ខ័ណ្ឌសេដ្ឋកិច្ច សង្គមរបស់ប្រជានេសាទនៅតំបន់អាងទន្លេមេគង្គក្រោម។ ក្នុងករណីអាក្រក់បំផុត អាចនឹងមានការបាត់បង់ផ្លូវត្រី នៅផ្នែកណាមួយ ប៉ុន្តែមានជម្រើសសម្រាប់ធ្វើការកាត់បន្ថយផលប៉ះពាល់ឲ្យនៅតិចបំផុត។ ក្នុងករណីនេះ អ្នកអភិវឌ្ឍន៍គម្រោង បានស្នើផ្តល់នូវដំណោះស្រាយថ្មីមួយ ដោយជំនួសផ្លូវត្រីដែលនឹងបាត់បង់នៅច្រក **សាហុង** ដោយច្រកផ្សេងៗទៀត។ ជាការពិតកិច្ចការទាំងនេះគឺអាស្រ័យទៅនឹងវិសាលភាពនៃជម្រើសច្រកផ្លូវត្រីដែលបានស្នើឡើងនោះ ថាតើអាចជំនួស ឬអាចម្លងឲ្យដូចនូវលក្ខណៈរូបសាស្ត្រព្រមទាំងភាពទាក់ទាញនៃលំហូរទឹក ដែលមាននៅច្រក**សាហុង** នាពេលបច្ចុប្បន្នបានដែរឬទេ។ បច្ចុប្បន្ននេះ នៅពុំទាន់មានព័ត៌មានគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ក្នុងការសិក្សា និងវាយតម្លៃ ថាតើវិធានការទាំងនេះអាចអនុវត្តបាន ឬយ៉ាងណានោះទេ ហើយថាតើវិសាលភាពនៃការបាត់បង់ផ្លូវត្រីអាចកាត់បន្ថយបាន ឬយ៉ាងណានោះទេ។

## ៥.២ ផ្សោតទឹកសាប (Irrawaddy Dolphin)

### ១. សេចក្តីសង្ខេបពីផលប៉ះពាល់ដែលអាចកើតមាន

ទិន្នន័យឆ្នាំ2013 បានបញ្ជាក់ថាមានផ្សោតទឹកសាបចំនួន 6ក្បាលរស់នៅតំបន់អន្លង់ឈើទាល ជាប់ព្រំ

ដែនកម្ពុជា-ឡាវ ហើយមានតែផ្សោតទឹកសាបទាំងនេះទេ ដែលអាចចាត់ទុកថានៅសេសសល់ និង ធ្វើដំណើរផ្លាស់ទីក្នុងតំបន់ព្រំដែននៃប្រទេសទាំងពីរ។ ផ្សោតទឹកសាប ៦ក្បាលនេះអាចជាប្រភពនៃការបន្តពូជ បង្កើនចំនួនសត្វនេះតទៅអនាគត។ ទីតាំងដ៏ជិត រវាងជម្រកធម្មជាតិរបស់សត្វនេះនិងទីតាំងគម្រោងនិងដោយសារចំនួនសត្វនេះនៅសេសសល់តិចផង នឹងធ្វើឲ្យសត្វនេះងាយរងគ្រោះថ្នាក់។ កត្តាគំរាមកំហែងសំខាន់នៃគម្រោង លើផ្សោតទឹកសាបគឺ៖

- ផលប៉ះពាល់ចេញពីការគាស់កកាយ និងការសាងសង់ ពិសេសគឺសំឡេងរំខាន។
- សំឡេងរំខានកើតចេញពីប្រតិបត្តិការទួរប៊ីន។
- ការប្រែប្រួលរបបលំហូរទឹកក្នុងមូលដ្ឋាន និងសក្តានុពលនៃការប្រែប្រួលកំណកដីល្បាប់។
- ការកើនឡើងនៃនាវាចរ ដែលជាលទ្ធផលនៃកំណើនវត្តមានមនុស្សនៅក្នុងតំបន់ និង
- ការថយចុះនូវបរិមាណ និងប្រភេទចំណី ដោយសារការរេចរិល និងការរាំងខ្ទប់ច្រកផ្លូវ សម្រាប់ការធ្វើបន្លាស់ទីរបស់ត្រី។

ការថយចុះនូវបរិមាណ និងប្រភេទចំណី ដោយសារការរេចរិល និងការរាំងខ្ទប់ផ្លូវសម្រាប់ការធ្វើបន្លាស់ទីរបស់ត្រី មិនត្រឹមតែគម្រាមកំហែងដល់ផ្សោតទឹកសាប ៦ក្បាលក្នុងតំបន់ព្រំដែនកម្ពុជា-ឡាវប៉ុណ្ណោះទេគឺវាជាការគម្រាមកំហែងដល់ផ្សោតតំបន់មេគង្គទាំងមូល។ ការបាត់បង់ផ្សោតទឹកសាប ៦ក្បាល គឺនឹងធ្វើឲ្យថយចុះផ្សោតទឹកសាបទូទាំងតំបន់មេគង្គ 34% និងថយចុះផ្សោតទឹកសាបទូទាំងពិភពលោក 7%។ ដោយសារអន្លង់ជ្រៅៗមានទីតាំងនៅជិតទីតាំងគម្រោង ហើយម៉្យាងទៀតផ្សោតទឹកសាបត្រូវបានគេសង្កេតឃើញធ្វើបន្លាស់ទីនៅក្នុង ឬជិតតំបន់ដែលគ្រោងនឹងធ្វើការគាស់កកាយ ហេតុនេះផ្សោតទឹកសាបក្នុងតំបន់នេះនឹងត្រូវរងនូវផលប៉ះពាល់ដោយកត្តាជាច្រើនក្នុងកំឡុងពេលសាងសង់ និងគាស់កកាយ។ សំឡេងរំខាន និងរំញ័រអាចឮយ៉ាងខ្លាំងដល់អន្លង់ជ្រៅៗក្នុងទឹកដីកម្ពុជា។ ដូចគ្នានេះដែរ ក្នុងកំឡុងពេលប្រតិបត្តិការ សំឡេង និងរំញ័ររំខានចេញពីទួរប៊ីន ក៏អាចរំខានយ៉ាងធ្ងន់ធ្ងរដល់ផ្សោតទឹកសាបផងដែរ។ លទ្ធផលនៃការសិក្សាស្រាវជ្រាវ បានបញ្ជាក់ថា សត្វផ្សោតមានភាពងាយនឹងប៉ះទង្គិចយ៉ាងខ្លាំងជាមួយនឹងសំឡេង និងប្រព័ន្ធសូណាយ៉ាងស្មុគ្រស្មាញ (Complex sonar system) ដែលប្រើប្រាស់សម្រាប់រកចំណី ធ្វើដំណើរ និងការទាក់ទងគ្នា។ហេតុនេះផលប៉ះពាល់ចេញពីសំឡេងដែលបង្កើតឡើងដោយមនុស្ស នឹងនាំឲ្យមានការប្រែប្រួលរូបសាស្ត្រ និង/ឬ អកប្បកិរិយាដល់សត្វនេះ។ធម្មជាតិ និងកម្រិតនៃផលប៉ះពាល់នីមួយៗ មានការប្រែប្រួលទៅតាមចម្ងាយនៃទីតាំងរបស់សត្វនេះ ពីប្រភពសំឡេងឬរំញ័រ ការជះចេញនៃសំឡេងឬរំញ័រ និងកម្រិត លក្ខណៈនៃសំឡេងឬរំញ័រ ហើយផលប៉ះពាល់អាចធ្វើឲ្យស្លាប់ និងខូចខាតរូបសាស្ត្រ រំខានដល់ការរកចំណី ការបន្តពូជ និងការចិញ្ចឹមកូន។ បញ្ហានេះគឺមិនទាន់មានការសិក្សានៅឡើយទេ។

ទោះជាយ៉ាងណាក៏ដោយ ក៏សំឡេង និងការកើនឡើងសកម្មភាពនានានៅក្នុងតំបន់ក្នុងកំឡុងពេលសាងសង់ នឹងមានផលប៉ះពាល់ក្នុងទំហំណាមួយទៅលើផ្សោតទឹកសាប ទន្ទឹមនឹងនេះសំឡេង ឬរំញ័រចេញពីប្រតិបត្តិការទួរប៊ីននឹងជះឥទ្ធិពលលើផ្សោតទឹកសាបនេះ។

## ២. អនុសាសន៍

- ការអង្កេតអំពីការរញ្ជួយ (Seismic survey) ចាំបាច់ត្រូវអនុវត្តជាផ្នែកមួយនៃដំណាក់ការគ្រោងប្លង់នៃគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** ដែលត្រូវអនុវត្តតាមគោលការណ៍នាំ ដែលអាចទទួលយកបានកម្រិតអន្តរជាតិ (ឧទាហរណ៍ បទដ្ឋានបច្ចេកទេសរបស់រដ្ឋាភិបាលអូស្ត្រាលី ឆ្នាំ2008)។
- ផែនការត្រួតពិនិត្យ គឺជាតម្រូវការចាំបាច់ មុនការអង្កេតអំពីការរញ្ជួយ ដើម្បីចែងអំពីតំបន់ដែលត្រូវមានការប្រុងប្រយ័ត្នជាមុន និងវិធានការបង្ការដែលត្រូវអនុវត្ត ដើម្បីកាត់បន្ថយ ឬកែលម្អផលប៉ះពាល់ចំពោះសត្វផ្សោតទឹកសាបឆ្លងដែននេះ។
- ការវាយតម្លៃលើភាពញឹកញាប់ រយៈពេល កម្រិតសម្ពាធនៃសំឡេងរំខាន និងការជះចេញនៃសំឡេងពីបណ្តាសកម្មភាពសាងសង់ផ្សេងៗ ចាំបាច់ត្រូវអនុវត្ត ដើម្បីកំណត់សក្តានុពលនៃផលប៉ះពាល់លើសត្វផ្សោត និងបង្កើតឡើងនូវតំបន់ដាច់ដោយឡែក/តំបន់ដែលត្រូវការពារជាមុន។
- ផែនការគ្រប់គ្រង និងត្រួតពិនិត្យបរិស្ថាន ត្រូវបញ្ចូលនូវចំណុចដែលមានចែងអំពីការត្រួតពិនិត្យផលប៉ះពាល់លើសត្វផ្សោត។ យុទ្ធសាស្ត្រនៃការត្រួតពិនិត្យ ចាំបាច់ត្រូវបង្កើតឡើងដោយអ្នកជំនាញ ដែលមានសមត្ថភាពពេញលេញ និងការពិនិត្យឡើងវិញរួមគ្នា។
- វិភាគទានដល់កិច្ចខិតខំប្រឹងប្រែងអភិរក្សសត្វផ្សោត ត្រូវមានការផ្គត់ផ្គង់ខាងហិរញ្ញវត្ថុគ្រប់គ្រាន់ និងស្របជាមួយកិច្ចខិតខំប្រឹងប្រែងដែលមានស្រាប់ និងត្រូវតែមានគម្រោងពិគ្រោះយោបល់ជាមួយអ្នកជំនាញទាំងនោះ ដើម្បីបង្កើនដល់កម្រិតអតិបរមាសក្តានុពលនៃផលប្រយោជន៍ដែលនឹងត្រូវបានផ្តល់។

## ៥.៣ ជលសាស្ត្រ និងភក់ដី

### ១. ជលសាស្ត្រ

### យោបល់នៃរបាយការណ៍របស់វិនិយោគិន

ក្រុមការងារសង្កេតឃើញថា ការប្រែប្រួលជលសាស្ត្រមានការទាក់ទងទៅនឹង ការវាយតម្លៃគម្រោង (Scheme) គ្រោងប្លង់ និងប្រតិបត្តិការរបស់វាត្រូវបានពិចារណា និងការប៉ាន់ស្មានជលសាស្ត្រ នៅនឹងកន្លែង "at site" ពីខ្សែទឹកខាងលើនៅទីតាំងវាស់ស្ទង់ ការរក្សាលំហូរទឹកក្នុងទន្លេមេ នៃទន្លេមេគង្គក្នុងតំបន់ប៉ាក់សេ របស់គណៈកម្មការទន្លេមេគង្គ (Pakse MRC PMFM Site) ត្រូវបានអធិប្បាយលម្អិតបានសមស្រប (ក្រុមការងារសង្កេតឃើញថា គ្រោងប្លង់ និងប្រតិបត្តិការគឺផ្អែកលើការវាយតម្លៃបណ្តាសមាសភាគជលសាស្ត្រផ្សេងៗ ដែលក្នុងនោះ ប្រើប្រាស់ជាចំបងនូវទិន្នន័យនៅចំណុចខ្សែទឹកខាងលើ ក្នុងស្ថានីយ៍វាស់ស្ទង់ការរក្សាលំហូរទឹកក្នុងទន្លេមេ នៃទន្លេមេគង្គក្នុងតំបន់ប៉ាក់សេ របស់ គណៈកម្មការទន្លេមេគង្គ)។

### សន្និដ្ឋាន

ផ្នែកជលសាស្ត្រនៃឯកសារដែលបានផ្តល់ បានធ្វើដល់កម្រិតសុក្រិត្យភាពសមស្រប និងប្រកបដោយការយកចិត្តទុកដាក់។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏ការវិភាគបែបស្ថិតិ (Statistical Analysis) ដែលប្រសើរជាងនេះនឹងផ្តល់នូវការវាយតម្លៃហានិភ័យនៃលំហូរទឹកកម្រិតទាប ព្រមទាំងការកាត់បន្ថយលំហូរឆ្លងកាត់ស្ថានីយ៍ថាមពល ឬឆ្លងកាត់ច្រកផ្លូវសម្រាប់ការធ្វើបន្លាស់ទីរបស់ត្រី។

ជាការពិតគឺថា ភាគីនៃកិច្ចសន្យា ចាំបាច់ត្រូវធ្វើការសិក្សាម៉ូដែលលម្អិតបន្ថែមទៀត ដែលផ្តល់នូវកាលានុវត្តិភាពមួយក្នុងការដោះស្រាយបញ្ហាជាច្រើនដែលបានលើកឡើងក្នុងផ្នែកស្តីពីធនធានជលផល និងផ្លូវសម្រាប់ការធ្វើបន្លាស់ទីរបស់ត្រីខាងលើ ដែលជាហេតុជួយធ្វើឲ្យបានសមស្រប ការកាត់បន្ថយឬការកែលម្អភាពដែលអាចប្រឈម នឹងផលប៉ះពាល់នានា។

ការសិក្សាជលសាស្ត្រសម្រាប់សំណើគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** គឺមានលក្ខណៈទូលំទូលាយ និងផ្អែកលើវិធីសាស្ត្រដ៏ល្អមួយ (ម៉ូដែលជលសាស្ត្រ និងកម្លាំងទឹក)។

វានឹងមានប្រយោជន៍បន្ថែមទៀត ប្រសិនបើលទ្ធផលនៃការសិក្សាជលសាស្ត្រសំខាន់ៗ ត្រូវបានសង្ខេបឲ្យបានច្បាស់លាស់ ពិសេសគឺទាក់ទងនឹងល័ក្ខខ័ណ្ឌនៃទីតាំង ក្នុងគ្រាមុន និងក្រោយការសាងសង់ ដើម្បីជួយឲ្យមានភាពងាយស្រួលក្នុងការយល់បាន អំពីការវាយតម្លៃផលប៉ះពាល់ ដែលនឹងសិក្សាដោយអ្នកដែលគ្មានជំនាញជលសាស្ត្រ ក្នុងការបង្ហាញថាការប្រែប្រួលលំហូរ និងកម្រិតកម្ពស់ទឹក នឹងនាំទៅដល់ការវាយតម្លៃនូវភាពប្រឈមដែលអាចមានផលប៉ះពាល់។

ចន្លោះប្រហោងសំខាន់ៗនៅក្នុងការវិភាគ គឺបញ្ហារបបលំហូរទឹក សម្រាប់ការវិភាគបរិស្ថាន ដែលចាំបាច់ត្រូវធ្វើការពិចារណាឲ្យបានស៊ីជម្រៅបន្ថែមទៀត គឺមិនត្រឹមតែធ្វើការពិចារណាលើលំហូរទឹកប៉ុណ្ណោះទេ។ ជាប្រការសំខាន់ក្នុងការពិចារណាលើការប្រែប្រួលផ្សេងៗទៀត ដូចជាល្បឿនទឹក និងសណ្ឋានរូបសាស្ត្រនៃច្រកផ្លូវទឹកក្នុងតំបន់ទំនប់នៃគម្រោង។

បទបង្ហាញលម្អិត និងច្បាស់លាស់ថែមទៀត ស្តីពីអ្វីដែលនឹងប្រែប្រួលលើលក្ខណៈរូបសាស្ត្រ នៃច្រក **សាជាម** និងច្រក**សាំងភឿក** គឺជាជំនួយដ៏សំខាន់ ក្នុងការពិចារណានូវចំណុចសំខាន់ដែលថា តើច្រកទាំងនេះនឹងត្រូវបានបង្កើតឡើងជាជម្រើសផ្លូវសម្រាប់ការធ្វើបន្លាស់ទីរបស់ត្រីបានដែរ ឬយ៉ាងណា។

**២. <u>កករដី</u>**

**កង្វះខាត និងភាពមន្ទិល**

- ការរៀបចំក្រាហ្វិក (Rating curve) ថ្មី សម្រាប់ការប៉ាន់ស្មានកករដីអណ្តែតក្នុងទឹកដែលហូរចូលច្រក **សាហុង**។
- បរិមាណកករដីមធ្យមដែលបានប៉ាន់ស្មាន ប្រមាណ 9.3Mt/yr ដោយវិនិយោគិនគម្រោង ចាំបាច់ត្រូវធ្វើការប៉ាន់ស្មានឡើងវិញ ដោយមានការចូលរួម។
- ការប៉ាន់ស្មានលម្អិតនៃការហូរនាំកករដី (ទាំងអណ្តែតក្នុងទឹក និងនៅបាតទន្លេ) ដោយផ្អែកលើទិន្នន័យវាស់វែងជាក់ស្តែង។
- វិនិយោគិនគម្រោងបានប្រើប្រាស់ព័ត៌មានពីប្រទេសអ៊ីរ៉ង់ អ៊ីរ៉ាក់ និងទន្លេ Indus ក្នុងការបង្កើតឡើងនូវ PSD ដោយការសន្មត សម្រាប់គម្រោងទំនប់វារីអគ្គិសនី ដន សាហុង (ទំហំនៃរបាយភាគល្អិត នៃកករដីល្បាប់ ដែលបានសន្មត និងកករដីអណ្តែតនៅបាតទន្លេ ក៏ត្រូវបញ្ជាក់ឲ្យបានច្បាស់)។

**ផលប៉ះពាល់ឆ្លងដែន**

- ត្រូវការជាចាំបាច់នូវការតាមដានកករដីក្នុងអន្លង់ជ្រៅៗ ដែលមិនទាន់បានវាស់វែងនៅឡើយ។
- ត្រូវការជាចាំបាច់នូវការតាមដានភាពល្អក់ (Turbidity) ដែលមិនទាន់បានវាស់វែងនៅឡើយ។
- ត្រូវការជាចាំបាច់នូវការតាមដានកករដី នៅតំបន់បណ្តាកោះឆ្លងដែន ដែលមិនទាន់បានវាស់វែងនៅឡើយ។

**សក្តានុពលនៃផលប៉ះពាល់ផ្សេងៗទៀត**

- វិនិយោគិនគម្រោងចាំបាច់ត្រូវធ្វើការបង្ហាញឲ្យឃើញថា លំហូរទឹកអតិបរមាចូលទៅក្នុងច្រក ខោនផាផេង ត្រូវបានធានា។
- កំណកដីនៅក្នុងគ្រោងប្លង់បច្ចុប្បន្ន ត្រង់មាត់ច្រកចូលនៃច្រក **សាហុង** នឹងមានការប្រែប្រួលយ៉ាងខ្លាំង ដែលនឹងលំបាកក្នុងការគ្រប់គ្រង។
- គ្រោងប្លង់ទ្វារទឹក ត្រង់ច្រកចូល (Gated Inlet Control Structure) ចាំបាច់ត្រូវធ្វើការតាមដាន។

## ៥.៤ គុណភាពទឹក និងប្រព័ន្ធអេកូឡូស៊ី

### ១. គុណភាពទឹក

ដោយទំនប់វារីអគ្គិសនី ដន សាហុងគឺជាប្រភេទទំនប់ដែលស្តុកទឹកតិច គេរំពឹងថានឹងពុំមានបញ្ហាគុណភាពទឹកធ្ងន់ធ្ងរនោះទេ នៅពេលមានប្រតិបត្តិការជាធម្មតា។ ទោះជាយ៉ាងនេះក្តី ក៏អាចបង្កផលប៉ះពាល់ខ្លះៗក្នុងកំឡុងពេលសាងសង់ ដែលភាគច្រើនទាក់ទងនឹង៖

- ការកើនឡើងកករដីល្បាប់អណ្តែតក្នុងទឹក ដោយសារការគាស់កកាយបាតទន្លេ/ច្រក ការកាយ និងដឹកជញ្ជូនដី ឧទាហរណ៍ ការសាងសង់ទំនប់បង្វែរទឹក និងការរៀបចំច្រាំងទន្លេ/ច្រក។ល។
- ការកើនឡើងសារធាតុពុលសរីរាង្គ ចេញពីការដ្ឋាន កន្លែងស្នាក់នៅរបស់កម្មករ អាហារដ្ឋាន។ល។
- ការលេចធ្លាយដោយចៃដន្យនូវសម្ភារៈសំណង់ រួមទាំងការលាងសម្អាតបេតុងជាដើម។
- ការលេចធ្លាយដោយចៃដន្យនូវប្រេង និងឥន្ធនៈផ្សេងៗពីរថយន្ត និងការថែទាំរោងចក្រអគ្គិសនី។

អាចនឹងមានទឹកខូចគុណភាពហូរចុះទៅខ្សែទឹកខាងក្រោមនៅកម្ពុជាដោយចៃដន្យ ដែលភាគច្រើនគឺដោយសារការកើនឡើងកំណកដីល្បាប់អណ្តែតក្នុងទឹក។ បញ្ហានេះអាចបង្កនូវផលប៉ះពាល់ធ្ងន់ធ្ងរក្នុងរដូវដែលមានទឹកតិច នៅពេលដែលទឹកមានសភាពថ្លា។ ការលេចធ្លាយ គ្រោះថ្នាក់ និងការបាត់បង់ដំណើរការនៃរោងចក្រប្រព្រឹត្តិកម្មទឹកកខ្វក់ក៏អាចកើតមានឡើងដែរ ហើយដែលនឹងបង្កផលប៉ះពាល់លើគុណភាពទឹកនៅខ្សែទឹកខាងក្រោមក្នុងតំបន់ដីសើម រ៉ាមសារ ខេត្តស្ទឹងត្រែង នៃកម្ពុជា។

ប្រសិនបើនឹងមានការអនុវត្តនូវវិធានការដែលបានលើកឡើង សម្រាប់ការគ្រប់គ្រងការបំពុលទឹកក្នុងកំឡុងពេលសាងសង់ ផ្គួបផ្សំនឹងអាងស្តុកទឹកមានទំហំតូច និងរយៈពេលតម្កល់ទឹកទុកខ្លី ក្នុងកំឡុងពេលប្រតិបត្តិការ គម្រោងទំនប់វារីអគ្គិសនី ដន សាហុង អាចនឹងគោរពតាម "គោលការណ៍បឋមនៃគ្រោងប្លង់ទំនប់វារីអគ្គិសនីនៅលើទន្លេមេ នៃទន្លេមេគង្គ" (Preliminary Design Guidance)។

## ២. ផលប៉ះពាល់លើជម្រកធម្មជាតិជលសាស្ត្រ

ឯកសារដែលបានផ្តល់ មានចែងពីលំហូរទឹក និងការប្រែប្រួលសណ្ឋានរូបសាស្ត្រនៃប្រេក **សាហ៊ុង** ប្រេក **សាជាម** និងប្រេក**សាំងកឿក** និងជុំវិញតំបន់ទឹកធ្លាក់ **ខោនផាផេង**។ ទោះជាយ៉ាងនេះក្តី ក៏ការគិតគូរវិភាគនេះ បានធ្វើតែអំពីផលប៉ះពាល់លើផ្លូវសម្រាប់ការធ្វើបន្លាស់ទីរបស់ត្រី និងពុំមានការសិក្សាវិភាគលើជម្រកធម្មជាតិនៅ តាមដងទន្លេ រុក្ខជាតិ និងពពួកសត្វផ្សេងៗទៀតនោះទេ។ជាទូទៅគឺមានការសន្មតថា ប្រេកផ្លូវទឹកទាំងអស់ មានសារៈសំខាន់ស្មើគ្នា ឬជម្រកធម្មជាតិនៅតាមដងទន្លេពុំមានសារៈសំខាន់ ប៉ុន្តែជាការពិតវាពុំដូច្នោះទេ។ គឺថា មានការបញ្ជាក់អំពីសារៈសំខាន់នៃបណ្តាពំនូកខ្សាច់ដែលលេចឡើងនៅពេលមានលំហូរទឹកទាបនៅតាមប្រេកផ្លូវ ទឹកមួយចំនួន ដែលជាជម្រកធម្មជាតិសំខាន់សម្រាប់ជាសំបុកពងកូននៃពពួកបក្សី និងអណ្តើក។

គឺជាសារៈប្រយោជន៍សំខាន់ក្នុងការសិក្សាប្រៀបធៀបនូវភាពខុសគ្នានៃប្រេកផ្លូវទឹកទាំងឡាយ ដើម្បីធ្វើ ការវាយតម្លៃសារៈសំខាន់នៃការបាត់បង់ជម្រកធម្មជាតិក្នុងប្រេក **សាហ៊ុង** និងថាតើប្រេក **សាជាម** និង**សាំងកឿក** អាចផ្តល់នូវជម្រកធម្មជាតិដែលបាត់បង់ទាំងនេះបានដែរឬទេ? ដូចគ្នានេះដែរ ផលប៉ះពាល់នៃការប្រែប្រួល លំហូរទឹកក្នុងប្រេក **ផាផេង** និងប្រេកផ្សេងៗទៀត ក៏ចាំបាច់ត្រូវធ្វើការវាយតម្លៃដែរ។

ឯកសារគម្រោងបានសរសេរខ្លះៗអំពីជម្រកធម្មជាតិតំបន់ដីគោក ហើយរបាយការណ៍វាយតម្លៃផលប៉ះ ពាល់បរិស្ថាន បានចែងអំពីតំបន់សិក្សានៃ "បណ្តាកោះ ថ្ម និងទឹក" ក្នុងប្រេក សាហ៊ុង និងតំបន់ខ្សែទឹកខាង ក្រោមដែលនឹងរងផលប៉ះពាល់មានទំហំសរុប 92.6ha ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏ពុំមានការវិភាគអំពីជម្រក ធម្មជាតិជលសាស្ត្រទាំងនេះ ឬក៏ការវាយតម្លៃសារៈសំខាន់នៃអេកូឡូស៊ីរបស់វា។ បណ្តាវិធានការកាត់បន្ថយ ឬកែ លម្អ (សម្រាប់ការគ្រប់គ្រងកោះដែលរងផលប៉ះពាល់ដោយសារការសាងសង់) ដែលបានលើកឡើង គឺអាចនឹង មានប្រសិទ្ធិភាព ក្នុងករណីដែល៖

- ភាគីកិច្ចសន្យាគោរពតាមការអនុវត្តដ៏ល្អនូវវិធានការគ្រប់គ្រងការហូរច្រោះដី និងការសំណល់ ក្នុងកំឡុង ពេលសាងសង់។
- គោរពគោលការណ៍ត្រួតពិនិត្យគម្រោង និងកិច្ចសន្យាឲ្យមានប្រសិទ្ធិភាព។
- ការត្រួតពិតិត្យគុណភាពទឹកដែលបានបញ្ជាក់នៅក្នុងផែនការគ្រប់គ្រង និងត្រួតពិនិត្យបរិស្ថាន ត្រូវបាន អនុវត្ត ហើយបរាជ័យភាពដោយចៃដន្យក្នុងការគោរពបទដ្ឋានគុណភាពទឹក ត្រូវបានតាមដាន ហើយវិ ធានការជួសជុលកែលម្អ ត្រូវបានគោរព និងអនុវត្ត ប្រសិនបើចាំបាច់។
- វិធានការឆ្លើយតបនឹងគ្រោះអាសន្នដ៏សមស្រប ត្រូវបានអនុវត្ត ដោយបុគ្គលិក ដែលបានឆ្លងកាត់វគ្គ បណ្តុះបណ្តាលដ៏សមស្រប។ រាល់ឧប្បត្តិហេតុទាក់ទងនឹងការលេចធ្លាយ និងការបំពុលទឹក ត្រូវបានតាម ដាន ហើយវិធានការជួសជុលកែលម្អ ត្រូវបានគោរព និងអនុវត្ត។

## ៣. កំណែប្រែលំហូរទឹក និងផលប៉ះពាល់លើល្បាក់ខោន

លំហូរធម្មជាតិនៃប្រេក **សាហ៊ុង** ជាមធ្យមប្រចាំឆ្នាំគឺ 510m$^3$/sec ដែលលំហូរកម្រិតខ្ពស់គឺ 1,500m$^3$/s និងលំហូរកម្រិតទាប 50m$^3$/s។ លក្ខខ័ណ្ឌសេដ្ឋកិច្ច ដែលអាចធ្វើទៅបាន នៃគម្រោងវារីអគ្គិសនី **ដនសាហ៊ុង** គឺទាមទារនូវការបង្កើនលំហូរទឹកចូលទៅក្នុងប្រេក **សាហ៊ុង** ដើម្បីរក្សាលំហូរដែលបានគ្រោង ទំហំ 1620m$^3$/s។

ដើម្បីសម្រេចគោលដៅនេះ គឺតម្រូវឲ្យធ្វើការគាស់កកាយ និងកំណែប្រែទម្រង់រូបសាស្ត្រនៃច្រកផ្លូវទឹក ប៉ុន្តែការធ្វើបែបនេះនឹងបង្កផលប៉ះពាល់ដល់លំហូរទឹកនៅក្នុងច្រកផ្លូវទឹកផ្សេងៗទៀត។ ការប្រែប្រួលនោះគឺមាន៖

- ក្នុងឆ្នាំដែលមានទឹកមធ្យម (Average Year) លំហូរក្នុងច្រក សាហុង នឹងមានការកើនឡើងយ៉ាងខ្លាំងក្នុងរដូវប្រាំង ដែលលំហូរទាបជាង 1,500m³/s មានតែក្នុងចន្លោះខែកុម្ភៈ និងឧសភា ហើយលំហូរក្នុងច្រក **ផាផេង** និង**សាដាម** (បញ្ចូលគ្នា) ត្រូវបានរក្សានៅក្រោម 1,000m³/s ចាប់ពីខែធ្នូ រហូតដល់ខែឧសភា។ គឺនៅពេលដែលលំហូរខ្ពស់ចាប់ផ្តើមក្នុងរដូវវស្សា (ពីខែមិថុនាដល់ខែវិច្ឆិកា) ប៉ុណ្ណោះ ដែលលំហូរឆ្លងកាត់ល្បាក់**ផាផេង** កើនឡើង តែទោះជាយ៉ាងនេះក្តី ក៏វានៅតែទាបជាងកម្រិតលំហូរមុននៅពេលសាងសង់ទំនប់វារីអគ្គិសនី **ដន សាហុង** ដែរ។
- ពុំមានការវិភាគ នៃសេណារីយ៉ូ ល័ក្ខខ័ណ្ឌធម្មជាតិ មុនពេលសាងសង់បណ្តាទំនប់ក្នុងប្រទេសចិន និងទំហំដែលលំហូរខ្ពស់ក្នុងរដូវប្រាំង សម្រាប់ទូទាត់ជាមួយនឹងការថយចុះនៃលំហូរបណ្តាលមកពីគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង**។
- ការប្រែប្រួលលំនាំនៃលំហូរទឹក ក្នុងចំណោមបណ្តាច្រកផ្លូវទឹកផ្សេងៗ ដែលបានព្យាករណ៍ នៅពេលមានកម្រិតលំហូរទឹកទាបបំផុត កាន់តែបញ្ជាក់ថែមទៀតថា នៅពេលណាដែលលំហូរទឹកនៅក្នុងច្រក**សាហុង** អាចនឹងស្ទើរតែមិនមាន។
- លំហូរឆ្លងកាត់ល្បាក់ទឹកធ្លាក់ នឹងត្រូវបានរក្សានៅក្រោម 1,000m³/s ក្នុងចន្លោះខែវិច្ឆិកា ដល់ខែមិថុនា ហើយលំហូរក្នុងរដូវវស្សានឹងកាត់បន្ថយពី 3,000m³/sec ក្នុងខែសីហា និងកញ្ញា មកនៅក្រោម 2,000 m³/sec ក្នុងឆ្នាំដែលមានភាពរាំងស្ងួត (Dry Year)។
- ក្នុងឆ្នាំដែលមានទឹកធំ (Wet Year) លំហូរទឹកនៅក្នុងច្រក **សាហុង** នឹងត្រូវរក្សាឲ្យនៅខ្ពស់ជាង 1,500m³/s ក្នុងរយៈពេលពេញមួយឆ្នាំ ដែលលំហូរទឹកឆ្លងកាត់ល្បាក់ទឹកមានកំរិតទាបជាង 1,000m³/s ក្នុងខែកុម្ភៈ មិនា និងមេសា។ ក្នុងរដូវវស្សា នៃឆ្នាំដែលមានទឹកធំ គឺមានភាពខុសគ្នាតិចតួចនៃលំហូរទឹក រវាងល័ក្ខខ័ណ្ឌមានវត្តមាន ឬអវត្តមានគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង**។

គឺមានការលំបាកក្នុងការវាយតម្លៃឲ្យមានសុក្រិត្យភាពនូវផលប៉ះពាល់ទាំងនេះលើតម្លៃទេសចរនៃតំបន់ជុំវិញល្បាក់**ខោន**។ ជាមួយគ្នានេះ ទេសចរដែលទាក់ទងទៅនឹងការទាក់ទាញដោយល្បាក់ទឹកធ្លាក់ផ្សេងៗ បានបង្ហាញថាមានការកើនឡើងនៅពេលមានលំហូរទឹកធំ នេះគឺដោយសារពេលវេលាដែលទេសចរមកទស្សនាត្រូវគ្នានឹងពេលដែលមានលំហូរទឹកធំ ច្រើនជាងមូលហេតុ ដែលថាទេសចរមិនមកទស្សនាដោយសារមានលំហូរទឹកទាប។ ផ្ទុយទៅវិញលទ្ធភាព ដែលអាចចូលទៅតំបន់ទាំងនេះនឹងត្រូវបានធ្វើឲ្យប្រសើរឡើង ព្រោះថាគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** អាចបង្កើនទេសចរ ទន្ទឹមនឹងនេះគម្រោងក៏អាចធ្វើការសាងសង់តំបន់សម្រាប់ការទស្សនា និងតំបន់ទេសភាពផ្សេងៗទៀត។

## ៤. សន្និដ្ឋាន

ក្រុមជំនាញការខាងគុណភាពទឹក និងប្រព័ន្ធអេកូឡូស៊ី ធ្វើការសន្និដ្ឋានដូចតទៅ៖

- បញ្ហាគុណភាពទឹកក្នុងកំឡុងពេលសាងសង់គឺអាចគ្រប់គ្រងបានតាមរយៈការអនុវត្តដ៏ល្អ និងការយកចិត្តទុកដាក់គោរព និងពង្រឹងការអនុវត្តបទដ្ឋានបច្ចេកទេស នៃការសាងសង់។
- ទោះជាយ៉ាងនេះក្តី ក៏វិធានការ និងផែនការនៃគ្រោះអាសន្ន ចាំបាច់ត្រូវប្រើប្រាស់ សម្រាប់ដោះស្រាយបញ្ហាលេចធ្លាយដោយចៃដន្យ ដោយមានបុគ្គលិកដែលបានទទួលការហ្វឹកហ្វឺនសមស្រប សម្រាប់គ្រប់គ្រងព្រឹត្តិការណ៍បែបនេះ។
- អាចនឹងមានចន្លោះពេលខ្លះដូចជាក្នុងកំឡុងពេលសាងសង់ទំនប់បង្វែរទឹក និងនៅពេលបំពេញការងារនៅក្នុងប្រក **សាជាម** និង**សាំងភឿក** ដែលកករដីនឹងត្រូវបញ្ចេញចោលជាបណ្តោះអាសន្ន ចាំបាច់ត្រូវមានការគិតគូរពិចារណាអំពីការគ្រប់គ្រងការហូរច្រោះ និងកម្រិតកករដីដ៏ច្រើនដែលបញ្ចេញទៅក្នុងទន្លេ។
- រយៈពេលស្តុកទឹកដ៏ខ្លីនៃទំនប់វារីអគ្គិសនី **ដន សាហុង** មានន័យថា គុណភាពទឹកដែលមិនល្អ គឺហាក់នឹងមិនបង្កបញ្ហាទៅខ្សែទឹកខាងក្រោមនោះទេ ទន្ទឹមនឹងនេះ ការយកចេញនូវរុក្ខជាតិពីក្នុងតំបន់អាងស្តុកទឹក នឹងជួយកាត់បន្ថយបញ្ហានេះបន្ថែមទៀត។
- ហេតុនេះប្រតិបត្តិការនៃទំនប់វារីអគ្គិសនី **ដន សាហុង** ហាក់មិនធ្វើឲ្យមានការប្រែប្រួលគុណភាពទឹកនៅខ្សែទឹកខាងក្រោមនៃទន្លេមេគង្គនោះទេ។
- ទោះជាយ៉ាងនេះក្តី ការអធិប្បាយឲ្យបានប្រសើអំពីជម្រកធម្មជាតិជលសាស្ត្រនៅក្នុងតំបន់ទាំងមូល រួមទាំងសណ្ឋានរូបសាស្ត្រនៃបណ្តាប្រកផ្លូវទឹកដែលអាចរងផលប៉ះពាល់  ជម្រកធម្មជាតិ និងសារៈសំខាន់នៃអេកូឡូស៊ីរបស់វា នឹងជួយឲ្យមានការវាយតម្លៃផលប៉ះពាល់
បណ្តាលមកពីទំនប់វារីអគ្គិសនី **ដន សាហុង** បានប្រសើរជាង។
- ដោយគ្មានការវាយតម្លៃអំពីលំហូរបរិស្ថានលើបណ្តាប្រកផ្លូវទឹកដែលនឹងរងផលប៉ះពាល់ គឺជាការលំបាកមួយក្នុងការវាយតម្លៃផលប៉ះពាល់ទៅលើល្បាក់ទឹកធ្លាក់**ផាផេង**។ ទោះជាយ៉ាងនេះក្តី ក៏កិច្ចការនេះអាចនឹងធ្វើបានជាផ្នែកមួយនៃការសិក្សាម៉ូដែលលម្អិតបន្ថែមទៀតរបស់ភាគីកិច្ចសន្យា។
- មានភាពបន្ទិលខ្លះទៀតដូចជាការកើនឡើងនូវលំហូរទឹកក្នុងប្រកផ្សេងៗទៀតជាបណ្តោះអាសន្ន ក្នុងកំឡុងពេលសាងសង់ក្នុងប្រក **សាហុង**។
- ការត្រួតពិនិត្យរួមគ្នានូវគុណភាពទឹក លំហូរ និងជម្រកធម្មជាតិ និងសុខភាពប្រព័ន្ធអេកូឡូស៊ី គឺជាប្រការចាំបាច់។ ពុំមានល័ក្ខខ័ណ្ឌសម្រាប់ការត្រួតពិនិត្យលំហូរទឹក ឬគុណភាពនៃជម្រកធម្មជាតិជលសាស្ត្រនៅក្នុងផែនការគ្រប់គ្រង និងត្រួតពិនិត្យបរិស្ថាន។ បញ្ហានេះគួរតែជាសមាសភាគដ៏សំខាន់នៃយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ នៅក្នុងព្រឹត្តិការនៃឧប្បត្តិហេតុការបំពុល។
- របបលំហូរទឹកឆ្លងដែននៅក្នុងតំបន់ជាប់ព្រំដែនកម្ពុជា-ឡាវ បង្ហាញឲ្យឃើញថា មានកម្រិតប្រែប្រួលលំហូរពីមធ្យមទៅតូច ជាមួយនឹងការកើនឡើងដ៏តិចតួចនៃលំហូរទឹកក្នុងបណ្តាប្រកផ្លូវទឹកភាគខាងកើត។
- ម៉ូដែលនេះនឹងត្រូវធ្វើការផ្ទៀងផ្ទាត់តាមរយៈការត្រួតពិនិត្យជលសាស្ត្រ និងកម្រិតកម្ពស់ទឹក ហើយផលប៉ះពាល់អេកូឡូស៊ីនៃជម្រកធម្មជាតិក្នុងប្រកទឹកភាគខាងត្បូងក៏ត្រូវធ្វើការត្រួតពិនិត្យជាទៀងទាត់ដែរ។

## ៥.៥ ការសន្និដ្ឋានរួម

តាមការវិភាគ របៀបសរសេរនៃឯកសារសំណើគម្រោង គឺហាក់ចង់ទាញទៅរកការសន្និដ្ឋានថា ការសាងសង់ ប្រតិបត្តិការណ៍ និងការបញ្ចប់គម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** នឹងពុំមានផលប៉ះពាល់ដល់ខ្សែទឹកខាងក្រោមនៃទន្លេមេគង្គនោះទេ។

ការពិត វាមិនដូចនេះទេ។ ជាទូទៅផលប៉ះពាល់ ដែលអាចកើតមានឡើងគឺទាក់ទងនឹង៖

- ឥទ្ធិពលនៃសំឡេងរំខានដល់ផ្សោតទឹកសាបក្នុងតំបន់ ជាពិសេសក្នុងកំឡុងពេលសាងសង់ និងប្រតិបត្តិការស្ថានីយ៍ថាមពលវារីអគ្គិសនី។
- ទំហំនៃការធ្វើកំណែប្រែ (លំហូរទឹក និងសណ្ឋានរូបសាស្រ្ត) នៃច្រក**សាដាម** និង**សាំងភឿក** ដើម្បីជំនួសឲ្យការបាត់បង់ផ្លូវធម្មជាតិសម្រាប់ការធ្វើបន្លាស់ទីរបស់ត្រីក្នុងច្រក **សាហុង**។ កិច្ចការនេះអាចជះឥទ្ធិពលលើធនធានជលផលក្នុងតំបន់ទាំងនៅខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោម ក៏ដូចជាចំណីសម្រាប់ផ្សោតទឹកសាប។
- ការបាត់បង់ជម្រកធម្មជាតិជលសាស្រ្ត (និងជម្រកធម្មជាតិពិសេសដែលមានតែក្នុងតំបន់នេះ) ក្នុងបណ្តាច្រកដែលនឹងត្រូវរងផលប៉ះពាល់ដោយសារការកើនឡើង ឬថយចុះនៃលំហូរទឹក។
- ការថយចុះនៃលំហូរទឹកឆ្លងកាត់ច្រក**ផាផេង** ពិសេសក្នុងរដូវប្រាំង និងការបាត់បង់តម្លៃទេសចរក្នុងតំបន់។

មានកាលានុវត្តិភាពខ្លះៗ សម្រាប់ការកាត់បន្ថយ និងកែលម្អផលប៉ះពាល់ទាំងនេះ ដែលកាលានុវត្តិភាពមួយចំនួនត្រូវបានលើកឡើងដោយវិនិយោគិនគម្រោង ហើយខ្លះទៀតត្រូវបានលើកឡើងដោយក្រុមការងារជំនាញ ដោយផ្អែកលើការវាយតម្លៃឯកសារដែលមានស្រាប់។ ប្រសិនបើមានប្រសិទ្ធិភាព ជម្រើសនៃវិធានការកែលម្អទាំងនេះ នឹងបង្កើននូវទំហំដែលថា សំណើគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** ឆ្លើយតបនឹងល័ក្ខខ័ណ្ឌនៃការប្រើប្រាស់ទឹក និងធនធានធម្មជាតិដែលពាក់ព័ន្ធ ក្នុងអាងទន្លេមេគង្គ ប្រកបដោយភាពសមហេតុសមផល និងសមធម៌ ហើយដូច្នេះគឺជាប្រព័ន្ធនៃការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។ ដូចគ្នានេះដែរ វិធានការទាំងនេះឆ្លុះបញ្ចាំងនូវការយកចិត្តទុកដាក់ដ៏សមស្របក្នុងការគោរពមាត្រា3 និង7 នៃកិច្ចព្រមព្រៀងមេគង្គឆ្នាំ1995 និងគោលការណ៍បឋម របស់គណៈកម្មការទន្លេមេគង្គ ស្តីពីគ្រោងប្លង់ទំនប់វារីអគ្គិសនី នៅលើទន្លេមេនៃទន្លេមេគង្គ។

ក្នុងករណីខ្លះ ជម្រើសនៃវិធានការកែលម្អដែលបានលើកឡើងដោយវិនិយោគិនគម្រោងអាចផលនូវផលប៉ះពាល់វិជ្ជមាន ដែលបញ្ច្រាសទៅនឹងនិន្នាការអវិជ្ជមាន(ឧទាហរណ៍ ការថយចុះនៃផ្សោតទឹកសាបជាដើម) ឬក្នុងការបង្កើនទេសចរ តាមរយៈការធ្វើឲ្យប្រសើរឡើងលទ្ធភាពដែលអាចចូលទៅក្នុងតំបន់ និងល្បាក់ទឹកធ្លាក់**ផាផេង**។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ដើម្បីឲ្យវិធានការទាំងនេះមានប្រសិទ្ធិភាព ពួកគេចាំបាច់ត្រូវរៀបចំផែនការដោយការប្រុងប្រយ័ត្ន និងមានថវិកាសមស្រប។

ម៉្យាងវិញទៀត មានការឯកភាពគ្នាដ៏ទូលំទូលាយក្នុងចំណោមក្រុមអ្នកជំនាញការស្តីពីផ្សោតទឹកសាបថា ត្រូវការព័ត៌មានបន្ថែមដើម្បីធ្វើគិតគូរជម្រើសនៃវិធានការទាំងនេះឲ្យបានសមស្រប និងដើម្បីកំណត់ប្រកបដោយប្រសិទ្ធិភាពនូវទំហំ (ឬដើម្បីទាត់ចោល) ផលប៉ះពាល់នានាដែលអាចកើតមានឡើង។ ក្រុមអ្នកជំនាញបានផ្តល់អនុសាសន៍បឋមជាច្រើនទាក់ទងនឹងបណ្តាការសិក្សា ដែលអាចចាប់ផ្តើមដើម្បីដោះស្រាយសេចក្តីត្រូវការនេះ។

កិច្ចការដែលបាន និងកំពុងដំណើរការដោយក្រុមអ្នកជំនាញ នឹងផ្តោតលើការធ្វើឲ្យប្រសើរឡើងនូវការ

សិក្សាដែលបានលើកឡើងទាំងនេះ និងបង្កើតក្របខ័ណ្ឌពេលវេលា និងថវិកាសមស្របសម្រាប់ការសិក្សានេះ។

## ៦. លទ្ធផល នៃការពិគ្រោះយោបល់ក្នុងតំបន់មេគង្គ ទឹកទន្លេសាប និងនៅថ្នាក់ជាតិ

### ១. លទ្ធផល នៃការពិគ្រោះយោបល់ក្នុងតំបន់មេគង្គកម្ពុជា

កិច្ចប្រជុំលើកទី1 ដែលជាកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ក្រោមជាតិ ស្តីពីសំណើគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** សម្រាប់តំបន់មេគង្គកម្ពុជា បានរៀបចំនៅ**ថ្ងៃ**ទី17-18 ខែតុលា ឆ្នាំ2014 នៅខេត្តស្ទឹងត្រែង។ កិច្ចប្រជុំនេះ មានអ្នកចូលរួមចំនួន90នាក់ មកពី៖ លេខាធិការដ្ឋាន MRC អគ្គលេខាធិការដ្ឋានCNMC ក្រុមការងារថ្នាក់ជាតិ បណ្តាមន្ទីជំនាញពាក់ព័ន្ធ អាជ្ញាធរដែនដីថ្នាក់ក្រោមជាតិ បណ្តាសហគមន៍មូលដ្ឋាន និងតំណាងអង្គការសង្គមស៊ីវិលថ្នាក់មូលដ្ឋាន និងបណ្តាអ្នកពាក់ព័ន្ធផ្សេងៗទៀត នៃបណ្តាខេត្តតាមដងទន្លេមេគង្គចំនួន6ខេត្តគឺ៖ ខេត្តស្ទឹងត្រែង ក្រចេះ កំពង់ចាម ព្រៃវែង កណ្តាល និងតាកែវ។ កិច្ចប្រជុំមានគោលបំណង៖ ទី1)លើកកម្ពស់ការយល់ដឹងរបស់អ្នកពាក់ព័ន្ធ អំពីគម្រោងទំនប់វារីអគ្គិសនី **ដនសាហុង**។ ទី2)បង្ហាញ និងពិភាក្សាលើឯកសារគម្រោង និងលទ្ធផលបឋមនៃការសិក្សាលើឯកសារគម្រោងដោយលេខាធិការដ្ឋានMRC។ ទី3)ប្រមូលមតិយោបល់ ទស្សនៈ ក្តីកង្វល់ និងអនុសាសន៍នានាពីសំណាក់មន្ទីរជំនាញពាក់ព័ន្ធ បណ្តាសហគមន៍មូលដ្ឋាន អាជ្ញាធរថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល។ ទី4)ធ្វើសំយោគរាល់មតិទាំងអស់សម្រាប់ជាមូលដ្ឋានពិចារណាដោយសមាជិកគណៈកម្មាធិការរួម នៃគណៈកម្មការទន្លេមេគង្គ នៃភាគីកម្ពុជា និងសម្រាប់ប្រើប្រាស់ ជាការរួមចំណែកក្នុងការរៀបចំ ”ទម្រង់ឆ្លើយតបជាផ្លូវការ ក្នុងក្របខ័ណ្ឌគណៈកម្មការទន្លេមេគង្គ ” អំពីទស្សនៈរបស់កម្ពុជា លើសំណើគម្រោងវារីអគ្គិសនី **ដន សាហុង** និងផ្តោតកិច្ច ពិភាក្សាលើប្រធានបទសំខាន់2គឺ ផលប៉ះពាល់ (ជាពិសេសផលប៉ះពាល់ឆ្លងដែន) និងក្តីកង្វល់បណ្តាលពីទំនប់វារីអគ្គិសនី **ដន សាហុង** ដែលអាចនឹងកើតមានមកលើប្រទេសកម្ពុជា និងវិធានការដែលអាចជួយបញ្ចៀស កាត់បន្ថយ និងទប់ស្កាត់ផលប៉ះពាល់ទាំងនោះ។ កិច្ចប្រជុំទទួលបានលទ្ធផលដូចតទៅ៖

- បញ្ហាច្បាប់សំខាន់ៗរួមមាន៖ ទី1)ដំណើរការ នៃការពិគ្រោះយោប់ជាមុនលើសំណើគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** នៅថ្នាក់ជាតិសម្រាប់កម្ពុជា។ ទី2)ទិដ្ឋភាពទូទៅ នៃកិច្ចព្រមព្រៀងមេគង្គ និងនីតិវិធីស្តីពីការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង។ ទី3)ដំណើរការ នៃការពិគ្រោះយោបល់ជាមុននៅថ្នាក់តំបន់សម្រាប់គម្រោងទំនប់វារីអគ្គិសនី **ដនសាហុង** ត្រូវបានបង្ហាញដើម្បីជាមូលដ្ឋានយល់ដឹង។
- សារៈតា ទិដ្ឋភាពទូទៅនៃទំនប់វារីអគ្គិសនី ផលប៉ះពាល់ និងវិធានការកែលម្អ ដែលមានសរសេរក្នុងឯកសារគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** ដែលបានដាក់ជូនដោយភាគីឡាវ ក៏បានលើកមកបង្ហាញជាសង្ខេបជូនអង្គប្រជុំដើម្បីពិនិត្យ និងពិភាក្សាផងដែរ។
- លទ្ធផលបឋមនៃការសិក្សាវាយតម្លៃដោយលេខាធិការដ្ឋានMRC លើឯកសារគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** ដែលរំលេចពីចំណុចខ្វះខាត និងអនុសាសន៍ ដែលទាមទារការសិក្សាវាយតម្លៃបន្ថែមបានបង្ហាញ និងពិភាក្សាផងដែរ។ ឯកសារដែលបានពិនិត្យ និងសិក្សាវាយតម្លៃទាំងនោះ រួមមាន៖

- ឯកសារពាក់ព័ន្ធនឹងការងារបច្ចេកទេសក្នុងនោះមាន៖ ក)ឯកសារគម្រោងវារីអគ្គីសនី **ដនសាហុង** – របាយការណ៍ស្តីពីការងារសាងសង់ (ផ្នែកទី1 និងផ្នែកទី2)។ ខ)របាយការណ៍សិក្សាជលសាស្រ្ត កម្លាំងទឹក និងដីល្បាប់។ គ)របាយការណ៍សិក្សាពីឥទ្ធិពល នៃកម្លាំងទឹកឆ្លងដែន។
- ឯកសារពាក់ព័ន្ធនឹងបញ្ហាបរិស្ថាន និងសង្គម៖ ក)ការវាយតម្លៃផលប៉ះពាល់បរិស្ថាន។ ខ)ការសិក្សាផ្នែកជលផលឆ្នាំ2010 និងឆ្នាំ2013 (បន្ថែមលើរបាយការណ៍EIA)។ គ)ផែនការត្រួតពិនិត្យ និងគ្រប់គ្រងបរិស្ថាន។ ឃ)ការវាយតម្លៃផលប៉ះពាល់សង្គម។ ង)ផែនការត្រួតពិនិត្យ និងគ្រប់គ្រងសង្គម។ ច)ផែនការជម្លៀស និងប្តូរទីតាំងលំនៅដ្ឋានប្រជាពលរដ្ឋ។ និងឆ)ការវាយតម្លៃបណ្តុំផលប៉ះពាល់។ ព័ត៌មាននៅក្នុងឯកសារខាងលើគឺខ្វះខាត និងទាមទារការសិក្សាបន្ថែម មុនចាប់ផ្តើមសកម្មភាពសាងសង់ទំនប់។

- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើបទបង្ហាញ ស្តីពីផលប៉ះពាល់ដែលអាចកើតមានឡើង ចេញពីគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** មកលើធនធានជលផលកម្ពុជា។
- អង្គប្រជុំបានកំណត់ផលប៉ះពាល់ និងសំដែងក្តីកង្វល់ដែលអាចកើតមានឡើង ចេញពីគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** រួមមាន៖
    - ប៉ះពាល់ធនធានជលផល៖ ក)ដាច់ពូជត្រីកម្រ(ផ្សោតទឹកសាប អន្លង់ផ្សោត "អន្លង់ឈើទាល" និងអូរម្រះ)។ ផលប៉ះពាល់លើអន្លង់ពូជត្រី(អន្លង់សុខន)។ ផលប៉ះពាល់ការបំលាស់ទី និងប្រកផ្លូវធម្មជាតិសម្រាប់ការធ្វើបន្លាស់ទីរបស់ត្រី ដែលកាត់ផ្តាច់ការតភ្ជាប់រវាងកន្លែងពងកូន និងកន្លែងចំណីត្រី (ផលប៉ះពាល់ដល់កូនត្រីម្សៅ (ឧទាហរណ៍ កូនត្រីប្រា) អណ្តែតតាមទឹកចុះក្រោម។ ការថយចុះទិន្នផលត្រី។
    - ប៉ះពាល់បរិស្ថាន និងជីវៈចម្រុះ តំបន់ដីសើម**រ៉ាមសារ** (ទាំងរយៈពេលវែង និងខ្លី) ដូចជាក្អែកទឹក (ត្រីដែលជាចំណីមានការថយចុះ)។
    - ប៉ះពាល់ជីវភាព ប្រជាពលរដ្ឋដែលពឹងផ្អែក និងអាស្រ័យផលលើទន្លេ ចំនួន3ឃុំ 17ភូមិ សរុបចំនួន 11,542នាក់ (ស្រី4,799នាក់) ពិសេស4ភូមិនៅជាប់ទីតាំងទំនប់ (ភូមិកោះឈើទាលធំ កោះបន្ទាយ កោះលូ និងកោះញ៉ៅ) ដែលមានពលរដ្ឋចំនួន450គ្រួសារ។ ការបាក់ទំនប់ធ្វើឲ្យមានផលប៉ះពាល់ដល់ការរស់នៅ និងជីវភាពប្រជាជន។
    - ប៉ះពាល់សេដ្ឋកិច្ចសង្គម ចំណាកស្រុក (បាត់បង់ការងារប្រជាជនក្នុងមូលដ្ឋានដែលពឹងផ្អែក លើវិស័យទេសចរធម្មជាតិ(ភ្ញៀវទស្សនាផ្សោតទន្លេមេគង្គ)។ ប៉ះពាល់វប្បធម៌ជនជាតិដើមភាគតិច (ការផ្លាស់ទីលំនៅ)។
    - ផលប៉ះពាល់កិច្ចសហការឆ្លងដែន ភាគីឡាវនៅតែបន្តការសាងសង់ទំនប់។ ប្រជាពលរដ្ឋរងផលប៉ះពាល់ផ្ទាល់នឹងមានប្រតិកម្មដែលនាំឲ្យមានអសន្តិសុខក្នុងមូលដ្ឋាន។ នេះគឺដោយសារ ផលប៉ះពាល់មកលើកម្ពុជាច្រើន តែផលចំណេញបានទៅប្រទេសឡាវ។
    - ប៉ះពាល់ធនធានទឹក របបទឹកហូរនឹងថយចុះ។ ទឹកខ្វក់ប៉ះពាល់ពលរដ្ឋនៅតាមដងទន្លេ (ងូត និងបរិភោគ) និងរមាស់។

- ប៉ះពាល់នាវាចរ ទឹកនៅក្រោមទំនប់មានកម្រិតកម្ពស់ទាបធ្វើអោយប៉ះពាល់ដល់នាវាចរចុះឡើង តាមដងទន្លេ និងទៅកាន់តំបន់រ៉ែនខាំ។
- ប៉ះពាល់កសិកម្ម គឺប៉ះពាលដល់សន្តិសុខស្បៀង។ ដីល្បាប់ថយចុះធ្វើឲ្យបាត់បង់ជីរជាតិដី។ នៅរដូវប្រាំងអាចខ្វះខាតទឹកធ្វើស្រែប្រាំង។ កសិករចំណាយប្រាក់ច្រើនលើការធ្វើកសិកម្មនៅតំបន់វាលទំនាបខេត្តព្រៃវែង និងទន្លេសាប។

- អង្គប្រជុំបានផ្តល់អនុសាសន៍ខាងក្រោម ដើម្បីបញ្ចៀស កាត់បន្ថយ និងទប់ស្កាត់ផលប៉ះពាល់៖
  - បន្តការសិក្សាបន្ថែមទៀតឲ្យស៊ីជម្រៅលើ៖ ផលប៉ះពាល់ឆ្លងដែន ផ្លូវសម្រាប់ការធ្វើបន្លាស់របស់ត្រី និងជម្រកធម្មជាតិរបស់ត្រី (ដោយអ្នកសិក្សាឯករាជ្យដែលអាចទទួលយកបានពីគ្រប់ភាគី) និងធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយជាសាធារណៈជាភាសាជាតិ។
  - បើកឲ្យមានការពិគ្រោះយោបល់ពេញលេញជាសាធារណៈជាមួយភាគីពាក់ព័ន្ធ។
  - ភាគីឡាវត្រូវរង់ចាំការសិក្សាផលប៉ះពាល់ខាងលើចប់សព្វគ្រប់សិន មុនសម្រេចសាងសង់។
  - ស្នើឲ្យវិនិយោគិនគម្រោងគោរពលក្ខណ្ឌកិច្ចសន្យានៅពេលដំណើរការ និងក្រោយការសាងសង់។
  - គិតគូរពីគោលការណ៍នៃចែករំលែកផលប្រយោជន៍អោយមានសមធម៌រវាងកម្ពុជា និងឡាវ។
  - គុណភាពទឹក៖
    - ✓ រៀបចំប្រព័នទឹកស្អាត (តម្លៃថោក)
    - ✓ លើកកម្ពស់ការយល់ដឹងដល់សហគមន៍មូលដ្ឋានអំពីសុខភាពសាធារណពាក់ព័ន្ធនឹងគុណភាពទឹកដែលអាចប៉ះពាល់ពីទំនប់។
  - នាវាចរ៖
    - ✓ ជូនដំណឹងដល់ប្រជាពលរដ្ឋពីការប្រែប្រួលកម្រិតកម្ពស់ទឹក
    - ✓ ធ្វើផ្លូវគមនាគមន៍តាមដងទន្លេ
  - ជម្រុញវារីវប្បកម្ម។
  - បញ្ចៀសលំហូរចេញពីទំនប់កុំអោយប៉ះពាល់ដល់អន្លង់ផ្សោត។

## ២. លទ្ធផល នៃការពិគ្រោះយោបល់ក្នុងតំបន់បឹងទន្លេសាប

កិច្ចប្រជុំលើកទី2 ដែលជាកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ក្រោមជាតិ ស្តីពីគម្រោងទំនប់វារីអគ្គីសនី **ដនសាហុង** សម្រាប់តំបន់បឹងទន្លេសាប បានរៀបចំនៅថ្ងៃទី30-31 ខែតុលា ឆ្នាំ2014 នៅខេត្តបាត់ដំបង។ កិច្ចប្រជុំនេះ មានអ្នកចូលរួមចំនួន78នាក់ មកពី៖ លេខាធិការដ្ឋាន MRC អគ្គលេខាធិការដ្ឋានCNMC ក្រុមការងារថ្នាក់ជាតិ បណ្តាមន្ទីជំនាញពាក់ព័ន្ធ អាជ្ញាធរដែនដីថ្នាក់ក្រោមជាតិ បណ្តាសហគមន៍មូលដ្ឋាន និងតំណាងអង្គការសង្គមស៊ីវិលថ្នាក់មូលដ្ឋាន និងបណ្តាអ្នកពាក់ព័ន្ធផ្សេងៗទៀត នៃបណ្តាខេត្តជុំវិញបឹងទន្លេសាប ចំនួន6 ខេត្តគឺ៖ខេត្តកំពង់ធំ សៀមរាប បន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ និងកំពង់ឆ្នាំង។ កិច្ចប្រជុំមានគោលបំណងដូចគ្នានឹងគោលបំណងនៃកិច្ចប្រជុំលើកទី1 ខាងលើ ប៉ុន្តែផ្តោតទៅលើអ្នកចូលរួម ដែលជាបណ្តាអ្នកពាក់ព័ន្ធក្នុង

តំបន់បឹងទន្លេសាប ដែលជាតំបន់មានប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ សណ្ឋានភាពភូមិសាស្ត្រ និងសេដ្ឋកិច្ចសង្គម ពាក់ព័ន្ធនឹងគម្រោងទំនប់វារីអគ្គិសនី ដន សាហុង។

កិច្ចប្រជុំទទួលបានលទ្ធផលដូចតទៅ៖

- សិក្ខាកាមបានជ្រួតជ្រាបអំពី៖ ទី1)ដំណើរការពិគ្រោះយោបល់ជាមុនលើគម្រោងទំនប់វារីអគ្គិសនីនៅថ្នាក់ជាតិក្នុងប្រទេសកម្ពុជា។ ទី2)ទិដ្ឋភាពទូទៅនៃកិច្ចព្រមព្រៀងមេគង្គ និងនីតិវិធីស្តីពីការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង។ ទី3)ដំណើរការ នៃការពិគ្រោះយោបល់ជាមុននៅថ្នាក់តំបន់សម្រាប់សំណើគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង**។
- សារតា ទិដ្ឋភាពទូទៅ នៃគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** ផលប៉ះពាល់ និងវិធានការកែលម្អ ដែលមានសរសេរក្នុងឯកសារគម្រោង ដែលបានដាក់ជូនដោយភាគីឡាវ ក៏បានបង្ហាញជូនអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាបន្ថែមទៀតផងដែរ។
- លទ្ធផលបឋមនៃការសិក្សាវាយតម្លៃដោយលេខាធិការដ្ឋានMRC លើឯកសារគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** ក៏បានបង្ហាញ និងពិភាក្សាផងដែរ។ ឯកសារទាំងនោះរួមមាន៖
  - ឯកសារពាក់ព័ន្ធនឹងការងារបច្ចេកទេស ក្នុងនោះមាន៖ ក)ឯកសារគម្រោងវារីអគ្គីសនី**ដនសាហុង** – របាយការណ៍ស្តីពីការងារសាងសង់ (ផ្នែកទី1 និងផ្នែកទី2)។ ខ)របាយការណ៍សិក្សា ជលសាស្ត្រ កម្លាំងទឹក និងដីល្បាប់។ គ)របាយការណ៍សិក្សាពីឥទ្ធិពលនៃកម្លាំងទឹកឆ្លងដែន។
  - ឯកសារពាក់ព័ន្ធនឹងបញ្ហាបរិស្ថាន និងសង្គម៖ ក)ការវាយតម្លៃផលប៉ះពាល់បរិស្ថាន។ ខ)ការសិក្សាផ្នែកជលផលឆ្នាំ2010 និងឆ្នាំ2013 (បន្ថែមលើរបាយការណ៍ EIA)។ គ)ផែនការត្រួតពិនិត្យ និងគ្រប់គ្រងបរិស្ថាន។ ឃ)ការវាយតម្លៃផលប៉ះពាល់សង្គម។ ង)ផែនការត្រួតពិនិត្យ និងគ្រប់គ្រងសង្គម។ ច)ផែនការសង់លំនៅដ្ឋានជាថ្មី។ ឆ)ការវាយតម្លៃផលប៉ះពាល់រួម។ ព័ត៌មាននៅក្នុងឯកសារខាងលើគឺខ្វះខាត និងទាមទារការសិក្សាបន្ថែម មុននឹងចាប់ផ្តើមការសាងសង់ ផ្អែកលើលទ្ធផលបឋមដែលបានបង្ហាញ។
- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្ហាញពីផលប៉ះពាល់ដែលនឹងកើតមានឡើងចេញពីគម្រោងទំនប់វារីអគ្គិសនី **ដនសាហុង** មកលើធនធានជលផលទឹកសាប នៅក្នុងទន្លេមេគង្គកម្ពុជា និងបឹងទន្លេសាប។
- អង្គប្រជុំបានកំណត់ក្តីកង្វល់ពីទំនប់វារីអគ្គិសនី រួមមាន៖
  - ***ប៉ះពាល់ធនធានជលផល៖*** បាត់ផ្លូវបំលាស់ទីធម្មជាតិមច្ឆាជាតិនៅខ្សែទឹកខាងលើ ដែលកែប្រែដោយទំនប់។ ផ្លូវទឹកថ្មីដែលជីកសម្រាប់ឲ្យត្រីបម្លាស់ទីជាផ្លូវថ្មីងាយហូរច្រោះបាក់ដី មិនដូចផ្លូវធម្មជាតិ ហើយមិនទាន់ប្រាកដថាត្រីនឹងផ្លាស់ទីតាមផ្លូវថ្មីនេះ។ ប៉ះពាល់ជាអវិជ្ជមានដល់ផលស្តុក នៃត្រីនៅតំបន់ទន្លេសាបព្រោះកាត់ផ្តាច់ផ្លូវធ្វើបន្លាស់ទីរបស់ត្រីទៅរកកន្លែងពងកូន និងចំណី។ ពូជត្រីមួយចំនួនអាចបាត់បង់។ អាចប៉ះពាល់សត្វផ្សោតដែលជាសត្វកម្រនៅអន្លង់ឈើទាល កាំពី និងសុភ័ក្រ្តមិត្ត (ទីជម្រកធម្មជាតិ និងចំណី)។ បាត់បង់ជាតិប្រូតេអ៊ីន (ប្រជាជន កម្ពុជាភាគច្រើនបរិភោគត្រី)។ ប៉ះពាល់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ បាត់បង់ចំណូលពីការធ្វើនេសាទនាំឲ្យមានការធ្វើ

ចំណាកស្រុក (បាត់បង់ប្រពៃណីជួយទុក្ខធុរៈគ្នា)។ បាត់បង់ការងារ/មុខរបររបស់អ្នកភូមិបណ្តែតទឹក និងអ្នកនៅតាមដងទន្លេ (រាប់លាននាក់)ដែលពឹងលើការធ្វើនេសាទ។

- ***ប៉ះពាល់ទេសចរណ៍ធម្មជាតិ៖*** បាត់បង់ភ្ញៀវទេសចរជាតិ និងអន្តរជាតិទៅមើលបឹងទន្លេសាប ទៅមើលតំបន់អភិរក្សសត្វស្លាបទឹកនៅព្រៃកទាល់ក្នុងខេត្តបាត់ដំបង តំបន់អេកូទេសចរណ៍សត្វផ្សោតព្រែកកាំពី តំបន់ដីសើមរ៉ាមសានៅស្ទឹងត្រែង និងទន្លេធ្មារ (ប្រែប្រួលប្រព័ន្ធអេកូឡូស៊ី តំបន់ដីសើមដោយសារការកែប្រែផ្លូវទឹក របបទឹក/ជារទឹកខាងលើពោលគឺ ប្រែប្រួលរបបទឹកហូរ នៅច្រកសាដាមនិងសាំងគៀក នៅរដូវប្រាំង)។
- ***ប៉ះពាល់ធនធានទឹក៖*** លំហូរទឹកនឹងមានការប្រែប្រួលខុសពីលក្ខណៈធម្មជាតិ។ ពេលសាងសង់ទំនប់ធ្វើឲ្យមានកករដីខ្លាំង និងការបំពុលទឹក។ សង្ស័យថាទឹកដែលហូរពីទួប៊ីននឹងមានក្លិនស្អុយ និងខ្វះអុកស៊ីសែន។
- ***ប៉ះពាល់កសិកម្ម៖*** កសិករមិនអាចពឹងលើទម្លាប់ការងារកសិកម្ម ដោយសាររបបទឹកហូរប្រែប្រួលខុសពីលក្ខណៈធម្មជាតិ (ប៉ះពាល់ស្រូវប្រដេញទឹក)។ ទឹកឡើងខ្លាំងធ្វើឲ្យលួយស្រូវ និងផលកសិកម្មដទៃទៀត។ ដីល្បាប់ថយចុះ(ដោយសារទំនប់ខាងលើ) ធ្វើឲ្យបាត់បង់ជីវជាតិដី ដែលធ្វើឲ្យកសិករចំណាយប្រាក់កាន់តែច្រើនលើការធ្វើកសិកម្មព្រោះថា ទន្លេមេគង្គហូរនាំ ដីល្បាប់សម្រាប់កសិកម្ម។
- ***ប៉ះពាល់សេដ្ឋកិច្ច និងសង្គម៖*** ប៉ះពាល់ដល់វប្បធម៌ អរិយធម៌របស់ជនជាតិដើមភាគតិច (ការ ផ្លាស់ទីលំនៅ) បណ្តាលពីការបាក់ទំនប់ដែលអាចកើតមានឡើង។ អាចមានការបាត់បង់ជីវិតប្រជាជននៅខ្សែទឹកខាងក្រោមដែលបណ្តាលមកពីប្រតិបត្តិការមិនត្រឹមត្រូវ (បាក់ទំនប់)។ ជំងឺបណ្តាលមកពីជាតិគីមី ពីការខួងថ្ម បំបែកថ្ម ដោយទំនប់ខាងលើ (ប្រជាជនហូប និងប្រើទឹកផ្ទាល់ពីក្នុងបឹងទន្លេសាប)។
- ***ការចែករំលែកព័ត៌មានមានកម្រិត៖*** ឯកសារជាភាសាបរទេស សហគមន៍មិនយល់។ ការទទួលបានព័ត៌មានពីការសាងសង់ទំនប់ របស់ប្រជាជននៅថ្នាក់មូលដ្ឋាន មានតិចតួចបំផុត។ មិនបានអញ្ជើញសហគមន៍មូលដ្ឋាន រស់នៅតំបន់បឹងទន្លេសាបឲ្យចូលរួមពេញលេញនៅក្នុងដំណើរការពិគ្រោះយោបល់។ ក្តីកង្វល់របស់សង្គមស៊ីវិល និងសហគមន៍លើការសិក្សាពីផលប៉ះពាល់មកលើប្រទេសកម្ពុជាមិនត្រូវបានក្រុមហ៊ុនយកទៅពិចារណា និងអនុវត្តតាម។

– អង្គប្រជុំបានផ្តល់អនុសាសន៍ខាងក្រោម ដើម្បីបញ្ចៀស កាត់បន្ថយ និងទប់ស្កាត់ផលប៉ះពាល់៖
  - ចុះសិក្សាស្រាវជ្រាវបន្ថែមអំពីបណ្តុំផលប៉ះពាល់ឆ្លងដែនលើជលផល បរិស្ថាន សេដ្ឋកិច្ចសង្គម នៅក្នុងបឹងទន្លេសាបដោយឯករាជ្យ និងដោយមានការចូលរួមពីអ្នកជំនាញឯកទេសកម្ពុជា។
  - អង្គការមិនមែនរដ្ឋាភិបាលស្នើសុំបញ្ឈប់ការសាងសង់ទំនប់វារីអគ្គិសនី ឬស្នើឲ្យពន្យាពេលការសាងសង់ ទុកពេលឲ្យមានការសិក្សាស្រាវជ្រាវពីផលប៉ះពាល់ឆ្លងដែនឲ្យបានល្អិតល្អន់។
  - ផ្តល់ឱកាសការងារក្រៅពីនេសាទ។ បង្រៀនបច្ចេកទេសធ្វើកសិកម្ម (វារីវប្បកម្ម និងអាងភ្ញាស់ត្រី ចិញ្ចឹមត្រី សត្វ ដាំដំណាំ) សម្រាប់អ្នកអត់ដីស្រែ។
  - ស្នើសុំប្រព័ន្ធទឹកស្អាតសម្រាប់សហគមន៍ (ភូមិបណ្តែតទឹក)។

- ស្នើសុំជួយស្តារបឹងអភិរក្សពូជត្រី។
- ស្នើសុំកម្មវិធីពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន មុនការធ្វើសេចក្តីសម្រេចចិត្ត។
- នៅក្នុងការពិគ្រោះយោបល់ពីគម្រោងសាងសង់ណាមួយ គួរតែធ្វើជាលក្ខណៈវិស័យឬតំបន់ ដូចជាការពិគ្រោះយោបល់ ជាមួយសហគមន៍មូលដ្ឋាន គួរតែធ្វើឡើងជាច់ដោយឡែក ដើម្បីផ្តល់ឪកាសដល់សហគមន៍បានចូលរួមពេញលេញ។
- ត្រូវរៀបចំរបាយការណ៍មូលដ្ឋានមុនពេលសាងសង់ និងរបាយការណ៍ពេលប្រតិបត្តិការ សម្រាប់ផ្ទៀងផ្ទាត់ និងពិនិត្យមើលផលប៉ះពាល់បណ្តាលមកពីការសាងសង់ទំនប់។
- ការធានាពីភាគីឡាវ និងក្រុមហ៊ុនពាក់ព័ន្ធលើផលប៉ះពាល់ឆ្លងដែន (សុំបង្ហាញឲ្យបានច្បាស់ អំពីនីតិវិធីក្នុងការកាត់បន្ថយផលប៉ះពាល់) ជាពិសេសផលប៉ះពាល់ដល់តំបន់បឹងទន្លេសាប។
- ពង្រឹងវិធានការ និងយន្តការជូនដំណឹង ផ្តល់ព័ត៌មាន ឲ្យបានទាល់ពេលវេលា និងទូលំទូលាយដល់ប្រជាពលរដ្ឋ អាជ្ញាធរមូលដ្ឋាននៅខ្សែទឹកខាងក្រោម នៅពេលប្រតិបត្តិការទំនប់វារីអគ្គិសនី (ការបញ្ចេញទឹក ឬបង្ហូរទឹក នៅពេលមានទឹកជំនន់)។
- ទាមទារការចែករំលែកផលប្រយោជន៍ដល់សហគមន៍មូលដ្ឋានរស់នៅខ្សែទឹកខាងក្រោមទំនប់ ដើម្បីបំពេញការខូចខាត (ខេត្តស្ទឹងត្រែង ក្រចេះ) និងសហគមន៍តំបន់ទន្លេសាប (កំពង់ធំ ពោធិសាត់ កំពង់ឆ្នាំង បាត់ដំបង សៀមរាប និងបន្ទាយមានជ័យ)។
- អនុវត្តឲ្យបានត្រឹមត្រូវតាមកិច្ចព្រមព្រៀងមេគង្គ និងស្នើសុំបណ្តាប្រទេសផ្តល់ជំនួយ និងសហគមន៍អន្តរជាតិជួយអន្តរាគមន៍ និងសម្របសម្រួល។
- សូមឲ្យមានសមភាពរវាងប្រទេសទាំងអស់ក្នុងអនុតំបន់ទន្លេមេគង្គ (ភាគីឡាវអាចសាងសង់វារីអគ្គិសនី ភាគីកម្ពុជាក៏អាចសាងសង់បានដែរ)។
- ផ្លូវត្រីឆ្លងកាត់ត្រូវតែធ្វើអោយល្អ (ពង្រីកជម្រៅ)

## ៣. លទ្ធផល នៃការពិគ្រោះយោបល់នៅថ្នាក់ជាតិ

កិច្ចប្រជុំលើកទី3 ជាកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីគម្រោងទំនប់វារីអគ្គីសនី **ដន សាហុង** បានរៀបចំនៅថ្ងៃទី12 ខែវិច្ឆិកា ឆ្នាំ2014 នៅរាជធានីភ្នំពេញ។ កិច្ចប្រជុំនេះ មានអ្នកចូលរួមសរុបចំនួន65រូប មកពីក្រសួងស្ថាប័នពាក់ព័ន្ធ បណ្តាភ្នាក់ងាររបស់អង្គការសហប្រជាជាតិប្រចាំកម្ពុជា អង្គការសង្គមស៊ីវិល គ្រឹះស្ថានអប់រំ សិក្សាស្រាវជ្រាវសាធារណៈ សមាជិកក្រុមការងារថ្នាក់ជាតិ បណ្តាញសារព័ត៌មានក្នុងស្រុកមួយចំនួន លេខាធិការដ្ឋាន MRC និងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា។ កិច្ចមានគោលបំណងនៃកិច្ចប្រជុំគឺ ទី1)លើកកម្ពស់ការយល់ដឹងរបស់អ្នកពាក់ព័ន្ធអំពីសំណើគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង**។ ទី2)បង្ហាញ និងពិភាក្សាលើគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** និងលទ្ធផលបឋម នៃការសិក្សាលើឯកសារគម្រោងដោយលេខាធិការដ្ឋាន MRC។ ទី3)ប្រមូលក្តីកង្វល់ ទស្សនៈ និងអនុសាសន៍នានា ពីសំណាក់ភាគីពាក់ព័ន្ធ។ ទី4)ធ្វើសំយោគរាល់មតិទាំងអស់សម្រាប់ជាមូលដ្ឋាន ក្នុងការពិចារណា ដោយសមាជិកគណៈកម្មាធិការរួម នៃគណៈកម្មការទន្លេមេគង្គកម្ពុជា សម្រាប់ជាមូលដ្ឋានពិចារណា ក្នុងកិច្ចប្រជុំលើកទី4 ដែលជាកិច្ចប្រជុំពិគ្រោះយោបល់ និងបូកសរុប

ថ្នាក់ជាតិចុងក្រោយ ក្នុងចំណោមបណ្តាក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល ក្នុងកម្រិតនយោបាយ មុននឹងរៀបចំ **"ទម្រង់ឯកសារឆ្លើយតបជាផ្លូវការក្នុងក្របខ័ណ្ឌគណៈកម្មការទន្លេមេគង្គ"** ទៅប្រទេសឡាវអំពីទស្សនៈ ក្តីកង្វល់ និងយោបល់របស់កម្ពុជាលើសំណើគម្រោងវារីអគ្គិសនី **ដន សាហុង**។

កិច្ចប្រជុំទទួលបានលទ្ធផលដូចតទៅ៖

- អង្គប្រជុំបានទទួលនូវចំណេះដឹងបន្ថែមពីបទបង្ហាញដែលបានផ្តោតលើ៖ ទី1)ដំណើរការពិគ្រោះយោបល់ជាមុនលើសំណើគម្រោងវារីអគ្គសនី **ដន សាហុង** នៅកម្ពុជា។ ទី2)ព័ត៌មានពាក់ព័ន្ធនឹងគម្រោងទំនប់វារីអគ្គសនី **ដន សាហុង** និងព័ត៌មានពាក់ព័ន្ធផ្សេងៗស្តីពី ឯកសារគម្រោងទំនប់វារីអគ្គសនី **ដន សាហុង** ដែលភាគីឡាវបានដាក់ជូនប្រទេសជាសមាជិកផ្សេងៗទៀត ដើម្បីធ្វើការពិគ្រោះយោបល់ជាមុន និងលទ្ធផលនៃការវាយតម្លៃបឋមលើសំណើគម្រោងវារីអគ្គិសនី។ ទី3)ក្តីកង្វល់ នៃផលប៉ះពាល់ចេញពីទំនប់វារីអគ្គិសនី **ដន សាហុង** មកលើធនធានជលផលកម្ពុជា។ ទី4)ក្តីបារម្ភរបស់សង្គមស៊ីវិល(អង្គការមិនមែនរដ្ឋាភិបាល) អំពីការសាងសង់ទំនប់វារីអគ្គិសនី ពិសេសទំនប់វារីអគ្គសនី **ដន សាហុង**មកលើកម្ពុជា។ ទី5)ក្តីកង្វល់អំពីផលប៉ះពាល់មកលើបរិស្ថាន និងលើធនធានទឹក និងជលសាស្ត្រ បណ្តាលមកពីការសាងសង់ និងដំណើរការទំនប់វារីអគ្គិសនី **ដន សាហុង**។
- អង្គប្រជុំបានធ្វើការពិភាក្សាលើផលប៉ះពាល់ និងក្តីកង្វល់មួយចំនួន ព្រមទាំងផ្តល់អនុសាសន៍ដើម្បីកាត់បន្ថយផលប៉ះពាល់។ ជាសង្ខេបការពិភាក្សាកង្វល់ និងអនុសាសន៍ ដែលអង្គប្រជុំទាំងមូល បានផ្តល់យោបល់ និងផ្លាស់ប្តូរមតិមានដូចខាងក្រោម៖
  - ការសិក្សាវាយតម្លៃ នូវបណ្តុំនៃផលប៉ះពាល់បរិស្ថាន និងផលប៉ះពាល់ឆ្លងដែន ទាំងនៅក្នុងប្រទេសឡាវ និងនៅក្នុងប្រទេសកម្ពុជា។ ការប្រែប្រួលនៃកំណាកដីល្បាប់។
  - ផលចំណេញពីគម្រោងដល់ប្រទេសកម្ពុជា។
  - យន្តការត្រួតពិនិត្យដើម្បីបញ្ចៀសគ្រោះមហន្តរាយដែលអាចកើតមានលើកម្ពុជា។
  - ផលប៉ះពាល់លើគុណភាពទឹកបណ្តាលពីការបំផ្ទុះថ្មនៅពេលសាងសង់ទំនប់។ សារជាតុគីមី នឹងប៉ះពាល់ដល់ផ្សោត តំបន់ដីសើម**រ៉ាមសារ** និងជីវភាពប្រជាជនដែលពឹងផ្អែកលើជលផលនៅខ្សែទឹកខាងក្រោម ដែលភាគីឡាវត្រូវទទួលខុសត្រូវ។
  - យន្តការសម្រាប់ផ្អាកជាបណ្តោះអាសន្ននូវការសាងសង់ទំនប់ ដោយរង់ចាំឲ្យមានព័ត៌មានគ្រប់គ្រាន់។
  - ពេលវេលាសម្រាប់រៀបចំកិច្ចពិគ្រោះយោបល់ជាមុន នៅថ្នាក់តំបន់នាពេលខាងមុខជាការព្រួយបារម្ភមួយ ព្រោះដំណើរការ PNPCA រយៈពេល គឺ6ខែ គឺខ្លីណាស់។ មតិប្រមូលបានពីអ្នកពាក់ព័ន្ធរួមទាំងសង្គមស៊ីវិលជាការសំខាន់ក្នុងដំណើរការពិគ្រោះយោបល់ជាមុន ដែលនឹងត្រូវបញ្ចូលក្នុងកិច្ចពិភាក្សាថ្នាក់តំបន់។
  - ការចូលរួមពេញលេញរបស់អ្នកពាក់ព័ន្ធ ក្នុងដំណើរការពិគ្រោះយោបល់។ សហគមន៍មានការលំបាកក្នុងការធ្វើសេចក្តីសម្រេចចិត្តអំពីគម្រោងសាងសង់ទំនប់វារីអគ្គិសនី ព្រោះប្រជាជនមិនបានពិគ្រោះយោបល់ពេញលេញ (ពេលវេលាខ្លី)។

- តម្រូវការឲ្យមានការសិក្សាបន្ថែមអំពីការធ្វើបន្លាស់ទីរបស់ត្រី និងពូជត្រី។
- តម្លៃសេដ្ឋកិច្ច (ការវិភាគលើផលចំណេញ និងតម្លៃ) នៃគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង។**
- ផលប៉ះពាល់លើសហគមន៍រស់នៅលើកោះចំនួន4 (500គ្រួសារ) ក្នុងខេត្តស្ទឹងត្រែង។
- ការសិក្សាលើបណ្តុំផលប៉ះពាល់ឆ្លងដែន ត្រូវធ្វើដោយក្រុមប្រឹក្សាបច្ចេកទេសឯករាជ្យ និងត្រូវមានការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាខេត្ត និងសហគមន៍មូលដ្ឋាន។
- មិនមានវត្តមានតំណាងភាគីឡាវក្នុងអង្គប្រជុំថ្ងៃនេះ ដើម្បីឆ្លើយបំភ្លឺនឹងសំណួរ ដែលជាកាតព្វកិច្ចរបស់ម្ចាស់គម្រោង។
- សមត្ថភាពមានកម្រិតរបស់កម្ពុជា លើទិដ្ឋភាពបច្ចេកទេស ដែលបានលើកឡើង។ នេះជាបញ្ហាដែលយើងគួរពិចារណាទាំងអស់គ្នា។
- អនុសាសន៍ដែលបានលើកឡើងក្នុងបទបង្ហាញគួរលើកមកពិចារណាក្នុងកិច្ចប្រជុំខាងមុខ។
- កម្ពុជាមិនទាន់យល់ព្រមលើសំណើគម្រោង **ដន សាហុង** ដោយសារព័ត៌មាននៅមានការខ្វះខាត។ ប៉ុន្តែភាគីឡាវបានដំណើរការសាងសង់ទៅហើយ តើរាជរដ្ឋាភិបាលកម្ពុជាមានយន្តការហាមឃាត់ដូចម្តេច?
- ភាគីឡាវត្រូវផ្ញើឯកសារសិក្សាបណ្តុំផលប៉ះពាល់មកកម្ពុជា។

## ៧. ការវាយតម្លៃជំហរភាគីឡាវ វៀតណាម ថៃ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល

### ១. ការវាយតម្លៃ ជំហរវៀតណាម

នៅពេលដែលភាគីឡាវ ដាក់គម្រោងទំនប់វារីអគ្គិសនី ដនសាហុង មកប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ តាមរយៈនិតិវិធី <u>**ការជូនដំណឹង**</u> ពេលនោះភាគីវៀតណាមបានមានចេតនាប្រតិកម្មយឺត ដោយរង់ចាំភាគីកម្ពុជា ក្នុងការស្នើឲ្យភាគីឡាវដាក់គម្រោងនេះ ឆ្លងកាត់ការពិគ្រោះយោបល់ជាមុន ស្របទៅតាមកិច្ចព្រមព្រៀងមេគង្គ ឆ្នាំ1995។ ម្យ៉ាងវិញទៀត តាមការសង្កេតជាក់ស្តែង ភាគីវៀតណាមពុំបានលើកយកជាមតិយោបល់អ្វីជាធំដុំ នៅក្នុងកិច្ចប្រជុំនាពេលកន្លងមកនោះទេ។ វៀតណាមយល់ក្នុងចិត្តថា គម្រោងដនសាហុងនេះស្ថិតនៅឆ្ងាយពីទឹកដីរបស់ខ្លួន នឹងមិនមានផលប៉ះពាល់អ្វីដោយផ្ទាល់ដល់ប្រទេសវៀតណាម បើប្រៀបធៀបចម្ងាយនៃទីតាំងទំនប់ជាមួយភាគីកម្ពុជា។ វៀតណាមគ្រាន់តែចង់ឈរនៅជួរក្រោយក្នុងការងារនេះ ដោយទុកឲ្យកម្ពុជាធ្វើការដោយផ្ទាល់ជាមួយឡាវចុះ។ វៀតណាមនឹងមានការព្រួយបារម្ភខ្លាំង នៅពេលទំនប់វារីអគ្គិសនីទាំងអស់កើតឡើងនៅលើដងទន្លេមេ នៃទន្លេមេគង្គ ហើយជាពិសេស គម្រោងដែលមាននៅក្នុងទឹកដីកម្ពុជា។

ជាលក្ខណៈនយោបាយ ប្រទេសវៀតណាមបានថ្លែងថា ខ្លួនគាំទ្រនូវរាល់សកម្មភាពអភិវឌ្ឍន៍របស់ឡាវ និងចង់ឃើញ មានកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ នៅក្នុងតំបន់ ហើយយល់ថាការអភិវឌ្ឍន៍នៅក្នុងប្រទេសឡាវ នឹងចូលរួមវិភាគទានដល់បណ្តាសកម្មភាពសមាហរណកម្មក្នុងតំបន់ជាមួយនឹងសហគមន៍អាស៊ាន។ ក្នុងកម្រិតបច្ចេកទេស ភាគីវៀតណាម តែងតែមានយោបល់ជាទ្រឹស្តីថា គម្រោងដនសាហុង ត្រូវតែមានការសិក្សាអំពីផលប៉ះពាល់បរិស្ថានឆ្លងដែន ដ៏សមស្របមួយ មុននឹងមានការសាងសង់។

ជាការរំពឹងទុក និងដោយផ្អែកលើលទ្ធផលនៃការពិគ្រោះយោបល់ក្នុងប្រទេសជាមួយភាគីពាក់ពន្ធ័នៅក្នុងប្រទេសនោះ ភាគីវៀតណាមជាផ្លូវការ អាចនឹងស្នើឲ្យមានការសិក្សាបន្ថែមទៀត ពន្យាពេលមួយរយៈសិនមុននឹងមានការសាងសង់ គម្រោងដនសាហុងនេះ។

## ២. ការវាយតម្លៃ ជំហរថៃ

ដូចនឹងភាគីវៀតណាមដែរដែលមានប្រតិកម្មយឺត ប្រទេសថៃបានស្នើឲ្យឡាវដាក់គម្រោងនេះឆ្លងកាត់ការពិគ្រោះយោបល់ជាមុន តាមកិច្ចព្រមព្រៀងមេគង្គឆ្នាំ1995។ ជាក់ស្តែង ក្រុមការងារប្រតិភូថៃពុំបានលើកជាយោបល់អ្វីជាសំខាន់នោះទេ នៅក្នុងអង្គប្រជុំនាពេលកន្លងមក និងមិនបានបញ្ជូនប្រតិភូខ្លួន មកចូលរួមសិក្ខាសាលា ឬចូលរួមទស្សនៈកិច្ចទីតាំងទំនប់ទេ នៅក្នុងរយៈពេលកន្លះឆ្នាំដំបូង។ ជំហរថៃ បើប្រៀបធៀបគឺរិតតែស្រាលជាងវៀតណាម។ ថៃអាចយល់ថា គម្រោងដនសាហុងនេះ នឹងមិនមានផលប៉ះពាល់អ្វីដល់ខ្លួនដោយផ្ទាល់ព្រោះវាស្ថិតនៅក្បែរព្រំដែនឡាវនិងកម្ពុជា។ ម្យ៉ាងទៀត ប្រទេសថៃមានផលប្រយោជន៍រួមជាមួយប្រទេសឡាវលើគម្រោងសាយាបូរី រួចហើយ នឹងមិនចង់ប៉ះពាល់អ្វីលើទំនាក់ទំនងទ្វេភាគី ឬនៅក្នុងក្របខណ្ឌ័គណៈកម្មការទន្លេមេគង្គ។ នៅក្នុងដំណើរការពិគ្រោះយោបល់ជាមុន ប្រទេសថៃមិនបានរៀបចំជាការពិគ្រោះយោបល់ពេញលេញទេ ដោយគ្រាន់តែធ្វើជាសិក្ខាសាលាចែកចាយពត៏មាន ស្តីពីគម្រោងដនសាហុង ដែលបណ្តាលឲ្យមានការតវ៉ាយ៉ាងខ្លាំង ពីអង្គការសង្គមស៊ីវិល។

ជាការរំពឹងទុក និងដោយផ្អែកលើលទ្ធផលនៃការពិគ្រោះយោបល់ក្នុងប្រទេសជាមួយភាគីពាក់ពន្ធ័នៅក្នុងប្រទេសនោះ ភាគីថៃជាផ្លូវការ អាចនឹងស្នើឲ្យមានការសិក្សាបន្ថែមទៀត តែអាចនឹងមិននិយាយដោយចំហក្នុងការស្នើឲ្យពន្យាពេល មុននឹងមានការសាងសង់ គម្រោងដនសាហុងនេះ។

## ៣. ការវាយតម្លៃ និងជំហររបស់ភាគីឡាវ

ភាគីឡាវបានផ្តើមគម្រោងនេះ ដោយដាក់ឆ្លងត្រឹមតែតាមនិតិវិធី ការជូនដំណឹង ដែលការនេះធ្វើឲ្យប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ និងអង្គការសង្គមស៊ីវិល មានប្រតិកម្មយ៉ាងខ្លាំងអស់រយៈពេលជាងកន្លះឆ្នាំ ទើបបានប្តូរជំហរមកជា ការពិគ្រោះយោបល់ជាមុនវិញ។

ភាគីឡាវបានថ្លែងការពារគម្រោងនេះជាច្រើនដងថា គម្រោងទំនប់វារីអគ្គិសនី ដនសាហុងនេះ មិនបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាននោះទេ ហើយផលប៉ះពាល់ខ្លះៗដែលមាន អាចនឹងធ្វើការកាត់បន្ថយបាន ព្រោះគម្រោងនេះគ្រាន់តែជាការសាងសង់លើលើច្រកផ្លូវទឹកតូចមួយ មិនប្រើទឹកទន្លេមេគង្គទាំងមូល នៅតំបន់ល្បាក់ខោន ដែលមានច្រកផ្លូវទឹកជាច្រើន បើប្រៀបធៀបទៅនឹងតួទន្លេមេគង្គទាំងមូល។ រដ្ឋាភិបាលឡាវ សូមថ្លែងអំណរគុណចំពោះរាល់មតិយោបល់ និងក្តីកង្វល់ទាំងអស់ដែលបានលើកឡើង ដោយប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ និងបន្តគោរពកិច្ចព្រមព្រៀងមេគង្គ ដើម្បីការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព និងការបើកចំហានូវទិន្នន័យ និងពត៏មាន និងតម្រូវការនានា។ គម្រោងដនសាហុងនេះ នឹងជួយដល់ការរីកចម្រើនសេដ្ឋកិច្ចរបស់ប្រទេសឡាវ ហើយក៏ចូលរួមចំណែកដល់ការអភិវឌ្ឍន៍ក្នុងតំបន់ ធានាដល់គោលដៅអភិវឌ្ឍ ក្នុងតំបន់អាស៊ាន និងជាផុង

អាគុយសម្រាប់តំបន់អាស៊ីអាគ្នេយ៍។ គម្រោងនេះ នឹងបង្កើតឱកាសការងារដល់ប្រជាជនឡាវ ចូលរួមកាត់បន្ថយភាពក្រីក្រ ការបំពុលបរិស្ថាន អាកាសធាតុប្រែប្រួល រីកចម្រើនសេដ្ឋកិច្ចមូលដ្ឋាន និងសុខមាលភាពសង្គម។

## ៤. ការវាយតម្លៃ ជំហរដៃគូអភិវឌ្ឍន៍

ប្រទេសដៃគូអភិវឌ្ឍ ចង់ឃើញមានការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងគាំទ្រជានិច្ចកម្មវិធីការកាត់បន្ថយភាពក្រីក្រ របស់ប្រទេសឡាវ និងបណ្តាប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គផ្សេងៗទៀត។ ដៃគូអភិវឌ្ឍចង់បានការអភិវឌ្ឍ ដោយមានការសិក្សាត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស ស្របតាមកិច្ចព្រមព្រៀងមេគង្គមានការពិភាក្សាជាមួយគ្នា រវាងប្រទេសជាសមាជិក (ដែលដៃគូអភិវឌ្ឍបានជួយ MRCច្រើនឆ្នាំកន្លងមកហើយ) និងមានការចូលរួមពីអង្គការសង្គមស៊ីវិល និងមានវិធានការដាក់លាក់ ក្នុងការកាត់បន្ថយផលប៉ះពាល់បរិស្ថានមុនពេលធ្វើការសម្រេចចិត្តសាងសង់។

## ៥. ការវាយតម្លៃ និងជំហររបស់អង្គការសង្គមស៊ីវិល

អង្គការសង្គមស៊ីវិល ដែលបានចូលរួមយ៉ាងសកម្ម នៅក្នុងការតាមដានការងារគណៈកម្មការទន្លេមេគង្គ និងការការពារបរិស្ថាន នៅក្នុងប្រទេសកម្ពុជា និងក្នុងតំបន់មេគង្គ យល់ឃើញថាដំណើរការនៃការពិគ្រោះយោបល់ជាមុន លើគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** តាមនីតិវិធីស្តីពីការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (PNPCA) មិនត្រឹមត្រូវតាមកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥។ ប្រសិនបើទំនប់វារីអគ្គិសនី ដន សាហុង ត្រូវបានសាងសង់នោះ វានឹងមានផលប៉ះពាល់ធ្ងន់ធ្ងរដល់សត្វផ្សោត ត្រីទន្លេមេគង្គ និងការបន្លាស់ទីរបស់ត្រីនៅទូទាំងអាងទន្លេមេគង្គក្រោម និងបឹងទន្លេសាប ដែលគម្រាមកំហែងដល់សន្តិសុខស្បៀង និងការចិញ្ចឹមជីវិតរបស់ប្រជាជនរាប់លាននាក់ ក៏ដូចជាស្ថេរភាព សេដ្ឋកិច្ច និងនយោបាយក្នុងតំបន់។

ក្តីកង្វល់អំពីផលប៉ះពាល់សំខាន់ៗដូចតទៅ៖

- ត្រូវមានជាចាំបាច់ ការត្រូវសិក្សាស្រាវជ្រាវអំពីផលប៉ះពាល់ឆ្លងដែននៃគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** ដែលធ្វើឡើងដោយអ្នកជំនាញការអន្តរជាតិ ប្រកបដោយសមត្ថភាព និងឯករាជ្យ ដើម្បីផ្ទៀងផ្ទាត់ជាមួយនឹងការវាយតម្លៃផលប៉ះពាល់បរិស្ថានដែលបានធ្វើតែមួយគត់ និងជាឯកតោភាគី ដោយម្ចាស់គម្រោង ក្រុមហ៊ុនMega First Corporation Berhad (MFCB)។
- ផលប៉ះពាល់អវិជ្ជមានពីគម្រោងទំនប់វារីអគ្គិសនី ដន សាហុង ចំពោះសហគមន៍ក្នុងប្រទេសកម្ពុជា ជាពិសេសប៉ះពាល់ទៅដល់បរិស្ថាន និងជីវៈចម្រុះ។
- មិនមានការជឿជាក់ថា វិធានការបង្ការត្រូវបានអនុវត្តដោយមានប្រសិទ្ធិភាពនោះទេ។
- កង្វះខាតការសិក្សាស្រាវជ្រាវឯករាជ្យផ្នែកវិទ្យាសាស្ត្រនៅមូល ដ្ឋាន ការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមឆ្លងដែនលើសំណើគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង**។

- វិធានការកាត់បន្ថយផលប៉ះពាល់លើការផ្លាស់ទីរបស់ត្រី ដែលត្រូវបានសិក្សាដោយអ្នកជំនាញការអន្តរជាតិ ខាងជលផល ដែលបានស្នើឡើងដោយអង្គការមិនមែនរដ្ឋាភិបាល បានបង្ហាញថា ការសិក្សា EIA របស់ក្រុមហ៊ុន គឺមិនស្របតាមបទដ្ឋានអន្តរជាតិនោះទេ ហើយការដោះស្រាយដោយការធ្វើផ្លូវវាងសម្រាប់ការធ្វើបន្លាស់ទីរបស់ត្រី ក៏មិនត្រូវបានបង្ហាញផងដែរ។
- វិធីសាស្ត្រកាត់បន្ថយផលប៉ះពាល់ដែលក្រុមហ៊ុន MFCB បានរៀបចំ មិនបានធ្វើសាកល្បង និងដំណើរការ។ ឧទាហរណ៍ ការបន្លាស់ទីរបស់ត្រីដូចជាបានលើកឡើងខ្លះៗ ប៉ុន្តែមិនមានបញ្ជាក់ពីករណីដែលធ្វើបានជោគជ័យ ឬបង្ហាញថាវាអាចដំណើរការបានក្នុងបរិបទទំនប់វារីអគ្គិសនី **ដន សាហុង**។ បញ្ហានេះគួរតែជាតម្រូវចាំបាច់នៅក្នុងកិច្ចពិគ្រោះយោបល់ជាមុន។
- ទំហំ និងលទ្ធផលរំពឹងទុកនៃដំណើរការពិគ្រោះយោបល់ជាមុន មិនមានទំនាក់ទំនងច្បាស់លាស់។ វាមិនច្បាស់ពីអ្វីជាគោលបំណងនៃការពិគ្រោះយោបល់ និងអ្វីដែលយើងរំពឹងទុកលើលទ្ធផល ប្រសិនបើមានការចូលរួម។
- មិនមានតំណាងម្ចាស់គម្រោងចូលរួមនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ទាំងថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ដើម្បីធ្វើបទបង្ហាញលម្អិត និងបំភ្លឺអំពីគម្រោង។ ទង្វើនេះ គឺជាការគេចវេសពីការទទួលខុសត្រូវក្នុងការធានាឲ្យអ្នកចូលរួមយល់ច្បាស់អំពីគម្រោង វិធានការកាត់បន្ថយផលប៉ះពាល់ និងការសិក្សាផ្សេងៗទៀត។
- ការពិគ្រោះយោបល់ បានបរាជ័យក្នុងការបង្ហាញអ្វីដែលមានចំពោះជម្រើសនិរន្តរភាពជាច្រើនដូចជាគម្រោងការបង្វែរទឹកតាខូ ដែលមានកំលាំងថាមពលអគ្គិសនីដូចគ្នាជាជម្រើសថោកជាង និងផលប៉ះពាល់លើមច្ឆាជាតិ និងផ្សេត តិចជាងក្នុងខណៈដែលមានសក្តានុពលសម្រាប់នាវាចរ និងសម្របសម្រួលការដឹកជញ្ជូនរវាងប្រទេសនីមួយៗ ។
- ម្តងហើយ ម្តងទៀត រដ្ឋាភិបាលឡាវ និងក្រុមហ៊ុន MFCB បានទទូចជាសាធារណៈថា គម្រោង **ដន សាហុង** នឹងត្រូវសាងសង់ ដោយមិនគិតពីលទ្ធផលនៃការពិគ្រោះយោបល់នោះទេ។ ការសាងសង់បឋមនៃទំនប់វារី អគ្គិសនីនេះ នៅតែមិនព្រមបញ្ឈប់ ខណៈពេលដែលដំណើរការនៃ"**ការពិគ្រោះយោបល់ជាមុន**" បាននិងកំពុងបន្ត។ បើមិនមានការដោះស្រាយពីប្រទេសឡាវ និងក្រុមហ៊ុន MFCB អំពីផលប៉ះពាល់ទាំងនោះទេ នោះដំណើរការ នៃ"**ការពិគ្រោះយោបល់ជាមុន**" បាននិងកំពុងបន្ត គឺមិនមានន័យនោះទេ។
- ការពិគ្រោះយោបល់ថ្នាក់ក្រោមជាតិ ក្នុងប្រទេសកម្ពុជា បានទទួលបរាជ័យជាច្រើនដងលើគោលបំណងចំបងរបស់ខ្លួនស្តីពីការចែកចាយព័ត៌មាន អំពីសំណើគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** អោយបានច្បាស់លាស់ ទៅដល់អ្នកចូលរួម ព្រមទាំងជួយអ្នកចូលរួមឲ្យស្វែងយល់ពីគម្រោង ផលប៉ះពាល់ និងការពិភាក្សាឲ្យបានពេញលេញ ដែលចំណុចភាគច្រើន គឺសុទ្ធតែប្រកបដោយបច្ចេកទេស និងស្មុគស្មាញ។ ឧទាហរណ៍ ឯកសារពេញលេញ ដែលត្រូវចែកជូនដល់អ្នកចូលរួមភាគច្រើនជាភាសាអង់គ្លេស។ ទាំងបទបង្ហាញ និងឯកសារពេញលេញ មានពាក្យបច្ចេកទេស និងវាក្យស័ព្ទជាច្រើន ដែលពិបាកក្នុងការពន្យល់ដល់អ្នកចូលរួម។ អ្នកចូលរួម បានផ្តល់មតិតបថា ពួកគេមិនយល់នូវការធ្វើបទបង្ហាញទាំងស្រុង។

ការធ្វើបទបង្ហាញប្រញាប់ប្រញាល់ពេក មិនមានពេលវេលាគ្រប់គ្រាន់ សម្រាប់អ្នកចូលរួមផ្តល់មតិតប/ឬសំណួរ ដើម្បីបញ្ជាក់ពីចំណុចដែលពួកគាត់មិនយល់។ កត្តាទាំងនេះហើយដែលធ្វើឲ្យពួកគាត់ កាន់តែមានការភាន់ច្រឡំកាត់តែជ្រៅទៅៗ ដោយសារតែខ្វះការបញ្ជាក់ឲ្យបានច្បាស់។

- ភាពជាតំណាង **"អ្នកពាក់ព័ន្ធផ្សេងៗ"** មិនមែនជាតំណាងដ៏ពិតប្រាកដនោះទេ។ ដំណើរការនេះផ្តល់ភាពលំបាកដល់សហគមន៍ ដោយមិនបានផ្តល់ព័ត៌មាន និងពេលវេលាគ្រប់គ្រាន់សម្រាប់សហគមន៍ក្នុងការរៀបចំការពិគ្រោះយោបល់ជាមួយសមាជិករបស់ពួកគាត់ ឯកសារបានផ្ញើរជូនអ្នកចូលរួមត្រឹមតែ3ថ្ងៃប៉ុណ្ណោះមុនពេលកិច្ចប្រជុំ។ សហគមន៍ ដែលបានចូលរួមនៅក្នុងការពិគ្រោះយោបល់ មិនអាចផ្តល់ភាពជាតំណាងដល់សហគមន៍ទូទាំងខេត្តបានទេ។ ក្នុងចំណោមអ្នកចូលរួម80នាក់ មានតំណាងសហគមន៍ត្រឹមតែ 6រូប មកពីខេត្តចំនួន6 និងតំណាងអង្គការចំនួន6រូបប៉ុណ្ណោះ។ ចំនួនដ៏តិចតួចនៃតំណាងសហគមន៍ និងអង្គការនេះត្រូវបានអ្នករៀបចំចាត់ទុកថាជាអ្នកតំណាងសង្គមស៊ីវិលតាមដងទន្លេមេគង្គក្រោម។
- អ្នករៀបចំមិនបានផ្តល់ពេលវេលា និងធនធានគ្រប់គ្រាន់ដល់អ្នកចូលរួមក្នុងដំណើរការពិគ្រោះយោបល់ ក្នុងកិច្ចប្រជុំ ដូចច្នេះអ្នកចូលរួមមិនបានរៀបចំជាតុចូល និងផ្តល់យោបល់ឲ្យបានទូលំទូលាយ និងពេញលេញ។

អង្គការសង្គមស៊ីវិល សូមផ្តល់នូវអនុសាសន៍ដូចតទៅៈ

- បញ្ឈប់ការសាងសង់ទំនប់វារីអគ្គិសនី **ដន សាហុង** ជាបន្ទាន់ រួមទាំងការសាងសង់ផ្លូវ និងស្ពានជំហានដំបូង រហូតដល់ឯកសារគម្រោង និងការវាយតម្លៃផ្សេងៗពីផលប៉ះពាល់បានទទួលយកពីក្តីបារម្ភរបស់អ្នកពាក់ព័ន្ធ រួមមានរដ្ឋាភិបាលគណៈកម្មការទន្លេមេគង្គ សង្គមស៊ីវិល និងសហគមន៍មូលដ្ឋាន នៃតំបន់ទន្លេមេគង្គក្រោម។
- ធ្វើឲ្យប្រាកដថាពល់ឯកសារនានានៃសំណើគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** ត្រូវបានចែករំលែកទាំងក្នុងការសរសេរ និងនិយាយជាភាសាជាតិ នៃប្រទេសជាសមាជិក និងផ្តល់ជូនឯកសារយ៉ាងតិច 30ថ្ងៃ មុនកិច្ចប្រជុំនីមួយៗ។
- ធ្វើការសិក្សាដាច់ដោយឡែកពីគ្នានូវការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) ហេតុប៉ះពាល់បរិស្ថាន និងសង្គមឆ្លងដែន និងការសិក្សាលម្អិតពីផលប៉ះពាល់ឆ្លងដែនលើមច្ឆាជាតិ និងផ្សោត នៅខ្សែទឹកខាងក្រោម។
- ទទួលយកជម្រើសផ្តួចផ្តើមដែលមានស្រាប់ដូចជាគម្រោងបង្វែរទឹកពីព្រែកឋាខូ ដែលមានផលប៉ះពាល់តិចជាងផលប៉ះពាល់បណ្តាលពីទំនប់វារីអគ្គិសនី **ដន សាហុង** និងមានកំលាំងថាមពលអគ្គិសនីដូចគ្នា។
- បង្កើនចំនួនអ្នកតំណាងអង្គការសង្គមស៊ីវិល និងសហគមន៍មូលដ្ឋាន នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់នានា។
- សម្របសម្រួលការពិគ្រោះយោបល់ជាសាធារណៈឲ្យបានទូលំទូលាយ និងពេញលេញជាមុន សម្រាប់កិច្ចប្រជុំនៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ។ ឧទាហរណ៍ ក្នុងប្រទេសកម្ពុជាគួរមានកិច្ចពិគ្រោះយោបល់

នៅថ្នាក់ឃុំជាមួយសហគមន៍ ដែលនឹងរងផលប៉ះពាល់ផ្ទាល់ ជូនដំណឹងពួកគាត់ពីសក្តានុពលនៃទំនប់ និងប្រមូលយកការផ្តល់ព័ត៌មានត្រលប់របស់ពួកគាត់។

- ការព្រួយបារម្ភ និងការផ្តល់អនុសាសន៍ របស់សង្គមស៊ីវិល និងសហគមន៍ គួរត្រូវបានគិតគូរពិចារណា នៅគ្រប់ដំណើរការនៃការពិគ្រោះយោបល់ និងចែករំលែករបាយការណ៍ផ្លូវការទៅអ្នកចូលរួម ដើម្បីពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍ចុងក្រោយ។ សូមឲ្យកត់ត្រា និងគិតគូរពិចារណា រាល់ក្តីកង្វល់ និង មតិយោបល់របស់សង្គមស៊ីវិល និងសហគមន៍ ក្នុងគ្រប់ដំណើរការនៃការសម្រេចចិត្តលើសំណើគម្រោង ទំនប់វារីអគ្គិសនី **ដន សាហុង**។
- គណៈកម្មការទន្លេមេគង្គ និងរដ្ឋាភិបាលនៃប្រទេសជាសមាជិក គួរកំណត់ឲ្យបានច្បាស់លាស់នូវគោល បំណង និងលក្ខណៈវិនិច្ឆ័យ នៃ PNPCA មុនពេលការចាប់ផ្តើមដំណើរការពិគ្រោះយោបល់។
- ធ្វើការទាក់ទងជាមួយអ្នកចូលរួមអំពីដំណើរការឲ្យបានច្បាស់លាស់ ផ្តល់ពេលវេលាគ្រប់គ្រាន់ជាមុន សម្រាប់ការត្រៀមលក្ខណៈចូលរួម បង្ហាញឲ្យបានច្បាស់នូវតួនាទីរបស់អ្នកចូលរួម កម្រិតនៃការចូលរួម របស់ពួកគាត់ និងលទ្ធផលរំពឹងទុកនៃការពិគ្រោះយោល់ និងបញ្ជាក់ឲ្យបានច្បាស់នូវពេលវេលានៃ ដំណាក់កាលនីមួយៗ និងមានប្រព័ន្ធតាមដាន ប្រកបដោយតម្លាភាព។
- ដំណើរការពិគ្រោះយោបល់ មិនគួរធ្វើសេចក្តីសន្និដ្ឋាន និងសម្រេចចិត្ត មុនការបញ្ចប់ការសិក្សាអំពីផល ប៉ះពាល់ឆ្លងដែន និងផលប៉ះពាល់ស៊ីជម្រៅផ្សេងៗទៀតនោះទេ។
- ប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គទាំងអស់ត្រូវមានការឯកភាព និងមានការយល់ឃើញដូច គ្នាអំពីនិតិវិធីទាំងឡាយ ក្រោមកិច្ចព្រមព្រៀងមេគង្គឆ្នាំ1995 ហើយត្រូវតែគោរពឲ្យបានខ្ជាប់ខ្ជួន និង អនុវត្តឲ្យបានត្រឹមត្រូវនូវបណ្តាលិខិតបទដ្ឋានច្បាប់ទាំងនោះ។

## ៨. ការវាយតម្លៃឯកសារគម្រោង ដោយក្រសួងជំនាញកម្ពុជា

ដូចបានជម្រាបនៅផ្នែកខាងលើរួចហើយ បន្ទាប់ពីបានទទួលឯកសារគម្រោងពីភាគីឡាវ នៅខែវិច្ឆិកា ឆ្នាំ 2013រួចមក គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បានបញ្ជូនឯកសារទាំងនោះ និងបានទទួលមកវិញនូវមតិ យោបល់ ការវាយតម្លៃ លើឯកសារគម្រោងរបស់ឡាវ ពីក្រសួងស្ថាប័នជំនាញ។ បន្ថែមលើនេះ យើងមានក្រុម ការងារថ្នាក់ជាតិ មួយដែលមានគ្រប់សមាសភាពជំនាញ (គណៈកម្មាធិការជាតិទន្លេមេគង្គ, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងបរិស្ថាន, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងរ៉ែ និងថាមពល និងក្រសួង ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ) ក្រសួងពាក់ពន្ធ័ បានចូលរួមគ្រប់សកម្មភាព និងបានធ្វើការងារនេះ យ៉ាងយកចិត្តទុកដាក់ ការតាមដាន និងការវាយតម្លៃ ទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់តំបន់។

តាមរយៈការសិក្សាឯកសារគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** បណ្តាក្រសួងជំនាញពាក់ព័ន្ធ មានក្តី កង្វល់ ទស្សនៈ ការសន្និដ្ឋាន និងអនុសាសន៍ដូចតទៅ៖

## ១. ទិដ្ឋភាពវិស្វកម្ម

ក្រុមការងារមើលឃើញថាចំណុចនេះក៏ជាចំណុងដ៏សំខាន់មួយ ដែលត្រូវធ្វើការពិនិត្យ វាយតម្លៃលើឯកសារគម្រោងស្តីពីវិស្វកម្ម (Engineering) ថាតើអ្វីៗដែលវិនិយោគិនគម្រោងបានធ្វើគ្រោងប្លង់ និងសន្និដ្ឋានយ៉ាងដូច្នេះ ឬយ៉ាងដូច្នោះ ឬថាមានផលប៉ះពាល់ ឬក៏គ្មានផលប៉ះពាល់នោះ ត្រឹមត្រូវដែរឬទេ។ ទិដ្ឋភាពវិស្វកម្មនេះគឺទាមទារនូវធនធានមនុស្សដែលមានឯកទេសជាក់លាក់ និងមានសមត្ថភាពខ្ពស់ក្នុងការយល់បានឯកសាររបស់វិនិយោគិនគម្រោង ដើម្បីសិក្សា ពិនិត្យ និងវាយតម្លៃ។ ក្រុមការងារពិនិត្យឃើញថា កម្ពុជាពុំទាន់មានធនធានមនុស្សដែលមានសមត្ថភាពគ្រប់គ្រាន់សម្រាប់ធ្វើកិច្ចការនេះទេ ដែលនេះជាបញ្ហាសំខាន់សម្រាប់កម្ពុជា ពិសេសក្រសួងមានសមត្ថកិច្ចត្រូវចាប់អារម្មណ៍ និងយកចិត្តទុកដាក់បណ្តុះបណ្តាល ឬកសាង ដើម្បីបញ្ចៀសឲ្យបាននូវកង្វះខានធនធានមនុស្សលើជំនាញបែបនេះ ព្រោះថាកិច្ចការនេះនឹងមានការកើនឡើងនាពេលអនាគត។

## ២. ជលផល

- គម្រោងទំនប់វារីអគ្គិសនី ដន សាហុង នឹងធ្វើការទប់គន្លងច្រកផ្លូវទឹកសាហុង ដែលជាគន្លងដ៏សំខាន់បំផុត នៃតំបន់ល្បាក់ខោនសម្រាប់ការធ្វើបន្លាស់ទីរបស់ត្រីក្នុងរដូវប្រាំង ហើយទំនប់នេះនឹងធ្វើការបង្វែរទាញទឹករហូតដល់ជាង50% ក្នុងរដូវប្រាំង ចេញពីគន្លងផ្សេងៗទៀត ចូលមកច្រកសាហុងសម្រាប់ផលិតកម្មវារីអគ្គិសនី។ ផ្លូវសម្រាប់ការធ្វើបន្លាស់ទីនៃប្រភេទត្រីធ្វើបន្លាស់ទីឆ្ងាយ មានសារៈសំខាន់ណាស់ គឺត្រីពេញវ័យធ្វើដំណើរពីខ្សែទឹកខាងក្រោមឡើងទៅខ្សែទឹកខាងលើដើម្បីពងកូន ហើយនៅពេលពងកូនរួច ក៏វិលត្រឡប់មកវិញជាមួយនឹងពងកូនរបស់វាឆ្ពោះទៅខ្សែទឹកខាងក្រោម ដែលជាកន្លែងសម្បូរចំណីនិងមានល័ក្ខខ័ណ្ឌសមប្រកបសម្រាប់ការរស់នៅ និងលូតលាស់។ មានត្រីប្រមាណជាង 100ប្រភេទត្រូវបានគេដឹងថា ធ្វើការបន្លាស់ទីពីកម្ពុជាទៅកាន់ប្រទេសឡាវ ដើម្បីពងកូនជារៀងរាល់ឆ្នាំ។ បើទោះបីជាមានផែនការកែសម្រួលខាងផ្នែកវិស្វកម្ម និងរចនាសម្ព័ន្ធមួយចំនួនទៀត ដើម្បីជួយសម្រួលផ្លូវសម្រាប់ការធ្វើបន្លាស់ទីរបស់ត្រីក៏ដោយ ក៏ប្រសិទ្ធិភាពពិតប្រាកដរបស់វានៅមិនទាន់ដឹងច្បាស់នៅឡើយ ជាពិសេសប្រសិទ្ធិភាពសម្រាប់ការធ្វើបន្លាស់ទីឆ្លងកាត់ផ្លូវជម្រើសចំនួនពីរ ដែលគ្រោងនឹងធ្វើការកែសម្រួល គឺគន្លងសាំងភឿក និងសាដាម ក្នុងកំឡុងពេលលំហូរស្ថិតនៅកម្រិតអប្បបរមា។
- គ្រោងប្លង់នៃការកែសម្រួលវិស្វកម្ម នៃផ្លូវសម្រាប់ការធ្វើបន្លាស់ទីរបស់ត្រី និងវិធីសាស្ត្រនៃការត្រួតពិនិត្យត្រី គឺមិនទាន់មានការអធិប្បាយឲ្យបានច្បាស់លាស់ និងមិនទាន់បានផ្សព្វផ្សាយជាសាធារណៈនៅឡើយ។ ម៉្យាងទៀត វិធានការដែលបានលើកឡើងនេះ មិនទាន់បានធ្វើការសាកល្បង ហើយក៏ពុំដែលបានអនុវត្តនៅក្នុងអាងទន្លេមេគង្គដែរ ដែលនេះគឺជាហានិភ័យមួយបន្ថែមទៀត។
- បរាជ័យភាពក្នុងការធានានូវផ្លូវសម្រាប់ការធ្វើបន្លាស់របស់ត្រីឲ្យបានសមស្រប អាចនឹងបង្កនូវផលប៉ះពាល់ឆ្លងដែន និងក្នុងក្របខ័ណ្ឌអាងទន្លេទាំងមូលលើធនធានជលផល និងជីវៈចម្រុះ ជាផលវិបាកគឺនឹងជះឥទ្ធិពលអាក្រក់លើការចិញ្ចឹមជីវិត ប្រភពចំណូល និងសន្តិសុខស្បៀងនៃប្រជាជនកម្ពុជា។

- ប្រភេទត្រីនៃអាងទន្លេមេគង្គជាច្រើន រស់នៅមាននិរន្តរភាពដោយអាស្រ័យលើអន្លង់ទឹកជ្រៅៗសម្រាប់ជាជម្រកនៅរដូវប្រាំង។ ការធ្វើឲ្យប្រែប្រួល ឬផ្លាស់ប្តូរលំហូរក្នុងទន្លេ អាចនឹងបង្កនូវផលប៉ះពាល់អវិជ្ជមានលើជម្រកធម្មជាតិដ៏សំខាន់ទាំងនោះ។
- ពុំមានការសិក្សាបញ្ហាប៉ះពាល់ដល់ការបន្លាស់ទីរបស់ត្រីឆ្លងដែន រួមនឹងប្រភេទត្រីកម្រ និងប្រភេទងាយបាត់បង់ ពិសេសអន្តរទំនាក់ទំនងជាមួយបឹងទន្លេសាប (ប្រព័ន្ធអេកូឡូស៊ីតែមួយ) និងតំបន់ដីសណ្តមេគង្គ។
- ប្រតិបត្តិការវិស្វកម្ម និងការសាងសង់ទាំងក្នុងដំណាក់កាលសាងសង់ និងប្រតិបត្តិការគម្រោង នឹងបង្កផលប៉ះពាល់ធ្ងន់ធ្ងរតាមរយៈសំឡេងរំខាន និងរំញ័រ ដល់សត្វផ្សោតទឹកសាប (Irrawaddy Dolphin) ដែលជាប្រភេទកំពុងរងការគម្រាមកំហែង ដែលរស់នៅក្នុងតំបន់ប៉ែកខាងក្រោមក្នុងទឹកដីកម្ពុជា ក្នុងតំបន់ដីសើមរ៉ាមសារ ជាប់នឹងទីតាំងគម្រោង ។
- ពុំមានទិន្នន័យគោល អំពីប្រភេទត្រី និងទិន្នផលត្រីសម្រាប់ជាមាត្រដ្ឋានប្រៀបធៀបនៅពេលខាងមុខ សម្រាប់តាមដាននូវការប្រែប្រួល និងផលប៉ះពាល់។

## ៣. គុណភាពទឹក

គុណភាពទឹកនឹងត្រូវរងការគម្រាមកំហែងទៅតាមតំណាក់កាលៈ

ក) ដំណាក់កាលកំពុងសាងសង់ទំនប់ (ការគាស់កកាយបាតទន្លេ)៖

- លក្ខណៈល្អក់កករ និងផ្ទុកដោយសមាសធាតុគីមីខ្ពស់ខុសប្រក្រតី។
- សារធាតុរឹកអណ្តែតក្នុងទឹក-សារធាតុរឹងរលាយក្នុងទឹក(រួមជាមួយសំណល់ថ្ម និងកំទេចកំទីផ្សេងៗទៀត) នឹងលុបអន្លង់ជ្រៅៗ នៅតំបន់បែកខាងក្រោម។

ខ) តំណាក់កាលប្រតិបត្តិការផលិតថាមពលវារីអគ្គិសនី៖

- គុណភាពទឹកក្នុងទន្លេ អាចរងការប៉ះពាល់ខ្លះៗ។ ដោយឡែក កំហាប់ល្អក់កករ នឹងឡើងខ្ពស់ខណៈពេលបញ្ចេញសារធាតុកករ និងដីល្បាប់ ដែលបានស្ទាក់ទុកនៅផ្នែកខាងលើទំនប់។

## ៤. លំហូរទឹក កំណកដីល្បាប់ ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី

- ការស្ទាក់ទុកនូវកករដីដោយគម្រោងទំនប់វារីអគ្គិសនី ដន សាហុង ត្រូវបានគេរំពឹងថានឹងមានទំហំតូច ប៉ុន្តែបណ្តុំនៃការស្ទាក់ទុកនូវកករដី (Cumulative retention) ដោយរួមបញ្ចូលពីបណ្តាទំនប់ផ្សេងៗទៀត អាចនឹងបង្កនូវផលប៉ះពាល់ដ៏ធ្ងន់ធ្ងរដល់ជីវចម្រុះវារីសត្វ និងតំបន់ទំនាបលិចទឹកសម្រាប់កសិកម្ម ហើយបញ្ហានេះមិនទាន់បានសិក្សាឲ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ។
- កម្រិតកម្ពស់ទឹក និងលំហូរទឹកក្នុងទន្លេ អាចទទួលរងឥទ្ធិពលប៉ះពាល់មួយចំនួន ដោយសារដំណើរប្រព្រឹត្តទៅនៃទំនប់វារីអគ្គិសនី ដន សាហុង ដែលតម្រូវឲ្យមានការសិក្សាស៊ីជម្រៅ ដោយមានភស្តុតាងបញ្ជាក់ច្បាស់លាស់បន្ថែម។

- ការថយចុះនៃបរិមាណដីល្បាប់ តាមរយៈការទប់ស្កាត់លំហូរកករដីជាលក្ខណៈធម្មជាតិ ដោយជំនួសវិញនូវការបញ្ចេញកករដីដែលបានស្ទាក់ទុកនៅផ្នែកខាងលើទំនប់ (តាមពេលវេលាកំណត់)។
- ការថយចុះនៃបរិមាណផលិតភាព ដែលទ្រទ្រង់ដល់ការរីកចម្រើន នៃប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះក្នុងទឹក (Zoo-plankton & Phyto-plankton)។

## ៥. សេដ្ឋកិច្ច-សង្គម

- ពុំមានការសិក្សាបញ្ហាប៉ះពាល់សេដ្ឋកិច្ច-សង្គមដល់ប្រជាជននិងសហគមន៍នៅប៉ែកខាងក្រោម (តំបន់តាមបណ្តោយទន្លេមេគង្គ និងជុំវិញបឹងទន្លេសាប) ដែលរស់នៅពឹងផ្អែកលើអាជីវកម្មនេសាទ សន្តិសុខស្បៀង (ត្រី ស្រូវ និងដំណាំរួមផ្សំផ្សេងៗទៀត) ទេសចរណ៍ធម្មជាតិ សុខភាពប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋាន (ដោយប្រើប្រាស់ត្រីជាប្រភពប្រូតេអ៊ីន)។
- ពុំមានការយកចិត្តទុកដាក់សិក្សានិងវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សេដ្ឋកិច្ច-សង្គមក្នុងក្របខ័ណ្ឌឆ្លងដែន។
- ពុំមានបញ្ជាក់អំពីលក្ខណៈវិនិច្ឆ័យសម្រាប់ការការពារទឹកជំនន់ក្នុងអំឡុងពេលសាងសង់ (The criterion for flood protection during construction was not stated)។
- ការគោរព និងអនុវត្តកិច្ចព្រមព្រៀងមេគង្គឆ្នាំ1995 ជាកាតព្វកិច្ចរបស់ប្រទេសជាសមាជិក ដើម្បីធានាការប្រើប្រាស់ និងកិច្ចការពារធនធានទឹក នៃអាងទន្លេមេគង្គប្រកបដោយនិរន្តរភាព ផ្អែកតាមគោលការណ៍ស្មើភាព សមធម៌ អធិបតេយ្យភាព និងបូរណភាពដែនដី ដូចមានចែងក្នុងមាត្រាទី5 នៃ កិច្ចព្រមព្រៀង ខាងលើ។ ម៉្យាងទៀត នីតិវិធីនៃការពិគ្រោះយោបល់ជាមុន ដើរតួយ៉ាងសំខាន់ក្នុងការពិនិត្យវាយតម្លៃ និងផ្តល់យោបល់រាល់គម្រោងអភិវឌ្ឍនៅលើទន្លេមេ នៃទន្លេមេគង្គ។

## ៦. អនុសាសន៍

- ការប្រើប្រាស់អ្នកសិក្សា និងវាយតម្លៃឯករាជ្យ (ក្រុមហ៊ុនប្រឹក្សាផ្តល់យោបល់) ផ្អែកលើយន្តការគណៈកម្មការទន្លេមេគង្គ និងមានការឯកភាពពីគណៈកម្មាធិការជាតិទន្លេមេគង្គ នៃបណ្តាប្រទេសជាសមាជិកទាំងអស់។
- ការសិក្សា និងវាយតម្លៃផលប៉ះពាល់បរិស្ថាន និងបណ្តុំនៃផលប៉ះពាល់ក្នុងកម្រិតឆ្លងដែន (ឧទាហរណ៍ តំបន់ដីសណ្ត និងមេគង្គកម្ពុជា និងតំបន់ជុំវិញបឹងទន្លេសាប។ល។) ដោយមានការចូលរួមពីភាគីពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- ការចងក្រងទិន្នន័យគោល នៃធនធានរូបសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គម ដោយដាក់បញ្ចូលទៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន សម្រាប់ជាមាត្រដ្ឋានប្រៀបធៀប និងវាស់វែងនៅពេលខាងមុខ។
- ការសិក្សា វិភាគលើការខូចខាតបរិស្ថាន និងការចំណេញផ្នែកសេដ្ឋកិច្ច ពិសេសប្រទេសនៅតំបន់ប៉ែកខាងក្រោម។

- ការសិក្សា និងវិភាគស៊ីជម្រៅលើផលប៉ះពាល់លើប្រភពប្រាក់ចំណូល សន្តិសុខស្បៀង និងជីវភាពរស់នៅរបស់ប្រជាជន បណ្តាលមកពីការប៉ះពាល់ការធ្វើបន្លាស់ទីឆ្លងដែនរបស់ត្រី ក្នុងអំឡុងពេល និងក្រោយពេលសាងសង់ ដោយលើកឡើងពីការបាត់បង់ទិន្នផលត្រីជាសាច់ប្រាក់ និងការលើកឡើងអំពីយន្តការចាំបាច់ ដើម្បីកាត់បន្ថយជាអតិបរមា។
- ការសិក្សាលម្អិតអំពីការប្រែប្រួលកករដី និងជីមានជីវជាតិក្នុងអំឡុងពេលសាងសង់ និងគួរដាក់បញ្ចូលក្នុងរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន (Changed sedimentation and nutrient loads downstream due to excavation during the construction period should be further studies and included in the report of EIA)។
- ជ្រើសរើសម៉ូដែលណាមួយ សម្រាប់ការត្រួតពិនិត្យការបញ្ចេញកករដី ដើម្បីនាំដីល្បាប់មកភាគខាងក្រោម សម្រាប់ជីវិតនានាអាចរស់រានបាន (Choose any model for controlling the release of the sediment to the downstream for nourish life)។
- គោរពឲ្យបានខ្ជាប់ខ្ជួន លក្ខណៈវិនិច្ឆ័យសុវត្ថិភាពទឹកជំនន់សម្រាប់ការឡើងគ្រោងប្លង់ទំនប់បង្វែរទឹក (The flood safety criteria for cofferdam design recommended complying) ។
- ធ្វើការពន្យាពេលយ៉ាងតិចពីរឆ្នាំចំពោះគម្រោង ហើយចំពោះការសាងសង់ទាំងឡាយណាដែលបាន និងកំពុងដំណើរការ ត្រូវបញ្ឈប់ជាបន្ទាន់ ដើម្បីអនុញ្ញាតឲ្យមានការសិក្សាស៊ីជម្រៅ និងល្អិតល្អន់ពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមឆ្លងដែន និងទុកពេលវាលាសមស្របឲ្យគណៈកម្មការទន្លេមេគង្គ រដ្ឋបាលជលផល នៃប្រទេសកម្ពុជា និងវៀតណាម និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត បញ្ចប់ការសិក្សាពាក់ព័ន្ធសំខាន់ៗ និងចាំបាច់ ដែលលទ្ធផលនៃការសិក្សាទាំងនោះ នឹងក្លាយជាមូលដ្ឋានដ៏សំខាន់សម្រាប់ជាជំនួយលើការសម្រេចចិត្ត។

## ៧. សន្និដ្ឋាន

- ការសិក្សា និងចងក្រងឯកសារគម្រោងទំនប់វារីអគ្គិសនី ដនសាហុង ដោយក្រុមហ៊ុន មានលក្ខណៈមិនទាន់គ្រប់ជ្រុងជ្រោយ មិនឯករាជ្យភាព និងធ្វើឡើង ជាឯកតោភាគី ដោយភាគីឡាវ។
- ការដែលភាគីឡាវ បានផ្តល់ឯកសារគម្រោងតាមគេហ៍ទំព័រ ដល់បណ្តាប្រទេសជាសមាជិក មិនបានសមស្របទៅតាមនិតិវិធីពិគ្រោះយោបល់ របស់គណៈកម្មការទន្លេមេគង្គ និងបានធ្វើឲ្យរយៈពេលដែលមាន 6ខែ សម្រាប់បំពេញកិច្ចការពិគ្រោះយោបល់លើគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** សម្រាប់ការឆ្លើយតបជាផ្លូវការ ដែលខ្លីស្រាប់ផងនោះ រឹតតែរួញខ្លីបន្ថែមទៀត។
- ការអនុមត័ជាផ្លូវការដោយរដ្ឋាភិបាលឡាវ នូវឯកសារកិច្ចព្រមព្រៀងសម្បទាន និងកិច្ចព្រមព្រៀងទិញថាមពល ហើយការបញ្ជូនឯកសារទាំងនេះ ដាក់ឆ្លងសភាឡាវដើម្បីអនុមត័ មុនពេលដំណើរការពិគ្រោះយោបល់ជាមុនបានបញ្ចប់ អាចបញ្ជាក់ថាគម្រោងនេះនឹងដំណើរការទៅមុខដោយមិនគិតគូរពិចារណាពីក្តីកង្វល់មតិយោបល់ លទ្ធផលវាយតម្លៃ និងអនុសាសន៍នានា ដែលបានលើកឡើងដោយប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ និងបណ្តាអ្នកពាក់ព័ន្ធ ដែលជាមូលដ្ឋាន នៃការសម្រេចចិត្តនោះទេ។

- **ការសិក្សារបស់ក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ** (MRC Council Study) **ការសិក្សាអំពីដីសណ្តមេគង្គរបស់វៀតណាម** (Vietnam Mekong Delta Study) និងការសិក្សាអំពីការធ្វើបន្លាស់ទីរបស់ត្រីឆ្លងដែនរបស់រដ្ឋបាលជលផល (Transboundary Fish Migration) ទើបតែបាន និងកំពុងដំណើរការ ដូច្នេះចំណេះដឹងចេញពីការសិក្សាទាំងនេះ នឹងមិនត្រូវបានគិតគូរពិចារណានៅក្នុងដំណើរការ នៃ**ការពិគ្រោះយោបល់ជាមុន** លើគម្រោងនេះឡើយ។
- ការធានាអះអាងថា នឹងធ្វើការកាត់បន្ថយ ឬកែលម្អផលប៉ះពាល់ចេញពីគម្រោងទំនប់វារីអគ្គិសនី **ដនសាហុង** ឲ្យមានកម្រិតទាបបំផុត និងប្រសិទ្ធិភាព នៃវិធានការដែលបានលើកឡើងនេះ គឺជាការទទួលខុសត្រូវ និងបន្ទុករបស់រដ្ឋជាម្ចាស់ និងវិនិយោគិននៃគម្រោង។
- ការអភិវឌ្ឍន៍ទំនប់ និងថាមពលវារីអគ្គិសនីទាំងអស់ ដែលមានស្រាប់នៅលើទន្លេមេ នៃទន្លេមេគង្គ គឺប្រកបទៅដោយទំនាស់ និងមានការខ្វែងគំនិតគ្នាក្នុងចំណោមបណ្តាប្រទេសជាសមាជិក។